ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




- ខួប៦ឆ្នាំនៃការស្លាប់របស់ អៀង សារី
- ហេតុអ្វីបានជាអំពើប្រល័យពូជសាសន៍នៅតែបន្តកើតមាន?

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៣១ ខែមីនា ឆ្នាំ២០១៩

ស្វែងរកការពិត

លេខ២៣១ ខែមីនា ឆ្នាំ២០១៩

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

**សំបុត្រ**

◆ *ខួប៦ឆ្នាំនៃការស្លាប់របស់ អៀង សារី ..................................១*

◆ *ហេតុអ្វីបានជាអំពើប្រល័យពូជសាសន៍នៅតែបន្តកើតមាន? ......... ៤*

**ផ្នែកឯកសារ**

◆ *វិញ ស៊ាង អ្នកស៊ើបការណ៍របស់កងទ័ពវៀតណាម ..................៦*

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ *រឿងរ៉ាវរបស់ប្រជាជនចេញពីសហគមន៍អន្លង់វែង .................... ៩*

◆ *ខ្ញុំធ្លាក់ខ្លួនពិការដោយសារជាន់មីន ......................................២១*

◆ *នៅពេលទស្សនាល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់ ..........២៣*

◆ *ការរំឭកឡើងវិញពីអនុស្សាវរីយ៍អតីតកាល តាមរយៈការ ........ ២៧*

◆ *ការផ្សះផ្សារវាងជនរងគ្រោះ និងជនដៃដល់តាមរយៈសិល្បៈ .....៣២*

◆ *ការសម្ដែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» .............. ៣៤*

◆ *ពិធីសម្ពោធផ្ទាំងពាក្យស្លោកស្ដីពី «ការទប់ស្កាត់អំពើ ............ ៣៨*

**ផ្នែកច្បាប់**

◆ *អង្គជំនុំជម្រះសាលាដំបូង៖ ............................................ ៤២*

**វេទិកាពិភាក្សាសាធារណៈ**

◆ *តើសិល្បៈបានចូលរួមចំណែកក្នុងការអប់រំ និងទប់ស្កាត់...........៤៧*

◆ *ផ្ទាំងរូបថតរបស់ តាម៉ុក ត្រូវបានដាក់បង្ហាញលើកដំបូង ........ ៥៣*

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ *បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុក .... ៥២*

◆ *សេក មឿន ៖ ពលទាហាន .............................................៥៧*

◆ *អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ .............................................៥៩*



*តួអង្គសត្វស្វាកំពុងតែរាំរែកនៅពេលសម្ដែងល្ខោន ទម្លាយភាពស្ងៀមស្ងាត់ កាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា*

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ៣៧៥ ព.មប្រក

ចុះថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្មេរលេខនេះ៖** *សូវិចិត្រ មេត្តា, មីន សាណាស់, ផាត សិលា, រ៉ាន់ថាន់ ពៅដារ៉ា, ឡុង ដានី, ប៊ាង ពីរ័ន្ត, វេនី ខកហ្គៀល, ចាន ប្រាថ្នា, សា ហ្វាទីលី, សុភ័ក្ត្រ ភាណា* **អ្នកនិពន្ធ និងស្រាវជ្រាវ៖** *ហូ ថុនា, អ៊ុន សុដារី និង ដារ៉ារដ្ឋ មេត្តា* **អ្នកបកប្រែ៖** *អ៊ុន សុដារី* **និពន្ធនាយកទូទៅ៖** *សោម ប៊ុនថន* **ជំនួយការនិពន្ធនាយក៖** *ហូ ថុនា* **ក្រាហ្វិកកុំព្យូទ័រ៖** *គីម សុវណ្ណដានី* **គ្រប់គ្រងការចែកផ្សាយ៖** *ឆេង វើង*

**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# ខួប៦ឆ្នាំនៃការស្លាប់របស់ អៀង សារី

អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីក្រសួងការបរទេស នៃរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) បានស្លាប់ដោយសារជំងឺនៅមន្ទីរពេទ្យខ្មែរសូវៀត ស្ថិតនៅក្នុងទីក្រុងភ្នំពេញកាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ដែលគិតមកដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ នេះ មានរយៈពេល ៦ឆ្នាំមកហើយ។ ការស្លាប់របស់ អៀង សារី គឺជាការបាត់បង់ភស្តុតាងដ៏ធំធេង ទាក់ទងនឹងតួនាទីរបស់គាត់ ការដឹងឮ ការចូលរួម ការទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) ដែលបណ្តាលឲ្យប្រជាជនកម្ពុជាស្លូតត្រង់ប្រមាណជាងពីរលាន់នាក់បាត់បង់ជីវិតអស់។ ការស្លាប់របស់ អៀង សារី គឺជាការបាត់បង់អ្នកដែលទទួលខុសត្រូវដ៏សំខាន់ចំពោះបទចោទប្រកាន់នានាដែលជាប់ទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីសាលាក្តីខ្មែរក្រហម ហើយក៏ជាការបាត់បង់នូវយុត្តិធម៌ដែលជនរងគ្រោះទន្ទឹងរង់ចាំអស់រយៈពេលជាង៣០មកហើយដែរ។

អៀង សារី កើតនៅឆ្នាំ១៩២៥ នៅខេត្តត្រាវិញ ប្រទេសវៀតណាមខាងត្បូង។ អៀង សារី គឺជាអតីតសិស្សនៅវិទ្យាល័យស៊ីសុវត្ថិ ក្នុងក្រុងភ្នំពេញ។ អៀង សារី បានទទួលអាហារូបករណ៍ទៅសិក្សានៅវិទ្យាល័យកុងដ័រសេ និងវិទ្យាស្ថានសិក្សានយោបាយ ក្រុងប៉ារីស ប្រទេសបារាំង។ អៀង សារី បានចូលជាសមាជិកបក្សកុម្មុយនីស្តបារាំងក្នុងឆ្នាំ១៩៥១។ អៀង សារី បានវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៥៧ ហើយបានចូលជាសមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរ។ អៀង សារី បានក្លាយជាគ្រូបង្រៀនប្រវត្តិវិទ្យានៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងវិទ្យាល័យកម្ពុជបុត្រ និងជាសមាជិកសកម្មនៃបក្សកុម្មុយនីស្តកម្ពុជា។ អៀង សារី បានរត់ចូលព្រៃ ដើម្បីចូលរួមជាមួយចលនាខ្មែរក្រហម នៅឆ្នាំ១៩៦៣។ ក្រោយមក អៀង សារី បានកាន់តំណែងជាមេបញ្ជាការកងទ័ពនៅភូមិភាគឦសាន។ ក្នុងអំឡុងសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧១-១៩៧៥ អៀង សារី បានចូលរួមជាមួយរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងជាបេសកជនពិសេសរបស់រណសិរ្សរួបរួមជាតិខ្មែរ។

ពេលដែលខ្មែរក្រហមឡើងកាន់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អៀង សារី គឺជាឧបនាយករដ្ឋមន្ត្រីទីមួយ ទទួលបន្ទុកកិច្ចការបរទេស។ អៀង សារី ក៏ជាសមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍បក្សដែរ។ អៀង សារី បានរត់គេចខ្លួនទៅប្រទេសថៃនៅពេល



អៀង សារី នៅសាលសវនាការ
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដែលរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩។ អៀង សារី ត្រូវបានកាត់ទោសកំបាំងមុខពីបទប្រល័យពូជសាសន៍ និង ត្រូវផ្តន្ទាទោសប្រហារជីវិតដោយតុលាការប្រជាជនបដិវត្តន៍ កម្ពុជានៅភ្នំពេញ។ ទោះបីយ៉ាងណា អៀង សារី បានបន្តតួនាទី របស់ខ្លួន ក្នុងរដ្ឋាភិបាលនិរទេស ប៉ុន្តែបានផ្ទេរមុខតំណែង ជារដ្ឋមន្ត្រីការបរទេសទៅឲ្យ ខៀវ សំផន បន្ទាប់ពីការបង្កើត រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ក្នុងឆ្នាំ១៩៨២។ បញ្ជូនទៅជំនុំជម្រះ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មនុស្សឃាត ការ ធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា ដែល មានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងផ្តន្ទាទោសតាម មាត្រា ៣ (ថ្មី) មាត្រា៤, ៥, ៦, ២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ


រូបឈរខាងមុខ អៀង សារី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អៀង សារី បានចាកចេញពីចលនាខ្មែរក្រហមជាមួយនឹង កងកម្លាំងយោធារាប់ពាន់នាក់នៅស្រុកម៉ាឡៃ មកចុះចូលជា មួយរាជរដ្ឋាភិបាលកម្ពុជា នៅខែសីហា ឆ្នាំ១៩៩៦ ជាថ្នូរនឹង ព្រះរាជក្រឹត្យលើកលែងទោសចំពោះសាលក្រមឆ្នាំ១៩៧៩។

អៀង សារី ត្រូវបានចាប់ និងឃុំខ្លួនដោយអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា នៅខែវិច្ឆិកា ឆ្នាំ២០០៧ ដោយ សាររកឃើញថា គាត់មានការជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្ត បទឧក្រិដ្ឋធ្ងន់ធ្ងរ។ អៀង សារី ត្រូវបានចោទប្រកាន់ និង កម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

នៅក្នុងសំណុំរឿងដែលបញ្ជូនទៅជំនុំជម្រះខាងលើ អៀង សារី ត្រូវបានចោទថា មានការទទួលខុសត្រូវតាមរយៈការ ធ្វើសកម្មភាព ឬបរាជ័យក្នុងការទប់ស្កាត់ (រួមបញ្ចូលទាំងការ ប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម) បញ្ជា ញុះញង់ រៀបចំ ផែនការ ដឹកនាំ ឬសមគំនិត ដោយការជួយឬជំរុញ ឬបង្ក លក្ខណៈងាយស្រួលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬទទួលខុស ត្រូវក្នុងនាមជាអ្នកដឹកនាំចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត

នៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ៖

- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖ មនុស្សឃាត ការសម្លាប់ផ្ដាច់ពូជ ការដាក់ក្នុង មន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត។

- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ៖ ការសម្លាប់ក្រុមជនជាតិវៀតណាម និង ចាម។



អៀង សារី និង អៀង ធីរិទ្ធិ នៅប៉ៃលិន (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

- ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ៖ មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្មឬការប្រព្រឹត្តអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរឬឲ្យមានការឈឺចាប់ដល់រូបរាងកាយឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ក្ដី ដោយយុត្តិធម៌ ការបង្ខាំង និងការនិរទេសជនស៊ីវិលដោយខុសច្បាប់។

- អំពើមនុស្សឃាត ៖ ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

ទោះបី អៀង សារី បានស្លាប់ទៅដោយមិនទាន់មានការផ្ដន្ទាទោសពីសាលាក្ដីខ្មែរក្រហមក៏ដោយ ក៏ឈ្មោះ និងបទឧក្រិដ្ឋរបស់គាត់ត្រូវបានប្រជាជនទូទៅដឹងឮ និងបានចារទុកក្នុងប្រវត្តិសាស្ត្រនៃការសម្លាប់យ៉ាងរង្គាលនៅក្នុងរបបខ្មែរក្រហម។ ប្រវត្តិសាស្ត្រមិនមែនជាតុលាការ ប៉ុន្តែប្រវត្តិសាស្ត្របានចារទុកអ្នកដែលបានប្រព្រឹត្តអំពើឃោរឃៅ និងការសម្លាប់សម្រាប់មនុស្សគ្រប់ជំនាន់។

អៀង សារី បានបដិសេធរាល់បទចោទប្រកាន់ទាំងអស់មកលើរូបគាត់ ហើយក្នុងសវនាការគាត់ក៏បានអនុវត្តសិទ្ធិមិនឆ្លើយតបទៅនឹងសំណួររបស់សហមេធាវី និងព្រះរាជអាជ្ញាទាក់ទងនឹងបទឧក្រិដ្ឋជាច្រើន ដែលជាប់ពាក់ព័ន្ធជាមួយរូបគាត់រហូតដល់ថ្ងៃស្លាប់។

សោម ប៊ុនថន

# ហេតុអ្វីបានជាអំពើប្រល័យពូជសាសន៍នៅតែបន្តកើតមាន?

នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ គឺជាថ្ងៃដែលអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ត្រូវបានអនុម័តដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាមួយសេចក្តីសម្រេចលេខ២៦០។ ការអនុម័តនេះ គឺមានរយៈពេលមុនមួយថ្ងៃនៃការប្រកាសសិទ្ធិមនុស្សជាសកល នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ដែលបានអនុម័តដោយអគ្គលេខាធិការអង្គការសហប្រជាតិ នៅឯមហាសន្និបាតលើកទី៣ ជាមួយសេចក្តីសម្រេចលេខ២១៧ នៅព្រះរាជវាំងឆាឡូត ក្នុងទីក្រុង ប៉ារីស ប្រទេសបារាំង ដែលមានសមាជិកចំនួន៤៨ ប្រទេសក្នុងចំណោម ៥៨ប្រទេស បានបោះឆ្នោតគាំទ្រ។

មកដល់ខែធ្នូ ឆ្នាំ២០១៨ នេះ អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងសេចក្តីប្រកាសសិទ្ធិមនុស្សជាសកល មានរយៈពេល៧0ឆ្នាំមកហើយ ប៉ុន្តែ យើងនៅតែសង្កេតឃើញថា អំពើប្រល័យពូជសាសន៍នៅតែកើតមាននៅជុំវិញពិភពលោកដដែល។

ប្រទេសកម្ពុជាបានចូលជាសមាជិករបស់អង្គការសហប្រជាជាតិ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥ (គឺមានរយៈពេលពីរឆ្នាំបន្ទាប់ពីប្រទេសកម្ពុជាបានទទួលឯករាជ្យទាំងស្រុងពីប្រទេសបារាំង នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣)។ ប៉ុន្តែ ប្រទេសកម្ពុជា មានកាតព្វកិច្ចត្រូវគោរពតាមធម្មនុញ្ញដែលអនុម័តដោយអង្គការសហប្រជាជាតិ រួមមាន អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍


អដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហម នៅវត្តឫស្សីសាញ់ ក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


អតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហម នៅវត្តសំរោងក្នុង ខេត្តបាត់ដំបង (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


ស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហម នៅវត្តឫស្សីសាញ់ ក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


ព្រះវិហារវត្តសំរោងក្នុង ខេត្តបាត់ដំបង (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

នៅពេលអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងសេចក្តីប្រកាសសិទ្ធិមនុស្សជាសកលត្រូវបានយកចិត្តទុកដាក់ពីអង្គការ និងសហគមន៍អន្តរជាតិនានា ជាពិសេសប្រទេសលោកខាងលិច ខណៈនោះក្រុមខ្មែរក្រហម បានខិតខំឆ្លៀតឱកាសឃោសនា អូសទាញទឹកចិត្តប្រជាជននៅតាមទីជនបទដាច់ស្រយាលកាន់តែខ្លាំងឡើង ឲ្យងាកមកគាំទ្រចលនាតស៊ូបដិវត្តន៍របស់ខ្លួនប្រឆាំងនឹងរបបដឹកនាំមុនៗ។ ខ្មែរក្រហមបានបណ្តុះគំនិតប្រជាជនឲ្យមានគំនិតស្អប់ គុំគួន និងចងកំហឹងចំពោះមេដឹកនាំ និងរបបមុនៗ។ ចាប់តាំងពីខ្មែរក្រហមបានឡើងកាន់អំណាចពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបនេះបានហាមឃាត់ប្រជាជនក្នុងការប្រើប្រាស់សិទ្ធិ សេរីភាព ដែលប្រទេសកម្ពុជាបានទទួលស្គាល់ និងដែលបានចែងក្នុងសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីអំពីសិទ្ធិមនុស្សថា គ្មានការប្រកាន់ បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិ នយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើត ជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាព ដទៃៗទៀតឡើយ។

ខ្មែរក្រហមមិនត្រឹមតែមិនបានអនុវត្តសេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្សទាំងនោះទេ ផ្ទុយទៅវិញខ្មែរក្រហមបានប្រព្រឹត្តរំលោភបំពានថែមទៀតទៅលើអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលបានចែងថា អំពើប្រល័យពូជសាសន៍គឺជាអំពើដែលបានប្រព្រឹត្តដោយមានចេតនាដាក់លាក់ ដើម្បីបំផ្លាញទាំងស្រុងឬដោយផ្នែកទៅលើក្រុមជាតិ ក្រុមជាតិពន្ធុពូជសាសន៍ ឬសាសនា។ អំពើទាំងនោះរួមមាន៖

- អំពើមនុស្សឃាតលើសមាជិកក្រុម។
- ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើរាងកាយ ឬផ្លូវចិត្តនៃសមាជិកក្រុម។
- ការដាក់ដោយចេតនានូវក្រុមមនុស្សនៅក្រោមលក្ខខណ្ឌរស់នៅលំបាកដែលនាំឲ្យមានការបំផ្លាញសុខភាពទាំងស្រុង ឬដោយផ្នែក។
- វិធានការដែលរារាំងដល់ការមានគភ៌ដល់សមាជិកក្រុម។
- ការជម្លៀសកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយទៀត។

ដោយបានអនុវត្តនូវការគ្រប់គ្រងតាមបែបផ្តាច់ការ និងតឹងរឹងជ្រុលហួសហេតុ របបខ្មែរក្រហមបានសម្លាប់ប្រជាជនខ្មែរស្លូតត្រង់អស់ប្រមាណជិតពីរលាននាក់។ ទោះបីរបបនេះបានដួលរលំ នៅឆ្នាំ១៩៧៩ ទៅហើយក្តី ប៉ុន្តែរបបនេះបានបំផ្លាញស្ទើរទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្សកម្ពុជា និងបានបន្សល់នូវស្ត្រីមេម៉ាយ ក្មេងកំព្រា ជនពិការការបែកបាក់ និងជំងឺបាក់ស្បាតរហូតមកដល់សព្វថ្ងៃនេះ។

សហគមន៍អន្តរជាតិ ធ្លាប់បានដឹងពីការកាប់សម្លាប់រង្គាលនៅក្នុងប្រទេសកម្ពុជា ពីចន្លោះឆ្នាំ១៩៧៥-១៩៧៩ ដែលបានប្រព្រឹត្តដោយក្រុមខ្មែរក្រហម និងប្រទេសមួយចំនួនទៀត ដូចជា ប្រទេសបូស្នី ប្រទេសរ៉្វាន់ដា និងប្រទេសយូហ្គោស្លាវី រួចហើយក្តី ក៏រហូតមកដល់សព្វថ្ងៃ ក៏យើងនៅតែសង្កេតឃើញការសម្លាប់រង្គាល នៅតែបន្តកើតមាននៅប្រទេសមួយចំនួន រួមមាន៖ នៅភាគខាងជើងប្រទេសអ៊ីរ៉ាក់ នៅប្រទេសស៊ីរី និងនៅប្រទេសភូមា។ ជារឿយៗវិធានការទប់ស្កាត់ការសម្លាប់រង្គាលតែងតែមានភាពយឺតយ៉ាវ និងមិនត្រូវបានអើពើ និងយកចិត្តទុកដាក់ដោយសារពាក់ព័ន្ធនយោបាយក្នុងតំបន់ និងសកលលោក។ ដូច្នេះដើម្បីទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍នេះ កើតឡើងទៅថ្ងៃខាងមុខ មេដឹកនាំប្រទេសទាំងអស់ត្រូវតែមានឆន្ទៈរួមគ្នា និងអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវ អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងអន្តរាគមន៍ទប់ស្កាត់ ឲ្យបានទាន់ពេលវេលាចំពោះអំពើទាំងឡាយណាដែលនាំទៅរកការប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍។

**សោម ប៊ុនថន**

# ទិញ ស៊ាង អ្នកស៊ើបការណ៍របស់កងទ័ពវៀតណាម

## ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខD០៧១៣៤

ខ្ញុំឈ្មោះ វិញ ស៊ាង ឬ វិន ស៊ាង ភេទប្រុស អាយុ ៣១ឆ្នាំ មានស្រុកកំណើតនៅភូមិអន្លុងថ្មី ឃុំស្វាយទង ស្រុកស្វាយទង ខេត្តមាត់ជ្រូក (ហៅ អាងយ៉ាង)។ ខ្ញុំមានតួនាទីជាអនុសេនីយ៍ឯករបស់កងទ័ពវៀតណាម។ ខ្ញុំត្រូវបានយោធារបស់ខ្មែរក្រហមចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៧៨។ ខ្ញុំត្រូវបាន យោធាខ្មែរក្រហមសួរចម្លើយចំនួន២លើក។ លើកទី១ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៨ និងលើកទី២ នៅខែមីនា ឆ្នាំ១៩៧៨។ ខាងក្រោមនេះជាសកម្មភាពរបស់ខ្ញុំមុនខ្មែរក្រហមចាប់ខ្លួន ៖

នៅឆ្នាំ១៩៧៧ ខ្ញុំមានមុខរបរជាអ្នករកស៊ីជួសជុលវិទ្យុនៅផ្សារមាត់ជ្រូក។ នៅខែធ្នូ ឆ្នាំ១៩៧៨ ខ្ញុំបានចូលបម្រើកងទ័ពវៀតណាម និងមានតួនាទីជាពលបាលទោ។ ខ្ញុំក៏ត្រូវបានអប់រំជា ហូរហែផងទាក់ទងនឹងមាគ៌ានយោបាយ សតិអារម្មណ៍ ស្ដីពីយុទ្ធសាស្ត្រក្នុងការគ្រប់គ្រង និងដឹកនាំ ឥណ្ឌូចិន។ មាគ៌ានយោបាយរបស់កងទ័ពវៀតណាម បានយកទ្រឹស្ដីរបស់ ហូ ជីមិញ និងត្រូវធ្វើការ វាយមកលើប្រទេសកម្ពុជា។

ខ្ញុំនៅផ្នែកខាងជួសជុលវិទ្យុទាក់ទងរបស់អនុសេនាតូចលេខ២ អនុសេនាធំលេខ៦ វរសេនា តូចលេខ២៨ វរសេនាធំលេខ១៦ កងពលតូចលេខ៣២ កងពលធំលេខ៨៥។ កងពលលេខ៣២ បានចាប់ផ្ដើមបង្កើតឡើងនៅក្នុងខែមករា ឆ្នាំ១៩៧៨។ កងពលតូចលេខ៣២ មានកងទ័ពចំនួន ប្រមាណជា ២០០០នាក់។ ចំណែក ទីតាំងបញ្ជាការរបស់កងពលតូចលេខ៣២ ស្ថិតនៅចន្លោះ ភ្នំកែត ខាងកើតឆៀងខាងជើង ដែលមានទំហំប្រមាណជា ៥០ម៉ែត្របួនជ្រុង។ កងកម្លាំងដែលបាន ចាត់តាំងឲ្យចូលកងពលតូចលេខ៣២ រួមមានការចាត់តាំងពីកម្លាំងថ្មី, យុវជនមកពីហាណូយ, យុទ្ធជនរត់ចេញ ឬរត់ចូលដែលមិនទាន់មានភាពច្បាស់លាស់ថា ខ្លួនត្រូវចូលខាងណា, ការប្រមូលគ្នារបស់ក្រុមយុទ្ធជនរត់ចោលជួរ និងយុទ្ធជនថ្មីមករៀនបំពេញនៅអង្គភាព។ អង្គភាពកងពលតូច លេខ៣២ មានចំនួន៤វរសេនាធំ រួមមានវរសេនាធំលេខ៧, ១៦, ២២ និងវរសេនាធំលេខ១៩។ ក្នុងនោះវរសេនាធំលេខ១៦ គឺជាកងដែលមានតួនាទីស៊ើបការណ៍។ ឈ្មោះ ថាច់ វ៉ាន់ថុង ជាអ្នក មើលការខុសត្រូវ ដែលមានតួនាទីជាវរសេនីយ៍ត្រី (ស័ក្តិ៤)។ អង្គភាពកងពលតូចលេខ៣២ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលធំលេខ៨៥ ដែលមានបោះទីតាំងនៅជាមួយគ្នា។ អង្គភាពកងពលធំលេខ៨៥ ដែលមានឈ្មោះ សៅ មានតួនាទីជាវរសេនីយ៍ឯក (ស័ក្តិ៥) ជាអ្នកដឹកនាំ។ អង្គភាពកងពលធំលេខ៨៥ នេះមានជនជាតិរុស្ស៊ីចំនួន៣នាក់ ជាអ្នកក្តាប់ពីលើមេបញ្ជាការយោធា និងមានជនជាតិគុយបាចំនួន១៨នាក់ ដែលជាអ្នកត្រួតពិនិត្យ វិភាគព្រមទាំងតាមដានសមរភូមិមុខ តាមដែនទឹក។

ជីវភាពរស់នៅប្រចាំថ្ងៃរស់នៅក្នុងកងពល មានភាពលំបាកខ្លាំងណាស់ អាហារហូបមាន ត្រឹមតែចុងអង្ករក្រហមលាយជាមួយកន្ទក់ ហើយជួនកាលផ្គត់ផ្គង់ មិនបានគ្រប់គ្រាន់ទៀត។ ពេលខ្លះ ខ្ញុំមានបំណងចង់រត់ចេញពីអង្គភាព៣ទៅ៤លើករួចមកហើយ ព្រោះខ្ញុំនឹករឭកប្រពន្ធ និងកូន។ ខ្ញុំក៏បានគិតពីការអត់ឃ្លាន និងសេចក្ដីលំបាកវេទនារកស៊ីចិញ្ចឹមកូនរបស់ប្រពន្ធខ្ញុំដែរ។ ប៉ុន្តែខ្ញុំមិនហ៊ានរត់ ព្រោះខ្លាចគេបាញ់សម្លាប់។

នៅថ្ងៃទី៥ ខែមីនាឆ្នាំ ១៩៧៨ ថាច់ វ៉ាន់ថុង វរសេនីយ៍ត្រី (ស័ក្តិ៤) បានចុះណែនាំ និងមកអប់រំខ្ញុំ។ ក្នុងការណែនាំនោះ ថាច់ វ៉ាន់ថុង បាននិយាយពីផែនការវាយកម្ពុជាឲ្យខ្ទេច

និងធ្វើឧបាយកលយ៉ាងណា ដើម្បីឲ្យកម្ពុជាយល់ព្រមចុះញ៉មប្រទេសវៀតណាម។ កម្ពុជាក៏ត្រូវយល់ព្រម ចូលសហព័ន្ធឥណ្ឌូចិន ដែលមានវៀតណាមជាអ្នកគ្រប់គ្រង ហើយកងទ័ពវៀតណាម ក៏មានមហិច្ឆតាក្នុងកាគ្រប់គ្រងអាស៊ីអាគ្នេយ៍ទាំងមូលផងដែរ។ ក្នុងការប្រជុំ មានសូវៀតជាអ្នកជំរុញ ព្រមទាំងមានការធានាជួយឧបត្ថម្ភសម្ភារទាំងអស់ទៀតផង។ ដោយសារខ្ញុំចេះភាសាខ្មែរច្បាស់ ខ្ញុំក៏ត្រូវបានកងទ័ពវៀតណាមបញ្ជូនមកប្រទេសកម្ពុជា ដើម្បីឲ្យស៊ើបការណ៍នៅតំបន់ភ្នំដិន។ រដ្ឋាភិបាល បាលវៀតណាមបានប្រើផែនការទាំងពីរក្នុងការដោះស្រាយបញ្ហាព្រំដែន គឺនយោបាយខាងក្នុង និងខាងក្រៅ។ ពោលគឺនយោបាយខាងក្រៅយើងបានយកនយោបាយការទូតយកមកដោះស្រាយ ដោយធ្វើកាអំពាវនាវ ដោះស្រាយបញ្ហាតាមព្រំដែនប្រកបដោយសន្តិភាព។ ចំណែកខាងក្នុងកងទ័ពវៀតណាមបានត្រៀមខ្លួនក្នុងការវាយទៅលើប្រទេសកម្ពុជារួចជាស្រេច។

នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧៨ ដោយមានការទទួលបញ្ជាពីឈ្មោះ ថាច់ វ៉ាន់ថុង និង ឈ្មោះ ដិន ទ្រឿង ដែលមានតួនាទីជាអនុសេនីយ៍ឯក (ស័ក្តិ៣)។ ដិន ទ្រឿង គឺជាប្រធានមន្ទីរបាន ចាត់តាំងខ្ញុំឲ្យនាំផ្លូវ និងធ្វើការពិនិត្យទៅលើភូមិសាស្ត្រ ព្រោះខ្ញុំមានបងប្អូនរស់នៅភ្នំដិននិងស្គាល់ភូមិសាស្ត្រប្រទេសកម្ពុជាផង។

នៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៨ ខ្ញុំ បានចូលមកក្នុងទឹកដីប្រទេសកម្ពុជា នៅសល់តែកន្លះគីឡូ ម៉ែត្រប៉ុណ្ណោះដល់ភ្នំដិន ពេលនោះ ខ្ញុំក៏ត្រូវយោធាខ្មែរក្រហមព័ទ្ធចាប់តែម្តង។

*កំណត់ចំណាំ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់ដែលជាប់ឃុំឃាំងនៅមន្ទីរ សន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយ របស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានឡើយថា ចម្លើយរបស់អ្នកទោស វិញ ស៊ាង នេះពិតឬយ៉ាងណានោះទេ។*

**ដារ៉ារដ្ឋ មេត្តា**



អតីតមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង (រូបថត ៖ សារមន្ទីរទួលស្លែង)

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង សុង ថាណៃ តាមរយៈទូរសព្ទលេខ៖ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល៖ truththanay.s@dccam.org។












# រឿងរ៉ាវរបស់ប្រជាជនចេញពីសហគមន៍អន្លង់វែង

អន្លង់វែង មានទីតាំងជាប់នឹងព្រំដែនប្រទេសថៃ ខណ្ឌចែកទឹកដីដោយជួរភ្នំដងរែក។ ដោយសារពីមុនតំបន់អន្លង់វែង សម្បូរទៅដោយព្រៃឈើក្រាស់ៗ និងហ៊ុំព័ទ្ធដោយភ្នំ ទើបអតីតមេដឹកនាំខ្មែរក្រហម បានជ្រើសរើសតំបន់នេះ ធ្វើជាមូលដ្ឋានតស៊ូប្រឆាំងនឹងរាជរដ្ឋាភិបាលរហូតដល់ តាម៉ុក មេដឹកនាំយោធាខ្មែរក្រហមដែលធ្លាប់បានប្រព្រឹត្តអំពើឃោរឃៅមកលើប្រជាជនស្លូតត្រង់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាប់ខ្លួននៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩។

ក្រោយពីសមរភូមិប្រយុទ្ធ អន្លង់វែងគឺជាកន្លែងដែលធ្លាប់កើតឡើងនូវអំពើហិង្សា ការកាប់សម្លាប់ និងបានក្លាយជាទីតាំងប្រវត្តិសាស្ត្រដ៏រន្ធត់ នៅពេលដែលរចនាសម្ព័ន្ធរបស់ខ្មែរក្រហមក្នុងតំបន់នេះបានដួលរលំទាំងស្រុង។ អន្លង់វែងបានបង្កប់នូវអត្ថន័យ និងរឿងរ៉ាវជាច្រើនដែលយើងមិនបានដឹង។

សព្វថ្ងៃប្រជាជនដែលរស់នៅក្នុងតំបន់អន្លង់វែងភាគច្រើនគឺជាអតីតកម្មាភិបាល យោធា និងគ្រួសារខ្មែរក្រហមដែលបានរត់កៀសខ្លួនមកពីបណ្តាខេត្តនានានៅទូទាំងប្រទេសកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ រួមទាំងប្រជាជនចំណូលថ្មីដែលបានចូលមករស់នៅក្នុងតំបន់នេះ បន្ទាប់ពីយោធារបស់ខ្មែរក្រហមដែលនៅសេសសល់ បានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ១៩៩៩។ ដោយសារតំបន់អន្លង់វែង មានប្រជាជនរស់នៅចម្រុះ ទាំងជនរងគ្រោះ និងជនដៃដល់ ដូច្នេះហើយទើប



ក្រុមនិស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងកំពុងសម្ភាសន៍ប្រជាជននៅក្នុងសហគមន៍អន្លង់វែង ខេត្តឧត្តរមានជ័យ អំពីបទពិសោធន៍ក្នុងសម័យខ្មែរក្រហម (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាជនទាំងនេះបានរៀបរាប់ពីបទពិសោធន៍ រឿងរ៉ាវ និង បានបញ្ចេញនូវទស្សនៈខុសៗគ្នាដូចខាងក្រោម ៖

**១) នូវ សុខន**



នូវ សុខន (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មុនរបប លន់ នល់ ខ្ញុំរស់នៅក្នុងគ្រួសារកសិករមួយ ដែលមានជីវភាពក្រលំបាកនៅក្នុងភូមិលាយបូ ឃុំលាយបូ ស្រុកត្រាំកក់ ខេត្តតាកែវ។ ខ្ញុំជាកូនទី៣ ក្នុងចំណោមបងប្អូន ៦នាក់។ ដើម្បីគេចចេញពីការទម្លាក់គ្រាប់បែក និងការវាយប្រយុទ្ធគ្នា គ្រួសាររបស់ខ្ញុំបានសម្រេចចិត្តទៅរស់នៅភូមិផ្សេងៗ ប៉ុន្តែនៅពេលធ្វើដំណើរដល់ភ្នំមួយ ខ្ញុំនិងក្រុមគ្រួសារបានជួបនឹងខ្មែរក្រហម ដែលកំពុងកៀរប្រជាជនឲ្យទៅរស់នៅក្នុងព្រៃជ្រៅ។ ឃើញដូច្នេះ ខ្ញុំ និងក្រុមគ្រួសារបានភៀសខ្លួនចេញពីតំបន់នោះវិញ។ នៅឆ្នាំ១៩៧៣ ខ្ញុំ និងក្រុមគ្រួសារបានទៅរស់នៅភូមិជ្រៃ ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង។

លុះដល់ឆ្នាំ១៩៧៤ ដោយសារតែមានការបាញ់គំរាម និងដុតផ្ទះប្រជាជនពីសំណាក់យោធាខ្មែរក្រហមដើម្បីប្លន់យកទ្រព្យសម្បត្តិ អង្ករ មាន់ ទា ខ្ញុំ និងក្រុមគ្រួសារបានរត់គេចចេញពីផ្ទះទៅដេកតាមអូរឆ្ងាយៗពីភូមិជារៀងរាល់យប់ៗ ដោយសារមិនមានសុវត្ថិភាពនៅពេលនោះ នៅចុងឆ្នាំ១៩៧៤ ខ្ញុំ និងគ្រួសារ បានផ្លាស់ទៅរស់នៅក្នុងក្រុងបាត់ដំបង ដោយសុំជម្រកស្រូវរបស់ប្រជាជននៅទីនោះស្នាក់នៅបណ្តោះអាសន្ន។

ខ្ញុំមានអាយុប្រហែល៩ឆ្នាំ នៅពេលយោធាខ្មែរក្រហមទទួលជ័យជម្នះ។ ពេលនោះ ខ្មែរក្រហមបានប្រកាសប្រាប់ប្រជាជនក្នុងក្រុងបាត់ដំបងទាំងអស់ឲ្យឈរតាមដងផ្លូវ រួចហើយស្រែកថា«ជយោ! សម្តេចឪឈ្នះហើយៗ»។ បន្ទាប់មកយោធាខ្មែរក្រហមក៏បានដឹកអតីតទាហាន លន់ នល់ តាមរថយន្តចេញទៅតាមជាយដែន។ ក្រោយមកទើបខ្ញុំដឹងថាអតីតទាហាន លន់ នល់ ទាំងនោះត្រូវបានខ្មែរក្រហមសម្លាប់។ បន្ទាប់ពីព្រឹត្តិការណ៍នោះ ខ្ញុំនិងគ្រួសារត្រូវបានយោធាខ្មែរក្រហមជម្លៀសចេញពីទីក្រុងបាត់ដំបងឲ្យទៅនៅភូមិជ្រៃ ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបងវិញ ដោយយើងត្រូវធ្វើដំណើរដោយថ្មើរជើងរយៈពេលពីរថ្ងៃ។ នៅពេលទៅដល់ភូមិ ខ្ញុំមិនទាន់ទទួលបានការចាត់តាំងឲ្យការងារអ្វីឡើយ ក្រៅពីនៅផ្ទះមើលប្អូនៗ។ រីឯឪពុកម្តាយរបស់ខ្ញុំ និងប្រជាជនដទៃទៀតនៅក្នុងភូមិជ្រៃ ត្រូវបានខ្មែរក្រហមបែងចែកឲ្យទៅធ្វើការងាររួម ប៉ុន្តែអាចវិលមកហូបបាយនៅតាមផ្ទះរៀងៗខ្លួន។ ទោះជាយ៉ាងនេះក្តី ក៏ការបរិភោគរបស់ប្រជាជនមិនបានគ្រប់គ្រាន់ដែរ។ ក្នុងឆ្នាំដដែល ប្អូនរបស់ខ្ញុំម្នាក់បានស្លាប់ដោយសារជំងឺ និងខ្វះថ្នាំសង្កូវសម្រាប់ព្យាបាល។

រហូតដល់ឆ្នាំ១៩៧៦ ទើបខ្មែរក្រហមបានប្រមូលប្រជាជននៅក្នុងភូមិជ្រៃឲ្យហូបរួម ដោយពេលថ្ងៃហូបបបរ និងពេលល្ងាចហូបបាយ។ នៅក្នុងភូមិរបស់ខ្ញុំមានរឿងស្នេហាគួរឲ្យរន្ធត់ និងខ្លោចផ្សាបានកើតឡើង គឺស្ត្រីមេម៉ាយម្នាក់ឈ្មោះជា ដែលប្តីរបស់គាត់ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោល បានស្រឡាញ់គ្នាជាមួយបុរសឈ្មោះ ជុំ។ អ្នកទាំងពីរធ្វើការក្នុងកងផ្សេងពីគ្នា ប៉ុន្តែថ្ងៃមួយអ្នកទាំងពីរបានលួចជួបគ្នាហើយចាប់ចិត្តស្រឡាញ់គ្នា។ ជា និង ជុំ តែងតែលួចទៅរួមរស់ជាមួយគ្នានៅពេលយប់។ ថ្ងៃមួយឈ្លបខ្មែរក្រហមបានដឹង

រឿងនេះ និងបានចោទអ្នកទាំងពីរថាបានប្រព្រឹត្តខុសសីលធម៌។ លុះដល់ពេលព្រឹកឡើង កម្មាភិបាលខ្មែរក្រហមបានកោះហៅប្រជាជននៅក្នុងឃុំទៅប្រជុំ រួចហើយក៏បាននាំយក ជា និង ជុំ មកលើវេទិកា។ ខណៈនោះ កម្មាភិបាលខ្មែរក្រហមក៏បង្គាប់ឲ្យអ្នកចូលរួមប្រជុំឡើងប្តេជ្ញាកុំយកគំរូតាមគូស្នេហ៍ទាំងពីរ។ បន្ទាប់ពីប្រជុំចប់ ឈ្លបខ្មែរក្រហមក៏បណ្តើរ ជា និង ជុំ ចេញទៅ។ ពេលបណ្តើរទៅដល់មាត់រណ្តៅនៅចុងភូមិ ឈ្លបខ្មែរក្រហមបានសម្រាតខោអាវអ្នកទាំងពីរចេញ រួចហើយក៏វាយសម្លាប់ ជា។ បន្ទាប់មក ឈ្លបខ្មែរក្រហមបានវះយកថ្លើម និងប្រមាត់របស់ ជា រួចហើយដាក់សពរបស់ ជា ផ្ងារក្នុងរណ្តៅ។ ចំណែក ជុំ ត្រូវបានឈ្លបខ្មែរក្រហមវាយឲ្យសន្លប់ បន្ទាប់មកដាក់ឲ្យដេកផ្កាប់ពីលើសាកសពរបស់ ជា រួចហើយកប់ទាំងរស់តែម្តង។

នៅក្នុងឆ្នាំ១៩៧៧ ខ្ញុំមានអាយុប្រហែល១១ឆ្នាំ ពេលនោះខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យចូលធ្វើការងារក្នុងកងកុមារ ដូចជា ដេញចាប និងបោចស្មៅនៅតាមវាលស្រែ។ រីឯរបបអាហាររបស់ខ្ញុំ គឺពេលថ្ងៃត្រង់ហូបបបរ និងពេលល្ងាចហូបបាយ។ ពេលនោះ ប្រសិនបើកុមារណាខ្ជិល ឬលួចរត់ទៅផ្ទះ មេកងនឹងចាប់កុមារទាំងនោះយកមកកងវិញ។ មេកងបានចងកុមារទាំងនោះផ្អោបទៅនឹងសសរ រួចយកអង្ក្រងមកឲ្យខាំ ថែមទាំងបង្អត់អាហារកុមារទាំងនោះទៀតផង។

ក្នុងអំឡុងឆ្នាំ១៩៧៨ ដល់ឆ្នាំ១៩៧៩ ខ្មែរក្រហមបានចាត់តាំងឲ្យខ្ញុំទៅនៅគាកោរទ្រេត ឆ្ងាយពីភូមិដែលគ្រួសាររបស់ខ្ញុំរស់នៅ។ រយៈពេលមួយខែ ទើបខ្មែរក្រហមអនុញ្ញាតឲ្យខ្ញុំត្រឡប់មកជួបគ្រួសារម្តង។ នៅទីនោះ ខ្ញុំត្រូវបានប្រធានកងចាត់តាំងឲ្យដើររើសខស កាប់ដី និងលើកទំនប់តូចៗ ប៉ុន្តែខ្មែរក្រហមមិនបានបង្ខិតបង្ខំខ្ញុំ និងប្រជាជននៅក្នុងតំបន់នេះឲ្យធ្វើការហួសកម្លាំងឡើយ។

ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩គ្រួសាររបស់ខ្ញុំបានមកជួបជុំគ្នាវិញ និងបានទៅរស់នៅក្នុងស្រុកថ្មគោល ខេត្តបាត់ដំបង។ ទោះបីរបបខ្មែរក្រហមដួលរលំទៅហើយក៏ដោយ ក៏សង្គ្រាមរវាងខ្មែរក្រហម និងកងទ័ពវៀតណាមនៅតែបន្តក្នុងភូមិឃុំដែល ខ្ញុំរស់នៅរហូតដល់ឆ្នាំ១៩៩៥។ ក្រោយមក ខ្ញុំក៏បានផ្លាស់មករស់នៅក្នុងភូមិគោកសំព័រ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ រហូតមកដល់សព្វថ្ងៃ។

### ៧) មឹង លាត

ខ្ញុំមានអាយុ៥៨ឆ្នាំ មានស្រុកកំណើតនៅឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប។ នៅមុនរបបខ្មែរក្រហម ខ្ញុំបានរស់នៅជួបជុំជាមួយក្រុមគ្រួសារ។ ឪពុកម្តាយរបស់ខ្ញុំប្រកបរបរជាកសិករ ចំណែកខ្ញុំបានជួយមើលថែប្អូនតូចៗ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលខ្ញុំមានអាយុ១៣ឆ្នាំ ខ្មែរក្រហមបានបំបែកខ្ញុំចេញពីក្រុមគ្រួសារ។ ប៉ុន្តែខ្មែរក្រហមមិនបានជម្លៀសខ្ញុំទៅតំបន់ឆ្ងាយឡើយ ដោយសារតែខ្ញុំមានប្រវត្តិរូបជាកូនកសិករ។ ផ្ទុយទៅវិញ ខ្មែរក្រហមបានជម្លៀសប្រជាជនដែលមានប្រវត្តិជាគ្រូបង្រៀន ឬគ្រូពេទ្យទៅតំបន់ឆ្ងាយៗ។

ដោយសារខ្ញុំនៅជាកុមារនាសម័យនោះ ខ្មែរក្រហមបានបញ្ជាខ្ញុំឲ្យទៅកាប់ទន្ទ្រានខែត្រយកមកចិញ្ច្រាំធ្វើជី វែកដីលើកទំនប់ ដាំដំឡូង និងជញ្ជូនកណ្តាប់។ ចំពោះការរៀនសូត្រ ខ្ញុំនិងក្មេងៗដទៃទៀតនៅក្នុងភូមិត្រូវបានខ្មែរក្រហមអនុញ្ញាតឲ្យរៀនអក្សរបន្តិចបន្តួច ជាមួយគ្រូបង្រៀននៅក្រោមម្លប់ដើមឫស្សី។

នៅពេលនោះ ខ្ញុំបានឃើញខ្មែរក្រហមចាប់មនុស្សយកទៅសម្លាប់ និងយកទៅមន្ទីរសន្តិសុខដែលភាគច្រើនអ្នកទាំងនោះជាគ្រូបង្រៀនកាលពីសង្គមចាស់ គ្រូពេទ្យ និងបញ្ញវន្តជាដើម។ ដោយសារខ្ញុំមានអាយុតិចនិងនៅវ័យក្មេងនៅឡើយ ដូច្នេះ ខ្ញុំមិនសូវភ័យខ្លាចទេនៅពេលឃើញហេតុការណ៍នៃការសម្លាប់ប្រជាជនទាំងនោះ ទោះបីជាឪពុកម្តាយរបស់ខ្ញុំបានហាមឃាត់ខ្ញុំមិនឲ្យទៅមើលក៏ដោយ។ ចំពោះអាហារប្រចាំថ្ងៃ ខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនដាំបាយ និង

ហូបជុំគ្រួសារនៅផ្ទះឡើយ។ ប្រជាជនទាំងអស់ត្រូវតែហូបជុំគ្នានៅរោងបាយរួម។ អាហារនៅពេលនោះមានបាយ បបរលាយជាមួយដំឡូងមី និងបន្លែផ្សេងៗ។ នៅពេលសហករណ៍ខ្វះខាតអង្ករម្តងៗ ប្រជាជនត្រូវហូបបបររាវរយៈពេលកន្លះខែទៅមួយខែ។ នៅក្នុងសម័យនោះ ប្រជាជនមិនមានសិទ្ធិជ្រើសរើសប្តីប្រពន្ធដោយខ្លួនឯងបានឡើយ គឺខ្មែរក្រហមជាអ្នករៀបការឲ្យអ្នកទាំងនោះ ដោយក្នុងពិធីរៀបការម្តងៗ មានប្តីប្រពន្ធចាប់ពី១០គូ ទៅ៥០គូ។

នៅពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលគាំទ្រដោយកងទ័ពវៀតណាម វាយផ្តួលរំលំរបបខ្មែរក្រហម ខ្ញុំមានអារម្មណ៍ភិតភ័យយ៉ាងខ្លាំង ព្រោះខ្ញុំធ្លាប់ឮពាក្យចចាមអារ៉ាមថា «កំពប់តែអុង» ដែលមានន័យថាវៀតណាម នឹងយកក្បាលខ្មែរធ្វើជាមុំចង្ក្រានដាំទឹកតែ។ ពេលនោះកងទ័ពវៀតណាមបានបង្គាប់ឲ្យខ្ញុំនិងប្រជាជនដទៃទៀតទៅដេកនៅវាលស្រែ បន្ទាប់មកបានចែកថ្នាំពេទ្យ ឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃឲ្យខ្ញុំ និងប្រជាជននៅទីនោះទៀតផង។

ខ្ញុំសប្បាយរីករាយយ៉ាងខ្លាំងព្រោះបានជួបជុំឪពុកម្តាយ និងមករស់នៅផ្ទះរបស់ខ្លួនវិញ។ បន្ទាប់មករដ្ឋអំណាចថ្មីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏បានចែកដីស្រែ និងពូជស្រូវឲ្យគ្រួសារខ្ញុំ និងប្រជាជនដាំដុះដើម្បីចិញ្ចឹមគ្រួសារ។

ទោះបីរបបខ្មែរក្រហមដួលរលំទៅហើយក៏ដោយក៏សង្គ្រាមនៅតែបន្ត ហើយខ្ញុំ និងក្រុមគ្រួសារតែងតែរត់គេចពីការវាយប្រហាររវាងយោធាខ្មែរក្រហម និងកងទ័ពរបបសាធារណរដ្ឋខ្មែរ ដែលគាំទ្រដោយវៀតណាម។

នៅពេលដែលសង្គ្រាមនៅក្នុងភូមិខ្ញុំបានចប់ជាស្ថាពរ នៅឆ្នាំ១៩៩៧ ខ្ញុំនិងក្រុមគ្រួសារបានវិលត្រឡប់មករស់នៅស្រុកកំណើតនៅស្រុកជីក្រែងវិញ។ ក្រោយមក ខ្ញុំក៏បានផ្លាស់មករស់នៅក្នុងភូមិគោកសំព័រ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលគិតមកដល់បច្ចុប្បន្នមានរយៈពេល ១៨ឆ្នាំមកហើយ។

ទោះបីរបបខ្មែរក្រហមបានផុតរលត់ទៅជាង ៣៩ឆ្នាំមកហើយក៏ដោយ ក៏ខ្ញុំនៅតែចងចាំ និងនឹកឃើញអំពីហេតុការណ៍នៃការសម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃ ហើយអដ្ឋិធាតុរបស់ជនរងគ្រោះទាំងនោះត្រូវបានតម្កល់នៅវត្តមួយក្នុងឃុំកំពង់ក្តីរហូតមកដល់សព្វថ្ងៃ។ ខ្ញុំមិនចង់ឲ្យរបបបែបនេះកើតឡើងនៅក្នុងប្រទេសកម្ពុជាទៀតទេ ប៉ុន្តែខ្ញុំចង់ឲ្យមានការចងចាំពីរបបនេះដើម្បីជាការផ្សះផ្សា និងចង់ឲ្យមានសន្តិភាពសម្រាប់ប្រទេសជាតិទាំងមូល។

៣) ឌី កិញ



ឌី កិញ (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពេលខ្ញុំអាយុ១៦ឆ្នាំ ប្រទេសជាតិកំពុងធ្លាក់ចូលក្នុងសង្គ្រាម ដោយការដណ្តើមអំណាចគ្នារវាងសេនាប្រមុខ លន់ នល់និងកងកម្លាំងរំដោះខ្មែរក្រហម។ ក្រោយពេលខ្មែរក្រហមឡើងគ្រប់គ្រងប្រទេស ខ្ញុំនិងក្មេងៗដទៃទៀតនៅក្នុងស្រុកភ្នំស្រុក ខេត្តបាត់ដំបង ត្រូវបានបញ្ចូលទៅក្នុងកងកុមារដែលមានភារកិច្ចឃ្វាលគោក្របីស្វែងរកវត្ថុជាតិរើសលាមកសត្វមកធ្វើជី និងជញ្ជូនជីដាក់ស្រែ។ ចំណែកឯយុវជនដែលមានកម្លាំងពេញ ត្រូវបានខ្មែរក្រហមបញ្ចូលទៅក្នុងកងចល័តដែលត្រូវធ្វើការងារភ្ជួររាស់ជីកស្រះជីកប្រឡាយ លើកភ្លឺស្រែលើកទំនប់ ស្ទូងស្រូវ និងដាំដំណាំ។ ជាធម្មតា កងចល័តទាំង

អស់ត្រូវទៅធ្វើការផាវឆ្ងាយពីផ្ទះសម្បែងរបស់ខ្លួន ដោយហូបចុក និងស្នាក់នៅរួមគ្នា។ នៅក្នុងសម័យនោះប្រជាជនត្រូវបានបង្ខំឲ្យធ្វើការហួសកម្លាំង និង លើសពី១០ម៉ោងក្នុងមួយថ្ងៃ ដោយមិនមានពេលវេលាឈប់សម្រាកឡើយ។ នៅក្នុងពេលធ្វើការ ប្រជាជនមិនអាចអែអង់ ឬខ្ជិលច្រអូសបានឡើយ ព្រោះគ្រប់កងចល័តទាំងអស់ គឺមានឈ្លបខ្មែរក្រហមជាអ្នកចាំត្រួតពិនិត្យ និងឃ្លាំមើលជាប្រចាំ។ ប្រសិនបើឈ្លបខ្មែរក្រហមចាប់បានសមាជិកកងចល័តណាម្នាក់ខ្ជិលច្រអូស ឈ្លបខ្មែរក្រហមនឹងវាយធ្វើបាបសមាជិកកងចល័តនោះនៅនឹងកន្លែងតែម្តង ហើយពេលខ្លះវាយរហូតដល់ស្លាប់ក៏មាន។

ក្នុងសម័យខ្មែរក្រហមការហូបចុកមានភាពខ្វះខាតយ៉ាងខ្លាំង។ របបអាហារមិនសក្តិសមនឹងកម្លាំងពលកម្មដែលប្រជាជនបានធ្វើដើម្បីអង្គការឡើយ។ នៅក្នុងសម័យនោះខ្មែរក្រហមតម្រូវឲ្យប្រជាជនទាំងអស់បរិភោគអាហាររួមគ្នានៅតាមរោងបាយក្នុងសហករណ៍។ ប្រជាជនទាំងអស់ទទួលបានអាហារពីរពេលក្នុងមួយថ្ងៃ គឺពេលថ្ងៃត្រង់ និងពេលល្ងាច។ នៅក្នុងតំបន់៥(ស្រុកភ្នំស្រុក) ដែលខ្ញុំរស់នៅ ខ្មែរក្រហមបានផ្តល់អង្ករតែមួយកំប៉ុងប៉ុណ្ណោះសម្រាប់មនុស្សពី៣០ទៅ ៤០នាក់ ដើម្បីយកទៅបបរលាយជាមួយគល់ល្ហុង គល់ចេកហូប ដែលមិនខុសពីចំណីសម្រាប់សត្វជ្រូកនៅពេល



ក្រុមនិស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងសម្ភាសន៍ប្រជាជននៅក្នុងសហគមន៍អន្លង់វែង ខេត្តឧត្តរមានជ័យ អំពីបទពិសោធន៍ក្នុងសម័យខ្មែរក្រហម (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បច្ចុប្បន្នឡើយ។ ទោះបីយ៉ាងណារបបអាហារមិនទៀងទាត់ទេនៅក្នុងរបបខ្មែរក្រហម ពេលខ្លះប្រជាជនអាចទទួលបានអាហារហូបគ្រប់គ្រាន់ និងពេលខ្លះទៀតក៏មានភាពខ្វះខាតដែរ។ ប្រជាជនដែលមានដើមកំណើតនៅស្រុកស្រែចម្ការអាចទ្រាំទ្រទុក្ខលំបាកទាំងនេះបាន ដោយសារតែធ្លាប់ឆ្លងកាត់ការហាត់នឿយពីមុនមក ប៉ុន្តែខ្ញុំអាណិតប្រជាជនថ្មីដែលខ្មែរក្រហមបានជម្លៀសឲ្យទៅរស់នៅក្នុងព្រៃឆ្ងាយពីភូមិ ដែលមិនមានអាហារហូបនិងមិនមានផ្ទះស្នាក់នៅ។ប្រជាជនថ្មីទាំងនោះបានទទួលរងការធ្វើបាប និងកៀបសង្កត់គ្រប់បែបយ៉ាងពីខ្មែរក្រហម។ ប្រជាជនថ្មីខ្លះបានយកទ្រព្យសម្បត្តិដែលសេសសល់បន្តិចបន្តួចទៅដូរយកអាហារពីប្រជាជនចាស់ក្នុងតំបន់នោះ ដោយមាសមួយជីដូរបានអង្ករតែពីរទៅបីកំប៉ុងតែប៉ុណ្ណោះ។ ដោយសារតែការអត់ឃ្លាន ប្រជាជនខ្លះបានលួចអង្ករពីសហករណ៍ ខ្លះទៀតបានដើរបូតកួរស្រូវនៅតាមវាលស្រែយកមកបុកហូប។ ខ្ញុំក៏ធ្លាប់បានលួចបូតស្រូវមកបរិភោគដែរ ប៉ុន្តែត្រូវឈ្លបខ្មែរក្រហមតាមទាន់។ ខ្ញុំបានបោះកួរស្រូវទាំងអស់នោះចោល រួចនិយាយកុហកឈ្លបខ្មែរក្រហមថា ខ្ញុំមកស្ទូចត្រីយកទៅឲ្យសហករណ៍ធ្វើម្ហូប ទើបឈ្លបខ្មែរក្រហមនោះមិនបានធ្វើទារុណកម្មខ្ញុំ។ ដោយសារតែការហូបចុកមិនគ្រប់គ្រាន់និងការបង្ខំឲ្យធ្វើការហួសកម្លាំង ទើបបណ្តាលឲ្យប្រជាជនថ្មីជាច្រើនបានធ្លាក់ខ្លួនឈឺ និងមួយចំនួនទៀតបានស្លាប់។ បើទោះបីជាបានហូបគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់យ៉ាងណាក៏ដោយ ក៏ប្រជាជនទាំងនោះមិនមានសិទ្ធិតវ៉ាដែរ ប៉ុន្តែប្រសិនបើនៅតែហ៊ានតវ៉ា នឹងត្រូវបានខ្មែរក្រហមចោទថាក្បត់ ដែលអាចទទួលរងទោសទណ្ឌ ដូចជាការបង្អត់អាហារ ការវាយដំ និងការយកទៅកសាង (សម្លាប់ចោល) មិនខាន។ ដូច្នេះ ប្រជាជនទាំងនោះត្រូវធ្វើគរ ធ្វើថ្លង់ ហើយសូម្បីតែបងប្អូនរាប់អានគ្នាជិតស្និទ្ធយ៉ាងណាក៏ដោយក៏មិនហ៊ាននិយាយរឿងរ៉ាវលំបាកប្រាប់គ្នាដែរ។

នៅសម័យនោះ មន្ទីរពេទ្យ គ្រឹះស្ថានសិក្សា វត្តអារាមទាំងអស់ ត្រូវបានខ្មែរក្រហមយកធ្វើជាឃ្លាំង និងជាកន្លែងសម្រាប់ដាក់អ្នកទោស។ប្រជាជនដែលមានជំងឺមិនបានទទួលសេវាព្យាបាលឲ្យបានត្រឹមត្រូវឡើយ ដោយសារមិនមានថ្នាំពេទ្យឲ្យអ្នកជំងឺលេប និងមិនមានក្រុមគ្រូពេទ្យជំនាញ។ ខ្មែរក្រហមបានផលិតថ្នាំម្យ៉ាងឈ្មោះថា ថ្នាំអាចម៍ទន្សាយសម្រាប់ឲ្យអ្នកជំងឺលេប។ ទោះបីអ្នកជំងឺនោះឈឺអ្វីក៏ដោយក៏ខ្មែរក្រហមប្រើថ្នាំប្រភេទនេះដើម្បីព្យាបាលដែរ។ ដូច្នេះប្រជាជនដែលធ្លាក់ខ្លួនឈឺភាគច្រើនបានបាត់បង់ជីវិត។ ខ្មែរក្រហមបានលុបបំបាត់ចោលទាំងស្រុង និងបានហាមឃាត់រាល់ការប្រណិប័តន៍សាសនា។ ចំណែកព្រះសង្ឃត្រូវបានខ្មែរក្រហមបង្ខំឲ្យសឹក រួចហើយបញ្ជូនឲ្យទៅធ្វើស្រែចម្ការដូចជាប្រជាជនទូទៅដែរ។ ចំពោះការរៀបការ ខ្មែរក្រហមបានរៀបចំពិធីជួបជុំមួយដែលប្រជាជនទូទៅហៅថា «ការចាប់អារម្មណ៍»។ពេលរៀបចំធ្វើពិធីនេះម្តងៗមានកូនកំលោះនិងកូនក្រមុំជាច្រើនគូបានចូលរួមគឺ៖១) សម្រាប់ពិធីតូចមានកូនកំលោះ និងកូនក្រមុំ ចាប់ពី២០ ទៅ ៣០គូ និង ២) សម្រាប់ពិធីរៀបការធំ មានកូនកំលោះ និងកូនក្រមុំ ចាប់ពី៥០ ទៅ១០០គូ។ កូនក្រមុំ និង កូនកំលោះ ភាគច្រើនត្រូវបានខ្មែរក្រហមចាប់បង្ខំឲ្យរៀបការ ដោយអ្នកខ្លះមិនដែលបានជួបមុខគ្នាទេ។ ប៉ុន្តែនៅពេលនោះ បុរសនារីស្រឡាញ់គ្នាទៅវិញទៅមក ក៏អាចស្នើសុំទៅប្រធានសហករណ៍ដើម្បីរៀបការបានដែរ។ប៉ុន្តែប្រសិនបើមានកម្មាភិបាលខ្មែរក្រហមនិងយោធាខ្មែរក្រហមណាម្នាក់ជំទាស់ បុរស និងនារីនោះក៏មិនអាចរៀបការបានដែរ ហើយនារីនោះត្រូវមករៀបការជាមួយកម្មាភិបាល ឬយោធាខ្មែរក្រហមវិញ បើទោះបីជានារីនោះមិនពេញចិត្តក៏ដោយ។ នៅក្នុងពិធីរៀបការកូនកំលោះនិងកូនក្រមុំ ត្រូវតែសន្យាយកគ្នាជាប្តីប្រពន្ធចំពោះមុខគណអធិបតី រួចវិលត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ។ ក្រោយពីរៀបការ គូស្វាមីភរិយាថ្មីអាចរស់នៅជាមួយគ្នារយៈពេល២ ទៅ៣ថ្ងៃតាមការយោគយល់របស់ប្រធានកង។ ក្នុងកំឡុងពេលរស់នៅជាមួយគ្នា គូស្វាមីភរិយាថ្មីបានស្ថិតនៅក្រោមការតាមដានរបស់កងឈ្លបភូមិជាប្រចាំ។ កងឈ្លបខ្មែរក្រហម

ភាគច្រើនមានវ័យក្មេងដែលមានអាយុចាប់ពី១៥ទៅ១៦ឆ្នាំ ជាកូនរបស់ប្រជាជនមូលដ្ឋាន និងជាក្មេងកំព្រាដែលឪពុកម្តាយស្លាប់ចោល។ ប្រសិនបើស្វាមីភរិយាថ្មីនោះរស់នៅមិនចុះសម្រុងគ្នា ឬមិនព្រមរួមរស់ជាមួយគ្នា កងឈ្លបនឹងរាយការណ៍ទៅថ្នាក់លើដើម្បីដាក់ទោសដល់អ្នកទាំងពីរ។ ក្នុងតំបន់របស់ខ្ញុំរស់នៅ មានស្វាមីភរិយាខ្លះត្រូវបានខ្មែរក្រហមយកទៅសម្លាប់ដោយសារអ្នកទាំងពីរមិនស្រឡាញ់គ្នា ចំណែកអ្នកខ្លះទៀតបានទ្រាំរួមរស់ជាមួយគ្នាទាំងបង្ខំចិត្តរហូតដល់របបខ្មែរក្រហមដួលរលំ ដោយសារតែខ្លាចឈ្លបសម្លាប់។

នៅក្នុងរបបខ្មែរក្រហម ប្រជាជនទូទាំងប្រទេសរងទុក្ខវេទនាយ៉ាងខ្លាំង សិទ្ធិសេរីភាពគ្រប់បែបយ៉ាងរបស់ប្រជាជនត្រូវបានដកហូត។ ប្រជាជនគ្មានសិទ្ធិក្នុងការប្រាស្រ័យទាក់ទងគ្នា គ្មានសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ឬស្នើសុំអ្វីឡើយ។ នៅក្នុងស្រុកភូមិរបស់ខ្ញុំ សូម្បីតែឪពុកម្តាយ បងប្អូនសាច់ញាតិគ្នាក៏មិនហ៊ានប្រាស្រ័យទាក់ទងគ្នាដែរ ព្រោះខ្លាចខ្មែរក្រហមចោទថាក្បត់។

រឿងរ៉ាវដែលធ្វើឲ្យប្រជាជនចងចាំមិនភ្លេចនោះ គឺខ្មែរក្រហមបានកាប់សម្លាប់ប្រជាជនដោយមិនញញើតឡើយ។ ជាក់ស្តែងប្រជាជន ១៧ មេសា ក្នុងស្រុកភ្នំស្រុក ទទួលរងការកាប់សម្លាប់ និងការជិះជាន់ខ្លាំងជាងប្រជាជនមូលដ្ឋាន។ ចំពោះប្រជាជនថ្មីដែលជម្លៀសមកពីទីក្រុង ត្រូវបានឈ្លបខ្មែរក្រហមយកទៅឃុំឃាំងនៅក្នុងសាលារៀនមួយក្នុងស្រុកភ្នំស្រុក បន្ទាប់មកឈ្លបខ្មែរក្រហមបានសម្លាប់អ្នកទាំងនោះរួចទម្លាក់ចូលទៅក្នុងអណ្តូងទឹកនៅក្នុងសាលារៀននោះ។ ចំណែកប្រជាជនមួយចំនួនទៀតត្រូវបានខ្មែរក្រហមបញ្ជូនចូលទៅក្នុងព្រៃដោយបង្អត់អាហារ និងធ្វើទារុណកម្មរហូតបាត់បង់ជីវិត។ ប្រជាជនដែលមានកំហុសបន្តិចបន្តួច ដូចជា លួចបេះបន្លែ ផ្លែឈើរបស់អង្គការ និយាយប៉ះពាល់អង្គការ ឬប្រឆាំងនឹងបញ្ជាថ្នាក់លើ ក៏ត្រូវបានឈ្លបខ្មែរក្រហមយកទៅសម្លាប់ចោលដែរ។ នៅពេលខ្លះប្រជាជនដែលស្ថិតនៅក្នុងការសង្ស័យពីថ្នាក់លើ ក៏ឈ្លបខ្មែរក្រហមយកទៅសម្លាប់ដោយគ្មានការសួរនាំដែរ។ ចាប់តាំងពីពេលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញភ្លាមៗ ខ្មែរក្រហមបានសម្លាប់ទាហានមន្ត្រីរាជការ គ្រូពេទ្យ គ្រូបង្រៀន បញ្ញវន្ត ក្នុងរបបចាស់អស់ជាច្រើន។ នៅក្នុងភូមិរបស់ខ្ញុំ មានស្ត្រីចំណាស់ម្នាក់បានជម្លៀសមកពីខេត្តសៀមរាប មានប្តីធ្លាប់ធ្វើជាទាហានក្នុងរបប លន់ នល់ ត្រូវបានឈ្លបខ្មែរក្រហមយកទៅសម្លាប់ចោលក្រោយពីស៊ើបដឹងប្រវត្តិរូប។ បន្ទាប់ពីឈ្លបខ្មែរក្រហមសម្លាប់ប្តីស្ត្រីម្នាក់នោះរួចមក ឈ្លបខ្មែរក្រហមបានប្រាប់ស្ត្រីនោះថា ប្រសិនបើស្ត្រីនោះមានបងប្អូនសាច់ញាតិខ្លួននៅរស់នឹងអនុញ្ញាតឲ្យស្ត្រីនោះទៅរស់នៅជុំគ្នាវិញ។ តមក ឈ្លបខ្មែរក្រហមក៏យកក្រុមគ្រួសារ និងសាច់ញាតិរបស់ស្ត្រីនោះទៅសម្លាប់បន្ថែមទៀតនៅភ្នំទ្រង់បាត ក្នុងឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប។

នៅខែធ្នូ ឆ្នាំ១៩៧៨ ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅនៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ មួយរយៈក្រោយមក ខ្មែរក្រហមក៏ជម្លៀសគ្រួសារខ្ញុំត្រឡប់ទៅនៅស្រុកស្រីស្នំ ខេត្តសៀមរាបវិញ។ នៅទីនោះ ដោយសារគ្រួសាររបស់ខ្ញុំមានទំនាក់ទំនងល្អជាមួយអតីតយោធាម្នាក់ ទើបយោធានោះបានលួចប្រាប់ឪពុករបស់ខ្ញុំថា គ្រួសារខ្ញុំនឹងត្រូវខ្មែរក្រហមយកទៅសម្លាប់បន្ទាប់ពីការជម្លៀសនេះមិនខាន។ ថ្ងៃមួយ កម្មាភិបាលខ្មែរក្រហមបានប្រកាសប្រាប់ប្រជាជននៅក្នុងភូមិឲ្យទៅចូលរួមពិធីជប់លៀងនៅភ្នំថ្មក្រាប នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៩ ជាពេលវេលាដែលខ្មែរក្រហមរៀបផែនការសម្លាប់ប្រជាជន។ ប៉ុន្តែសំណាងល្អ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិបានចូលមករំដោះ ខ្ញុំ និងក្រុមគ្រួសារមុន គឺនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ប្រជាជនទាំងអស់បានមកជួបជុំបងប្អូនសាច់ញាតិ និងបានវិលត្រឡប់មកស្រុកកំណើតរៀងខ្លួនវិញ។ ពេលនោះ រដ្ឋអំណាចក៏បានបែងចែកដីធ្លីឲ្យគ្រួសាររបស់ខ្ញុំធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។ ចំណែកកងឈ្លបខ្មែរក្រហមនៅក្នុងភូមិដែលធ្លាប់ធ្វើបាបប្រជាជន ក៏បានរត់

ភៀសខ្លួនទៅរស់នៅតាមជំរំរឹងប្រធានសហករណ៍ខ្មែរក្រហមខ្លះដែលរត់គេចខ្លួនមិនទាន់ ក៏ត្រូវប្រជាជនសម្លាប់ ព្រោះឈឺចាប់ជាមួយនឹងរបបខ្មែរក្រហម។ ក្រោយមក ខ្ញុំក៏ផ្លាស់ទីលំនៅពីស្រុកភ្នំស្រុកមករស់នៅក្នុងឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដោយបានប្រកបរបរជាកសិករ រហូតមកដល់សព្វថ្ងៃ។

## ៤) វ៉ាង វឿង

នៅពេលខ្ញុំមានអាយុ៧ឆ្នាំ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើការនៅក្នុងកងកុមារ។ កាលនោះគ្រួសាររបស់ខ្ញុំមានសមាជិក៨នាក់ រស់នៅស្រុកក្រឡាញ់ ខេត្តសៀមរាប។ នៅក្នុងសម័យខ្មែរក្រហម ប្រជាជនចាប់ផ្តើមធ្វើការចាប់ពីម៉ោង៥ព្រឹក ដល់ម៉ោង១១ថ្ងៃត្រង់ ហើយពេលរសៀលធ្វើការចាប់ពីម៉ោង១រសៀល ដល់ម៉ោង៥ ឬ ៦ល្ងាច។ ដោយឡែកខ្ញុំជាកុមារតែងតែបានបរិភោគអាហារមុនគេ។ ទាំងកុមារទាំងមនុស្សចាស់បានទទួលរបបអាហារពីរពេលក្នុងមួយថ្ងៃដូចៗគ្នា។ ខ្មែរក្រហមបានចែកចានមួយ និងស្លាបព្រាបាយមួយសម្រាប់មនុស្សម្នាក់ៗ ដើម្បីប្រើប្រាស់រៀងៗខ្លួន។

នៅម៉ោងសម្រាកពីការងារ ខ្ញុំនិងក្មេងដទៃ តែងតែដើររកអាហារហូបបន្ថែម ដូចជា បេះស្លឹកផ្ទី និងជីកមើមក្តួច។ ការងាររបស់ខ្ញុំពេលនោះ គឺដើររើសអាចម៍គោក្របី និងកាត់ដើមទន្ទ្រានខែត្រដើម្បីចិញ្ច្រាំធ្វើជី។ ខ្ញុំមិនត្រូវបានមេកងវាយដំឡើយព្រោះខ្ញុំនៅក្មេង ប៉ុន្តែខ្ញុំធ្លាប់បានទទួលពិន័យឲ្យឈរលើសំបុកស្រមោច និងឈរហាលថ្ងៃ។

នាពេលខ្លះ ខ្ញុំបានមកដេកជាមួយឪពុកម្តាយ ហើយថ្ងៃខ្លះទៀតខ្ញុំស្នាក់នៅជាមួយកងកុមារ។ រឿងរ៉ាវដែលធ្វើឲ្យខ្ញុំតក់ស្លុត និងភ័យខ្លាចបំផុតនោះ គឺការសម្លាប់មនុស្សដែលប្រព្រឹត្តដោយឈ្លបខ្មែរក្រហម។ នៅសម័យនោះ ប្រជាជនដែលត្រូវបានចោទថាបានប្រព្រឹត្តខុសវិន័យ ត្រូវបានឈ្លបខ្មែរក្រហមចាប់ចងនិងបណ្តើរទាំងខ្សែៗ ដោយក្នុងមួយខ្សែមានមនុស្សចាប់ពី១០នាក់ឡើងទៅ និងមានយោធាខ្មែរក្រហមម្នាក់កាន់ខ្សែបណ្តើរពីមុខ និងម្នាក់ទៀតនៅខាងក្រោយ។ ពេលបណ្តើរអ្នកទោសដល់មាត់ជ្រោះ ខ្មែរក្រហមបានវាយរួចហើយច្រានអ្នកទោសនោះទម្លាក់ចូលទៅក្នុងជ្រោះនោះ បន្ទាប់មកខ្មែរក្រហមបានចាក់អង្កាមលើសាកសពដើម្បីដុតធ្វើជាជីដាក់ដំណាំនិងស្រូវ។ អ្នកដែលធ្លាក់ចូលក្នុងជ្រោះនោះ មិនអាចឡើងមកវិញបានឡើយ។ ខ្ញុំធ្លាប់ដើរទៅជិតជ្រោះនោះ និងបានឮសំឡេងមនុស្សស្រែកឲ្យជួយ។

នៅឆ្នាំ១៩៨៤ ខ្ញុំបានចូលបម្រើជាកងទ័ពរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា។ នៅឆ្នាំ១៩៨៤ ខ្ញុំបានរៀបការ ហើយបានទៅរស់នៅជាមួយប្រពន្ធនៅភូមិកណ្តាល ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។

មកដល់ឆ្នាំ១៩៩០ ខ្ញុំនិងប្រពន្ធក៏បានផ្លាស់មករស់នៅក្នុងភូមិគោកសំព័រ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ក្រោយមក ខ្ញុំបានសម្រេចចិត្តឈប់ធ្វើជាទាហានដោយសារប្រាក់ខែមិនគ្រប់គ្រាន់។ សព្វថ្ងៃខ្ញុំមានកូន៦នាក់ កូនស្រី៣នាក់ និងកូនប្រុស៣នាក់ ដោយប្រកបរបរកសិកម្ម និងធ្វើជំនួញ។

## ៥) នួន អ៊ឹម

នៅឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសពីស្រុកកំណើតក្នុងខេត្តកំពង់ធំ ឲ្យទៅខេត្តកំពង់ចាម។ ពេលនោះ ខ្ញុំមានអាយុ១៦ឆ្នាំ ជាកូនពៅក្នុងចំណោមបងប្អូនចំនួន៧នាក់ (ប្រុស៣នាក់ និង ស្រីចំនួន៤នាក់) ត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យធ្វើការងារ ដូចជា លើកទំនប់ និងជីកប្រឡាយ។ ក្រោយមក ខ្ញុំត្រូវបានជ្រើសរើសឲ្យចូលក្នុងកងដឹកជញ្ជូនគ្រាប់ឲ្យយោធា។

ក្រោយរបបខ្មែរក្រហមដួលរលំ ខ្ញុំនិងក្រុមគ្រួសារបានភៀសខ្លួនពីស្រុកកំណើតមកនៅអន្លង់វែង។ ពេលនោះ ខ្ញុំបានបាត់បង់ឪពុកជាទីស្រឡាញ់ដោយសារជាន់មីននៅតាមផ្លូវពេលរត់ភៀសខ្លួន។ ក្រុមគ្រួសាររបស់ខ្ញុំ បានមករស់នៅក្នុងតំបន់អន្លង់វែងមិនទាន់បានប៉ុន្មានផង ក៏ស្រាប់តែឮដំណឹងថាកងទ័ពវៀតណាមវាយចូលមក។ ដូច្នេះ ខ្ញុំនិងគ្រួសារក៏ចាប់ផ្តើមរៀបចំបង្វេចខោអាវរត់ចេញពីតំបន់អន្លង់វែងដោយ

ធ្វើដំណើរថ្មើរជើងទៅនៅជំរំភូណាយ ក្នុងទឹកដីថៃ។ ការធ្វើដំណើររបស់ខ្ញុំនៅពេលនោះជួបការលំបាកខ្លះដែរ ដោយការខ្វះខាតស្បៀងអាហារហូបចុក និងថ្នាំសង្កូវយ៉ាងខ្លាំង។ នៅពេលមកដល់ជំរំក្នុងទឹកដីថៃ ទើបការរស់នៅ និងជីវភាពរបស់ខ្ញុំបានប្រសើរជាងមុន ដោយសារមានអង្គការអន្តរជាតិផ្គត់ផ្គង់អាហារសម្រាប់ប្រជាជនដែលរត់ភៀសខ្លួន។

ខ្ញុំ និងក្រុមគ្រួសារ បានរស់នៅក្នុងជំរំក្នុងទឹកដីថៃមួយរយៈ យើងបានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ។ ខ្ញុំ និងប្រជាជនភៀសខ្លួនដទៃទៀតបានមកនៅភូមិសន្តិភាព ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ក្រោមការគ្រប់គ្រងរបស់តាម៉ុក។ តាម៉ុក បានពិការជើងម្ខាងដោយសារផ្ទុះគ្រាប់មីននៅពេលគាត់ដើរពិនិត្យមើលការដ្ឋានឈូសឆាយធ្វើផ្លូវ។ បើទោះបីជា តាម៉ុក ពិការជើងម្ខាងក៏ដោយ ក៏ តាម៉ុក នៅតែមានឥទ្ធិពលនៅក្នុងតំបន់អន្លង់វែង និងបានដឹកនាំយោធាខ្មែរក្រហមធ្វើសង្គ្រាមប្រឆាំងរាជរដ្ឋាភិបាលដដែល។ តាម៉ុក បានខិតខំរិះរកស្បៀងអាហារសម្រាប់ផ្គត់ផ្គង់កងទ័ព និងប្រជាជនដែលបានភៀសខ្លួនមកពីតំបន់ផ្សេងៗ និងបានសាងសង់សាលារៀន មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត ដើម្បីទាក់ទាញការគាំទ្រពីប្រជាជនចំពោះការដឹកនាំរបស់ខ្លួន។

### ៦) ជន់ មិល

ខ្ញុំមានអាយុ៨០ឆ្នាំ មានប្រពន្ធឈ្មោះ ម៉ៅ យឿ អាយុ៧៩ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិភ្នំបាត ឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល។ មុនសម័យខ្មែរក្រហម ខ្ញុំបានបួសនៅវត្តមួយនៅភូមិកំណើត។ ខ្ញុំបានរៀនអក្សរបាលី សំស្ក្រឹត និងបានប្រឡងជាប់មធ្យមសិក្សាផ្នែកបាលី។ បន្ទាប់ពីបានខ្ញុំប្រឡងជាប់មួយរយៈ ស្រាប់តែលោកសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីអំណាច។ ចាប់តាំងពីពេលនោះមក ក៏មានការលេចចេញនូវក្រុមចលនាតស៊ូមួយក្រុមដែលមានឈ្មោះថា ខ្មែរក្រហម បានប្រមូលកម្លាំងដើម្បីប្រឆាំងនឹងលោក លន់ នល់ វិញ។

ចលនាតស៊ូរបស់ខ្មែរក្រហមកាន់តែរីកធំឡើងៗ រហូតបានផ្តួលរំលំរបប លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ អ្វីៗដែលជាការរំពឹងទុករបស់ខ្ញុំដែលថា ប្រទេសជាតិទទួលបានសុខសន្តិភាពគឺផ្ទុយស្រឡះទាំងស្រុង។ ខ្ញុំ និងប្រជាជនជាច្រើនទៀតត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅកាន់តំបន់ឆ្ងាយៗ ក្រោយពីរំដោះបានទីក្រុងភ្នំពេញទាំងស្រុង។ ខ្ញុំត្រូវបានប្រធានភូមិថ្មីចាត់តាំងដោយខ្មែរក្រហមបញ្ជាឲ្យធ្វើការងារបង្កបង្កើនផល លើកទំនប់ ជីកប្រឡាយ ទៅតាមផែនការដែលថ្នាក់លើបានកំណត់។ ប្រជាជននៅកងចល័តក្នុងម្នាក់ៗ យ៉ាងហោចណាស់ត្រូវលើកភ្លឺស្រែប្រវែង១៥ម៉ែត្រក្នុងមួយថ្ងៃ ប្រសិនបើធ្វើមិនបានតាមផែនកការកំណត់ប្រធានកងមិនអនុញ្ញាតឈប់សម្រាក និងហូបបាយឡើយ។

ខ្ញុំបានខិតខំតស៊ូ ប្រឹងប្រែងព្យាយាមធ្វើការងារ រហូតសម្រេចតាមផែនការកំណត់។ ចំណែករបបអាហារដែលខ្ញុំទទួលបានមានតែបបរពីរវែករាវៗ សឹងតែរកគ្រាប់អង្ករគ្មានលាយជាមួយគល់ល្ហុង និងបណ្តូលចេក។ ខ្ញុំបានហូបអាហារពីរពេលក្នុងមួយថ្ងៃ គឺពេលថ្ងៃខ្ញុំហូបនៅវេលាម៉ោង១១ និងពេលល្ងាចខ្ញុំហូបនៅវេលាម៉ោង៥រសៀល។ ដោយសារតែការបរិភោគមិនឆ្អែត ខ្ញុំបានឆ្លៀតដើររើសផ្លែត្នោតទុំហូបបន្ថែមទៀត។ ខ្ញុំក៏បានលាក់ទុកផ្លែត្នោតទុំខ្លះហូបនៅពេលព្រឹកមុនចេញទៅធ្វើការដែរ។ បើទោះបីខ្ញុំហូបផ្លែត្នោតទុំ ឬដំណាំផ្សេងៗ ដែលមិនមែនជារបស់ខ្មែរក្រហមដាំក៏ដោយ ក៏ខ្មែរក្រហមនៅតែចាត់ទុកថា ខ្ញុំបានប្រព្រឹត្តផ្ទុយទៅនឹងច្បាប់របស់អង្គការ ហើយអាចយកខ្ញុំទៅរៀនសូត្រ ឬសម្លាប់ចោលប្រសិនបើកងឈ្លបបានឃើញខ្ញុំលួចហូប។

ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើស្រែគ្មានពេលសម្រាកឡើយ ចាប់ពីរដូវដកស្ទូង រហូតដល់រដូវច្រូតកាត់។ បន្ទាប់ពីរដូវច្រូតកាត់បានកន្លងផុតទៅ ខ្ញុំត្រូវបានខ្មែរក្រហមផ្លាស់ឲ្យទៅលើកទំនប់ ជីកប្រឡាយ និងលើកភ្លឺស្រែ ដែលខ្មែរក្រហមបានចែកជាក្រុមៗឲ្យធ្វើការងារនេះ។ ប្រសិនបើយើងធ្វើមិនរួចរាល់តាមការកំណត់នោះទេ យើងអាចប្រឈមទៅ

នឹងការចោទប្រកាន់ខ្មែរក្រហមថា ខ្ជិលច្រអូស មិនត្រឹមតែប៉ុណ្ណោះខ្មែរក្រហមបានដកកម្លាំងចេញខ្លះ រួចហើយបង្ខំឲ្យកងរបស់យើងធ្វើការរហូតរួចរាល់តាមផែនការ។

ខ្ញុំត្រូវបានខ្មែរក្រហមហៅទៅសួរនាំពីប្រវត្តិរូបដែរ ព្រោះខ្ញុំធ្លាប់មានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ប៉ុន្តែខ្ញុំបានកុហកថា ខ្ញុំបានរៀនផ្នែកភាសាបាលីបន្តិចបន្តួចតែប៉ុណ្ណោះ ហើយបន្ទាប់ពីឈប់រៀន ខ្ញុំបានចេញមកធ្វើជាកម្មករដើម្បីចិញ្ចឹមគ្រួសារ។

នៅពេលរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ ខ្ញុំបានរត់ភៀសខ្លួនទៅភ្នំដងរែក ចំណែកប្រជាជនខ្លះ ក៏បានរត់ចូលទៅខាងរដ្ឋាភិបាលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលគាំទ្រដោយវៀតណាម។ ខ្ញុំបានសង់ខ្ទមនៅក្នុងព្រៃលើភ្នំដងរែកជាមួយប្រជាជនដែលរត់គេចខ្លួនដូចគ្នា ចំណែកអាហារហូបចុកវិញ ខ្ញុំទទួលបានការផ្គត់ផ្គង់ពីក្រុមរបស់តាម៉ុក។ ពេលនោះក៏មានសង្គ្រាមរវាងខ្មែរក្រហម និងរដ្ឋាភិបាលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែរ។ ដូច្នេះខ្ញុំបានបន្តរស់នៅជំរំចាប់ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៥។ ក្រោយមក ខ្មែរក្រហមក៏បានប្រកាសឲ្យប្រជាជនភៀសខ្លួនទាំងអស់



ក្រុមនិស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងសម្ភាសន៍ប្រជាជននៅក្នុងសហគមន៍អន្លង់វែង ខេត្តឧត្តរមានជ័យ អំពីបទពិសោធន៍ក្នុងសម័យខ្មែរក្រហម (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចុះមករស់នៅក្នុងស្រុកអន្លង់វែងវិញ ដោយបានបង្កើតទៅជាភូមិឃុំ។ ដំបូង ខ្ញុំបានរស់នៅឃុំត្រពាំងប្រីយ៍ ប៉ុន្តែមិនទាន់បានប៉ុន្មានផង ខ្មែរក្រហមបានប្រកាសប្រាប់ខ្ញុំ និងប្រជាជនឲ្យឡើងទៅរស់នៅលើភ្នំដងរែកសារជាថ្មី។ រហូតមកដល់ឆ្នាំ១៩៩៨ ទើបមានការចចាររវាងយោធាខ្មែរក្រហមជាមួយរាជរដ្ឋាភិបាលដើម្បីបញ្ចប់សង្គ្រាម។ ដូច្នេះ ខ្ញុំនិងប្រជាជនភៀសខ្លួនផ្សេងទៀត ក៏បានចុះពីលើភ្នំដងរែកមករស់នៅក្នុងស្រុកអន្លង់វែងវិញ។ ប្រជាជនខ្លះទៀតក៏បន្តដំណើរទៅស្រុកកំណើតដើម្បីរស់នៅជួបគ្រួសារ និងប្រពន្ធកូន។ ដោយឡែកខ្ញុំមិនបានវិលត្រឡប់ទៅស្រុកកំណើតវិញទេ ដោយសារមិនមានដីធ្លីនៅឯស្រុក ដូច្នេះខ្ញុំសម្រេចចិត្តបន្តរស់នៅក្នុងស្រុកអន្លង់វែងរហូតដល់បច្ចុប្បន្ន។

**៧) យស់ ថាច**

កាលពីសង្គមចាស់ ខ្ញុំបានរៀនត្រឹមថ្នាក់ទី៦ប៉ុណ្ណោះ នៅសាលាបឋមសិក្សាវត្តព្រៃង ក្នុងខេត្តកំពង់ចាម។ សម័យនោះ ខ្ញុំមានបងប្អូនបង្កើតទាំងអស់ចំនួន៨នាក់ និងមានឪពុកឈ្មោះ អ៊ូច អាន និង ម្ដាយឈ្មោះ នា ផុត (អ្នកទាំងពីរបានស្លាប់ក្នុងសម័យខ្មែរក្រហម)។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានអង្គការជម្លៀសចេញពីស្រុកកំណើតនៅភូមិពែងមាសជើង ឃុំស្ដី ស្រុកចម្ការលើ ខេត្តកំពង់ចាម ឲ្យទៅរស់នៅខេត្តកំពង់ធំ។ អង្គការបានចាត់តាំងខ្ញុំធ្វើការនៅក្នុងកងចល័ត និងប្រើឲ្យលើកទំនប់ស្ទឹងជីនិត ដែលមានសមាជិកសរុបចំនួន១៩៣នាក់។ ពេលនោះគឺជារដូវប្រាំង ដូច្នេះការកាប់គាស់ និងលើកទំនប់ ជួបការលំបាកយ៉ាងខ្លាំង ព្រោះដីរឹងបែកក្រហែង ព្រមទាំងគ្មានទឹកគ្រប់គ្រាន់សម្រាប់ផឹកទៀតផង។ ចំណែករបបអាហារ គឺមានតែបាយលាយជាមួយចេកខ្ចីប៉ុណ្ណោះ។ ទោះបីជាលំបាកយ៉ាងណាក៏ដោយ ខ្ញុំពុំដែលហ៊ានត្អូញត្អែរ និងតវ៉ាជាមួយអង្គការដែរ ព្រោះខ្ញុំដឹងថាប្រសិនបើហ៊ានតវ៉ាគឺច្បាស់ជាអង្គការយកខ្ញុំទៅសម្លាប់ចោលមិនខាន។ កន្លះឆ្នាំក្រោយមក អង្គការបានផ្លាស់ខ្ញុំឲ្យមកនៅស្រុកចម្ការលើវិញ ដោយបានចាត់តាំងខ្ញុំឲ្យលើកទំនប់ ដើម្បីទប់ទឹកសម្រាប់បញ្ចូលស្រែ។

មកដល់ឆ្នាំ១៩៧៦ អង្គការបានជ្រើសរើសខ្ញុំឲ្យចូលបម្រើអង្គភាពយោធា រួចហើយបញ្ជូនមកឲ្យឈរជើងនៅក្រុងភ្នំពេញ។ ពេលនោះ ខ្ញុំមានកិច្ចការយាមល្បាតនៅជុំវិញទីក្រុងភ្នំពេញ។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំត្រូវបានមេបញ្ជាការបញ្ជូនឲ្យទៅប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅអ្នកលឿង។

បន្ទាប់ពីច្បាំងចាញ់កងទ័ពវៀតណាម ខ្ញុំបានរត់ភៀសខ្លួនទៅព្រំដែនថៃ។ នៅតាមផ្លូវ ខ្ញុំបានជួបប្រទះនូវឧបសគ្គជាច្រើនដោយសារកងទ័ពវៀតណាមដេញតាមវាយប្រហារ ហើយអង្គភាពទ័ពរបស់ខ្ញុំដែលមានសមាជិកទាំងអស់ប្រហែល៩០នាក់ ក៏គ្មានស្បៀងអាហារគ្រប់គ្រាន់សម្រាប់ហូបដែរ។ ខ្ញុំបានភៀសខ្លួនមកដល់តំបន់ប៉ៃលិន ហើយបានរស់នៅទីនោះអស់រយៈពេល៣ឆ្នាំ។ ក្រោយមក ខ្ញុំ និងអង្គភាពបានផ្លាស់ទីពីប៉ៃលិនទៅឈរជើងនៅភ្នំឆ័ត្រក្នុងអង្គភាព (ក-៥)។ ពេលនោះ ខ្ញុំបានចេញទៅប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាមស្ទើរតែគ្មានលោះពេលឡើយក្នុងរយៈពេលមួយខែៗ។ មានយោធាខ្មែរក្រហមជាច្រើននាក់បានដើរជាន់មីនស្លាប់ និងពិការ។ នៅឆ្នាំ១៩៩៧ ខ្ញុំបានផ្លាស់មករស់នៅតំបន់អន្លង់វែងវិញ ដោយសារខ្មែរក្រហមនៅអន្លង់វែង បានរៀបចំ និងបង្កើតឲ្យមានភូមិឃុំសម្រាប់ប្រជាជនរស់នៅ។

នៅក្នុងឆ្នាំ១៩៩៩ នៅពេលដែលកងកម្លាំងរបស់ខ្មែរក្រហមធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល ខ្ញុំក៏បានចូលបម្រើកងទ័ពរដ្ឋាភិបាលរហូតដល់ឆ្នាំ២០០៨ ទើបខ្ញុំសម្រេចចិត្តលាឈប់។ ក្រោយសមាហរណកម្មពីរឆ្នាំ ខ្ញុំបាននាំប្រពន្ធកូនចៅទៅលេងស្រុកកំណើតនៅស្រុកចម្ការលើ និងបានជួបបងស្រី។ ខ្ញុំបានស្នាក់នៅជាមួយបងស្រីនៅឯស្រុកមួយរយៈក៏ធ្វើដំណើរត្រឡប់មករស់នៅឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ វិញ។ សព្វថ្ងៃ ខ្ញុំមានអាយុ៥៩ឆ្នាំ មានប្រពន្ធឈ្មោះ មុត រី និងមានកូនស្រីចំនួន៣នាក់។

*សោម ប៊ុនថន*

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែមេសា ឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ២០១៩ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរ ឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្តី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្តី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្តុះបណ្តាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

**លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖**

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង៥ល្ងាច។

**សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖**

១) លិខិតសុំធ្វើការងារ ១ច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាម៉ីខ្លួន។

២) ប្រវត្តិរូបសង្ខេប ១ច្បាប់ (Resume)។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល៖ truthbunthorn.s@dccam.org។ ប្រសិនបើមានចម្ងល់ សូមទូរសព្ទមកលេខ៖ ០២៣ ២១៤ ០០៩ ឬ ០១២ ៩៩៦ ៧៥០។

**សូមអរគុណ!**

# ខ្ញុំធ្លាក់ខ្លួនពិការដោយសារជាន់មីន

«ទោះបីខ្ញុំធ្លាក់ខ្លួនពិការដោយសារការតស៊ូវាយប្រយុទ្ធគ្នាជាមួយកងទ័ពខ្មែរក្រហមក៏ខ្ញុំមិនដែលតូចចិត្តនឹងខ្លួនឯងដែរ ព្រោះការតស៊ូនេះបានធ្វើឲ្យខ្ញុំរឹងមាំ និងបានចូលរួមចំណែកជួយប្រជាជនកម្ពុជាឲ្យរួចផុតពីរបបខ្មែរក្រហម»។

ខាងលើនេះ គឺជាការរៀបរាប់របស់ សុខ ង៉ា បច្ចុប្បន្នរស់នៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ង៉ា បាននិយាយមកកាន់ខ្ញុំទាំងទឹកមុខរីករាយ នៅខណៈពេលដែលគាត់កំពុងមមាញឹកជួសជុលម៉ាស៊ីនបូមទឹកថា នៅឆ្នាំ ១៩៧៥ ពេលខ្មែរក្រហមឡើងកាន់អំណាចខ្ញុំមានវ័យប្រហែល ១៥ឆ្នាំ និងរស់នៅខេត្តព្រះត្រពាំង (កម្ពុជាក្រោម) ប្រទេសវៀតណាម។ នាពេលនោះ ខ្ញុំគឺជាសិស្សសាលាបឋមសិក្សាក្នុងខេត្តព្រះត្រពាំង។ ខ្ញុំរៀនបាន៨ឆ្នាំ ក៏ត្រូវរដ្ឋាភិបាលវៀតណាម ចាប់បង្ខំឲ្យចូលធ្វើកងទ័ពដើម្បីវាយប្រយុទ្ធជាមួយខ្មែរក្រហម ក្នុងគោលបំណងរំដោះប្រជាជនកម្ពុជាឲ្យរួចផុតពីការកាប់សម្លាប់ នៅក្នុងឆ្នាំ១៩៧៩។ ខ្ញុំបានធ្វើជាកងទ័ពវៀតណាមចាប់តាំងពីឆ្នាំ១៩៧៩មក។ បន្ទាប់មក អង្គភាព



សុខ ង៉ា កំពុងជួសជុលម៉ាស៊ីនបូមទឹក នៅក្នុងស្រុកព្រះនេត្រព្រះ (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទ័ពបានចាត់តាំងខ្ញុំឲ្យទៅហ្វឹកហាត់ និងរៀនសូត្រពីយុទ្ធសាស្ត្រកងទ័ពនៅតំបន់៤ ក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា អស់រយៈពេលប្រាំមួយខែ។ ប្រាំមួយខែក្រោយមក ខ្ញុំត្រូវបានថ្នាក់លើចាត់តាំងឲ្យទៅឈរជើងនៅស្រុកម៉ាឡៃ ក្នុងខេត្តបន្ទាយមានជ័យ។ នៅទីនោះខ្ញុំបានចូលសមរភូមិវាយប្រយុទ្ធតទល់នឹងយោធាខ្មែរក្រហមជារៀងរាល់ថ្ងៃ និងស្ទើរតែគ្មានពេលឈប់សម្រាកឡើយ។ ទោះជាយ៉ាងនេះក្ដី ក៏ខ្ញុំមិនដែលរុញរាដែរ ព្រោះវាជាកាតព្វកិច្ចរបស់ខ្ញុំក្នុងការផ្ដួលរំលំកងកម្លាំងរបស់ខ្មែរក្រហមដែលនៅសេសសល់។ មួយរយៈក្រោយមក ខ្ញុំនិងកងទ័ពវៀតណាមដទៃទៀត បានផ្លាស់ប្ដូរទីកន្លែងទៅឈរជើងនៅក្នុងភូមិម៉ក់ហឺន (ស្ថិតក្នុងស្រុកម៉ាឡៃដដែល) ព្រោះកន្លែងឈរជើងចាស់ខ្វះទឹកប្រើប្រាស់ និងពិបាកក្នុងការដឹកជញ្ជូនស្បៀង និងគ្រាប់សព្វាវុធ ដែលនាំឲ្យមានការលំបាកក្នុងការវាយប្រយុទ្ធតទល់នឹងយោធាខ្មែរក្រហម ព្រោះយោធាខ្មែរក្រហមពូកែវាយឆ្មក់។ ជួនកាលយោធាខ្មែរក្រហមមានត្រឹមតែដប់នាក់ប៉ុណ្ណោះ ប៉ុន្តែអាចវាយកងទ័ពវៀតណាមស្លាប់ និងរបួសជាច្រើននាក់ ដោយសារការលួចឆ្មក់គប់គ្រាប់បែក ចូលបន្ទាយទាហានវៀតណាម។ ពេលខ្ញុំឈរជើងនៅភូមិម៉ក់ហឺន ពេលនោះយោធាខ្មែរក្រហមបានវាយសម្រុកចូលជាញឹកញាប់។

រហូតដល់ឆ្នាំ១៩៨៣ ខ្ញុំបានផ្លាស់ទៅឈរជើងនៅភូមិអូរបីជាន់ដើម្បីការពារព្រំដែនដីកប្រឡាយ និងលើកទំនប់។ មកដល់ឆ្នាំ១៩៨៥ ខ្ញុំត្រូវបានថ្នាក់លើបញ្ជូនឲ្យទៅប្រយុទ្ធតទល់នឹងកងទ័ពខ្មែរក្រហមនៅសមរភូមិក្ដុលតាយីង ក្នុងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងជាមួយសមាជិកក្រុមប្រមាណដប់នាក់ ខណៈនោះខ្ញុំក៏បានជាន់មីន៦៩ និងធ្លាក់ខ្លួនពិការមកដល់សព្វថ្ងៃ។ ខ្ញុំត្រូវបានអង្គភាពទ័ពបញ្ជូនមកសម្រាកព្យាបាលនៅមន្ទីរពេទ្យភូមិភាគ ស្ថិតនៅក្នុងក្រុងស្វាយស៊ីសុផុន។ ខ្ញុំបានសម្រាកព្យាបាលរបួសនៅមន្ទីរពេទ្យអស់រយៈពេលបីខែ ទើបថ្នាក់លើបញ្ជូនខ្ញុំទៅសម្រាកព្យាបាលរបួសបន្តនៅខេត្តសៀមរាប។ បន្ទាប់ពីបានជាសះស្បើយរួចហើយ ខ្ញុំត្រូវបានសាច់ញាតិបបួលមករស់នៅទីក្រុងភ្នំពេញ ព្រមទាំងបានណែនាំខ្ញុំឲ្យរកស៊ីទិញទំនិញគេចពន្ធពីប្រទេសថៃ រួមមាន សម្លៀកបំពាក់ ម្សៅ និងគ្រឿងទេស ដើម្បីយកមកលក់នៅស្រុកខ្មែរ។ នៅឆ្នាំ១៩៨៩ ខ្ញុំបានផ្លាស់មករស់នៅខេត្តសៀមរាប និងមានប្រពន្ធជាអ្នកខេត្តសៀមរាប។ រហូតមកដល់ឆ្នាំ១៩៩៣ ប្រពន្ធរបស់ខ្ញុំបានស្លាប់ដោយសារជំងឺ ទើបខ្ញុំសម្រេចចិត្តមករស់នៅក្នុងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យវិញ។

ក្រោយមក ខ្ញុំបានរៀបការប្រពន្ធថ្មី នៅក្នុងស្រុកព្រះនេត្រព្រះ និងបានប្រកបរបរជាជាងជួសជុលកង់នៅក្នុងស្រុកព្រះនេត្រព្រះ។ មកដល់ឆ្នាំ១៩៩៥ អង្គការទស្សនពិភពលោកបានមកជួបខ្ញុំ ហើយបានសាកសួរ និងសម្ភាសន៍ខ្ញុំពីពិការភាព។ អង្គការនេះបានសួរខ្ញុំថា «តើខ្ញុំមានចំណាប់អារម្មណ៍ ចង់រៀនជំនាញជួសជុលគ្រឿងម៉ាស៊ីនដែរឬទេ?» ពេលនោះ ខ្ញុំបានឆ្លើយតបទៅកាន់បុគ្គលិកអង្គការថា «ខ្ញុំពិតជាចង់រៀនណាស់»។ ក្រោយមក បុគ្គលិកអង្គការទស្សនពិភពលោក បានស្នើឲ្យខ្ញុំជួយបំពេញឯកសារបែបបទ ក្នុងការរៀនវគ្គជំនាញជួសជុលម៉ូតូ និងម៉ាស៊ីនម៉ាស៊ូត។ បន្ទាប់មក ខ្ញុំក៏បានមករៀនជំនាញនេះនៅឃុំអន្លង់វិល ក្នុងខេត្តបាត់ដំបង។

រហូតដល់ឆ្នាំ១៩៩៧ ខ្ញុំបានរៀនចប់វគ្គជំនាញជួសជុល និងបានបើករបរធ្វើជាជាងជួសជុលម៉ូតូ និងជាងជួសជុលម៉ាស៊ីន នៅក្នុងស្រុកព្រះនេត្រព្រះ រហូតមកដល់សព្វថ្ងៃនេះ។ សព្វថ្ងៃខ្ញុំពិតជារវល់ខ្លាំងណាស់ចំពោះអាជីពនេះ ព្រោះខ្ញុំមិនត្រឹមតែជាងនៅក្នុងស្រុកព្រះនេត្រព្រះប៉ុណ្ណោះទេ គឺខ្ញុំបានដើរជួសជុលគ្រឿងម៉ាស៊ីនស្ទើរតែទូទាំងខេត្តបន្ទាយមានជ័យ។ ទោះបីខ្ញុំពិការដោយសារសង្គ្រាមពិតមែន តែខ្ញុំក៏អាចធ្វើការរកស៊ីដូចជាប្រជាជនធម្មតាផ្សេងទៀតដែរ ដូច្នេះខ្ញុំសូមជំរុញទឹកចិត្តដល់ជនពិការកម្ពុជាដទៃទៀត ត្រូវតែមានក្ដីសង្ឃឹម។

ហ៊ូ ផុនា

# នៅពេលទស្សនាល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់ បានធ្វើឲ្យខ្ញុំចងចាំឡើងវិញពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម

*ប៉ាង អ៊ិន បានក្រោកចេញពីអង្រឹងដែលចងនៅក្រោមផ្ទះឈើរបស់គាត់ ជាមួយទឹកមុខញញឹមញញែមនៅពេលពួកខ្ញុំជម្រាបសួរគាត់ពីចម្ងាយៗ គាត់ហាក់បង្ហាញនូវទឹកចិត្តរីករាយនៅពេលដែលខ្ញុំសាកសួរសុខទុក្ខគាត់ៗ បន្ទាប់ពីសំណេះសំណាល និងជម្រាបគាត់ពីការងាររបស់ខ្ញុំរួចមក ខ្ញុំក៏បានសុំការអនុញ្ញាតដើម្បីសាកសួរគាត់ពីបទពិសោធន៍នៅក្នុងរបបខ្មែរក្រហម និងបានឆ្លៀតឱកាសអញ្ជើញគាត់ទៅទស្សនាការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ ដែលមានចម្ងាយប្រមាណ៥គីឡូម៉ែត្រពីផ្ទះរបស់គាត់ៗ*

## *សាច់រឿងក្នុងល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់*

*ល្ខោននិយាយ«ទម្លាយភាពស្ងៀមស្ងាត់» គឺជាសាច់រឿងល្ខោនដែលដកស្រង់ចេញពីរឿងរ៉ាវពិតរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម តាមរយៈការស្រាវជ្រាវ និងសម្ភាសន៍ជាមួយជនរងគ្រោះ និងជនដៃដល់នៅតាមភូមិឃុំនានាក្នុងប្រទេសកម្ពុជាៗ ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺជាការជំរុញឲ្យមានការយល់ដឹងបន្ថែមពីប្រវត្តិសាស្ត្រសម័យខ្មែរក្រហម ការផ្សះផ្សា ការព្យាបាលរបួសផ្លូវចិត្ត រួមទាំងការដោះស្រាយនូវបញ្ហាប្រឈមនានាទាក់ទងនឹងប្រវត្តិសាស្ត្រដ៏សោកសង្រេងដែលបានកើតឡើង*



*ប៉ាង អ៊ិន និង ចៅ នៅមុខផ្ទះរបស់គាត់ ស្ថិតនៅឃុំអូរស្វាយចេក សង្កាត់រការក្នុង ក្រុងដូនកែវ*
*(រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩)។ ក្រោយពីការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» អ្នកទស្សនាក៏មានឱកាសពិភាក្សា លើកឡើងអំពីបទពិសោធន៍ជីវិតផ្ទាល់ខ្លួន និងបង្ហាញពីចំណាប់អារម្មណ៍ប្រាប់ដល់អ្នកចូលរួមដែរ។

អ៊ិន មានការភ្ញាក់ផ្អើលនៅពេលឮពីការសម្តែងល្ខោននេះ ព្រោះពេលទស្សនា និងស្តាប់ចម្រៀងដែលច្រៀងរៀបរាប់អំពីរបបខ្មែរក្រហម គាត់តែងនឹកឃើញពីរឿងរ៉ាវរបស់គាត់ ភាពភ័យខ្លាច ការអត់ឃ្លាន ការធ្វើការងារស្រែចម្ការ ការលើកទំនប់ និងការជីកប្រឡាយដើម។ សព្វថ្ងៃ អ៊ិន មានអាយុ៧១ឆ្នាំហើយ ហើយគាត់គឺជាអាចារ្យវត្ត និងជាមេភូមិអូរស្វាយចេក ស្ថិតនៅក្នុងសង្កាត់រការក្នុង ក្រុងដូនកែវ ខេត្តតាកែវ។

## ខាងក្រោមគឺជារឿងរ៉ាវរបស់ ប៉ាង អ៊ិន

នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការនៅក្នុងសហករណ៍ភូមិតានូ ស្ថិតនៅក្នុងឃុំលាយបូរ ស្រុកត្រាំកក់ តំបន់១៣ ភូមិភាគនិរតី ដោយខ្ញុំត្រូវបាន ចាត់តាំងឲ្យធ្វើការងារនៅកងភ្ជួររាស់។ មួយរយៈក្រោយមក ខ្ញុំត្រូវបានប្រធានកងជ្រើសរើសឲ្យទៅកាប់គាស់គល់ឈើដើម្បីរានដីដាំដំណាំ នៅភ្នំដំរីមៀលក្រោមការគ្រប់គ្រងរបស់ តាចាយ ដោយរក្សាទុកប្រពន្ធ និងកូនរបស់ខ្ញុំឲ្យរស់នៅ និងធ្វើការនៅក្នុងសហករណ៍តានូដដែល។ នៅការដ្ឋានការងាររបស់ខ្ញុំ មានមនុស្សជាច្រើនបានស្លាប់ដោយសារការងារធ្ងន់ធ្ងរ គ្មានអាហារហូបគ្រប់គ្រាន់ និងការយកទៅសម្លាប់ចោល។ ខ្ញុំរស់នៅ និងធ្វើការនៅភ្នំដំរីរមៀលរយៈពេលបីខែ ទើបត្រឡប់មកភូមិវិញ។ ប្រពន្ធ និងបងប្អូនរបស់ខ្ញុំមានភ្ញាក់ផ្អើល និងត្រេកអរយ៉ាងខ្លាំង ព្រោះមិននឹកស្មានថាខ្ញុំនៅរស់មានជីវិត។ នៅពេលនោះខ្ញុំ និងប្រជាជននៅក្នុងភូមិមានការខ្វះខាតអាហារយ៉ាងខ្លាំង។ ខ្ញុំនៅចាំបានថា នៅថ្ងៃមួយប្រធានកងភ្ជួរបានចាត់តាំងខ្ញុំ និងបុរសបីនាក់ទៀតឲ្យទៅភ្ជួរស្រែមួយកន្លែងដែលមានទីតាំងស្ថិតនៅក្បែររោងបាយសហករណ៍រួម។ ដោយសារតែហេវហត់ និងអស់កម្លាំងខ្លាំងពេក នៅវេលាម៉ោង១២យប់ ខ្ញុំក៏បានទៅលួចដួសស្ករត្នោតរាវៗនៅរោងបាយរួមយកមកផឹកអស់បីផ្តិល។ ខ្ញុំមិននិយាយរឿងនេះប្រាប់ទៅអ្នកដែលធ្វើនៅក្នុងកងភ្ជួរជាមួយខ្ញុំ ក្រុមគ្រួសារ និងប្រជាជននៅក្នុងភូមិឡើយ ព្រោះខ្ញុំគិតថាជារឿងអាម៉ាស់ និងខ្មាស់អៀនរបស់ខ្ញុំ។ ខ្ញុំទើបតែនិយាយរឿងលួចស្ករនៅពេលនេះប៉ុណ្ណោះ។ ក្រោយមក ខ្ញុំក៏ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការនៅកងត្រួតពិនិត្យមើលទឹក និងទំនប់នៅសហករណ៍



តានូ។ នៅថ្ងៃមួយ វេលាម៉ោងប្រហែលជាង១១យប់ មានទឹកហូរយ៉ាងខ្លាំងមកពីស្ទឹងស្លាគូធ្វើឲ្យបាក់ទំនប់ទឹកនៅក្នុងសហករណ៍តានូ ភ្លាមនោះប្រធានភូមិក៏បានមកហៅខ្ញុំឲ្យចេញទៅទប់ទំនប់។ ប្រពន្ធរបស់ខ្ញុំបានយំរហូតហើមភ្នែកទាំងសងខាង ព្រោះនាងគិតថា ប្រាកដជាប្រធានភូមិហៅខ្ញុំយកទៅសម្លាប់មិនខាន។ ប៉ុន្តែខ្ញុំមានសំណាងណាស់ ព្រោះបន្ទាប់ពីទប់ទំនប់

ទឹករួច ខ្ញុំត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់មកផ្ទះវិញ។ ក្រោយមក ប្រធានកងក៏បានដកខ្ញុំមកនៅកងសេដ្ឋកិច្ចវិញ ដោយខ្ញុំត្រូវដើររកបន្លែ ត្រី និងសាច់សម្រាប់ផ្គត់ផ្គង់រោងបាយសហករណ៍រួមៗ ពេលនោះ ខ្ញុំទទួលបានរបបអាហារហូបប្រសើរជាងមុនៗ

ក្រៅពីធ្វើការងារប្រចាំថ្ងៃ រៀងរាល់បីខែម្តងខ្មែរក្រហមក៏មានការរៀបចំសម្តែងល្ខោន និងសិល្បៈឲ្យប្រជាជននៅតាមសហករណ៍ ភូមិ ឃុំ ស្រុក និងតំបន់របស់ខ្ញុំ ទស្សនាដែរ



ដូចជា ការសម្តែងល្ខោននៅទំនប់ស្វាគូៗ ល្ខោនភាគច្រើនគឺសម្តែងអំពីការតស៊ូ ការលះបង់និងការខិតខំប្រឹងប្រែងធ្វើការរបស់ប្រជាជនៗ ប៉ុន្តែទោះបីយ៉ាងក៏ដោយ ក៏ខ្ញុំមិនដែលបានចូលរួមទស្សនាការសម្តែងល្ខោន និងសិល្បៈទាំងនោះដែរៗ អ្នកដែលអាចទៅទស្សនាការសម្តែងល្ខោន លុះត្រាតែអ្នកនោះមានការអញ្ជើញពីថ្នាក់លើ និងអ្នកដែលមានតួនាទីនៅក្នុងបដិវត្តន៍ ដូចជា ប្រធានក្រុម ប្រធានកងពិសេស ប្រធានសហករណ៍ ប្រធានភូមិ និងប្រធានឃុំជាដើមៗ ខ្ញុំបានឮសាច់រឿងល្ខោន និងសិល្បៈទាំងនោះតាមរយៈអ្នកដែលបានទៅចូលរួមទស្សនានិយាយប្រាប់ បន្ទាប់ពីអ្នកទាំងនោះត្រឡប់មកដល់សហករណ៍វិញៗ ចំណែកខ្ញុំបានត្រឹមតែស្តាប់ចម្រៀងបដិវត្តន៍ខ្មែរក្រហម ដែលតែងតែចាក់នៅតាមការដ្ឋានការងារប៉ុណ្ណោះ ហើយចម្រៀងភាគច្រើនគឺជំរុញទឹកចិត្តប្រជាជនឲ្យខិតខំប្រឹងប្រែងធ្វើការដើម្បីបម្រើអង្គការបដិវត្តន៍ៗ ដូច្នេះនៅថ្ងៃស្អែក ខ្ញុំក៏ចង់ចូលរួមទស្សនាការសម្តែងល្ខោននិយាយដែលមានចំណងជើងថា «ទម្លាយភាពស្ងៀមស្ងាត់» ទាក់ទងនឹងរបបខ្មែរក្រហមដែរៗ

## ការចេញទៅទស្សនាការសម្តែង

នៅសៀលថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ អ៊ិន បានដឹកនាំប្រជាជនប្រមាណ៩នាក់ នៅក្នុងភូមិអូរស្វាយចេក ដោយខ្លះធ្វើដំណើរតាមម៉ូតូ និងខ្លះទៀតធ្វើដំណើរតាមរ៉ឺម៉ក ទៅទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នៅសាលប្រជុំមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវៗ ប្រជា-ជននៅក្នុងភូមិអូរស្វាយចេក ដែលទៅចូលរួមទស្សនាល្ខោននិយាយជាមួយ អ៊ិន នៅថ្ងៃនោះ គឺមានអាយុច្រើន និងធ្លាប់បានដឹងរឿងរ៉ាវពីរបបខ្មែរក្រហមៗ

## ចំណាប់អារម្មណ៍របស់ អ៊ិន

បន្ទាប់ពីបានទស្សនាល្ខោននិយាយទម្លាយស្ងៀមស្ងាត់រួចមក ខ្ញុំយល់បានថា សាច់រឿងនៅក្នុងល្ខោននេះ គឺដកស្រង់ចេញ ពីរឿងរ៉ាវរបស់ប្រជាជនដែលរស់នៅក្រោមរបបខ្មែរក្រហម ហើយខ្ញុំក៏ធ្លាប់បានឆ្លងកាត់រឿងរ៉ាវដូច្នេះដែរៗ ពាក្យសម្តីទាំងឡាយដែលប្រើប្រាស់នៅក្នុងល្ខោននិយាយនេះ គឺជាពាក្យដែលខ្ញុំធ្លាប់បានស្តាប់ឮរាល់ថ្ងៃនៅក្នុងរបបខ្មែរក្រហម ដូចជាពាក្យ«អង្គការ» ឬ«សមមិត្ត» ជាដើមៗ ខ្ញុំគិតថាល្ខោននិយាយនេះនឹងធ្វើឲ្យមានការចងចាំពីរបបមួយ (របបខ្មែរក្រហម) ដែលបានបង្ខំឲ្យប្រជាជនធ្វើការធ្ងន់ធ្ងរ និងប្រព្រឹត្តអំពើឃោរឃៅមកលើប្រជាជន ហើយក៏ជាប្រវត្តិសាស្ត្រដែល

ប្រជាជនកម្ពុជាត្រូវយល់ដឹងដែរ។

## ចំណាប់អារម្មណ៍របស់តួសម្តែង

កូវ សុធារី ដែលសម្តែងជាតួអង្គនិស្សិតម្នាក់ដែលធ្លាប់ស្រមៃចង់បានពិភពលោកមួយដែលប្រសើរជាងមុន នៅក្នុងឈុតមួយក្នុងចំណោមឈុតទាំងប្រាំបីនៅក្នុងល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់បានមានប្រសាសន៍ថា ខ្ញុំក៏ជាជនរងគ្រោះម្នាក់ដែរ។ នៅសម័យខ្មែរក្រហមខ្ញុំមានវ័យក្មេងនៅឡើយ ដូច្នេះខ្ញុំមិនទាន់ទទួលរងនូវការឈឺចាប់ច្រើនទេនៅក្នុងអំឡុងពេលនោះ។ នៅពេលខ្ញុំពេញវ័យនៅក្រោយរបបខ្មែរក្រហម និងបានចូលរៀននៅសាលាវិចិត្រសិល្បៈ ហើយបានអានសៀវភៅផ្សេងៗទាក់ទងនឹងរបបខ្មែរក្រហម ទើបធ្វើឲ្យខ្ញុំមានការឈឺចាប់។ ទំហំនៃការឈឺចាប់របស់ខ្ញុំកាន់តែធំឡើងនៅពេលដែលខ្ញុំបានដឹងរឿងរ៉ាវពីរបបខ្មែរក្រហមកាន់តែច្រើនជាពិសេស នៅពេលខ្ញុំហ្វឹកហាត់ការសម្តែងល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់ពីគ្រូជនជាតិហូឡង់។ ដូច្នេះនៅពេលសម្តែងខ្ញុំបានបែងចែករឿងរ៉ាវផ្ទាល់ខ្លួនរបស់ខ្ញុំនិងសាច់រឿងសម្តែងនៅក្នុងល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់នេះ។ ទោះបីយ៉ាងណា មានឈុតមួយដែលនិយាយពីឈ្មោះ សារុន ដែលឪពុករបស់នាងត្រូវបានខ្មែរក្រហមសម្លាប់ បានប៉ះពាល់ដល់អារម្មណ៍របស់ខ្ញុំយ៉ាងខ្លាំង។ ឪពុករបស់ខ្ញុំគឺជាទាហាន លន់ នល់ ដែលឈរជើងនៅខេត្តកំពង់ឆ្នាំង។ ឪពុករបស់ខ្ញុំបានមកជួបម្តាយខ្ញុំនៅភ្នំពេញតែប៉ុន្មានខែតែប៉ុណ្ណោះ មុនពេលខ្មែរក្រហមឡើងកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ បន្ទាប់ពីឪពុករបស់ខ្ញុំបានត្រឡប់ទៅខេត្តកំពង់ឆ្នាំងវិញ គាត់បានបាត់ដំណឹងរហូត។ ចំណែកម្តាយខ្ញុំ និងកូនៗត្រូវបានខ្មែរក្រហមជម្លៀសមកខេត្តតាកែវ។ ខ្ញុំគិតថាឪពុករបស់ខ្ញុំប្រាកដជាខ្មែរក្រហមយកទៅសម្លាប់ព្រោះគាត់គឺជាទាហាន លន់ នល់។ រឿងរ៉ាវរបស់ឪពុកខ្ញុំបានអន្ទោលតាមខ្ញុំជាប់ជានិច្ច។

សោម ប៊ុនថន



រូបទីពីររាប់ពីស្តាំ ៖ ប៉ាង អន មកទស្សនាល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់ (រូបថត ៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការរំឭកឡើងវិញពីអនុស្សាវរីយ៍អតីតកាល តាមរយៈ ការទស្សនាល្ខោន «ចម្ងាយភាពស្ងៀមស្ងាត់» នៅខេត្តតាកែវ

*«រូបភាពនៃសេចក្តីទុក្ខព្រួយ និងការនឹករឭកជាច្រើន បានចាប់ផ្តើមផុសឡើងនៅចំពោះមុខ បន្ទាប់ពីខ្ញុំបានទស្សនាការសម្តែងល្ខោន «ចម្ងាយភាពស្ងៀមស្ងាត់»ដែលសម្តែងពីរឿងរ៉ាវនៃរបបខ្មែរក្រហមនៅថ្ងៃនេះ»។*

*នៅលើគ្រែឈើក្នុងខ្ទមតូចមួយស្ត្រីម្នាក់ឈ្មោះ ហ៊ឹម ខេង អាយុ៦៨ឆ្នាំ បានរៀបរាប់ពីរឿងរ៉ាវដែលគាត់បានជួបប្រទះ និងការចងចាំដែលបានដក់ជាប់យ៉ាងជ្រៅនៅក្នុងជីវិតរបស់គាត់ថា ៖*

*«កែវភ្នែកមួយគូរបស់ប្អូនប្រុសខ្ញុំនៅតែបន្តរស់នៅក្នុងភ្នែករបស់ខ្ញុំជានិច្ច ទោះបីជាខ្មែរក្រហមបានយកប្អូនខ្ញុំទៅសម្លាប់ក៏ដោយ»។ រសៀលថ្ងៃមួយនារដូវប្រាំង ខ្ញុំកំពុងតែរែកដីដំបូកស្ថិតនៅចម្ងាយប្រហែល១០០ម៉ែត្រពីកន្លែងដែលប្អូនប្រុសរបស់ខ្ញុំធ្វើការ។ កងឈ្លបដែលមានវ័យក្មេង និងមាឌតូចៗចំនួន២នាក់ ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ បានចាប់ទាញដៃប្អូនប្រុសរបស់ខ្ញុំចងព័ទ្ធទៅក្រោយយ៉ាងកំរោល។ ខ្ញុំបានឃើញពីហេតុការណ៍ទាំងនោះយ៉ាងច្បាស់ ទន្ទឹមពេលដែលប្រជាជនគ្រប់គ្នាខ្លាចរអាមិនហ៊ានក្រឡេកមើល ហើយឱនមុខចុះ ដោយដៃទាំងពីរខិតខំធ្វើការផារយ៉ាងញាប់ស្អេក ព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់។ កងឈ្លបបានបណ្តើរប្អូនប្រុសរបស់ខ្ញុំចេញទៅ ថែមទាំងវាយដូចដេញសត្វគោឲ្យចូលក្នុងនឹមនង្គ័ល។ ប្អូនខ្ញុំបានក្រឡេកមើលមកខ្ញុំដែលកំពុងតែធ្វើការនៅតាមផ្លូវនោះជាមួយកែវភ្នែកទាំងគូរបស់វាដែលហាក់បីដូចជាកំពុងតែប្រាប់ខ្ញុំថាលារហូតហើយ។ ខ្ញុំនៅតែមិនទាន់អាចស្វែងរកចម្លើយឲ្យត្រូវទៅនឹងអត្ថន័យនៃកែវភ្នែករបស់យើងទាំងពីរ។ កែវភ្នែករបស់យើង ហាក់បីដូចជាការសម្លឹងមើលគ្នាក្នុងអត្ថន័យនៃការលាគ្នា ការជូនពរគ្នា សេចក្តីស្រឡាញ់ ក្តីបារម្ភណ៍ ដែលពោរពេញទៅដោយសេចក្តីក្រៀមក្រំបំផុត។ ខ្ញុំមិនហ៊ានសម្លឹងមើលប្អូនប្រុសរបស់ខ្ញុំយូរនោះទេ។ មិនយូរប៉ុន្មាន ប្អូនប្រុសរបស់ខ្ញុំនិងកងឈ្លប ក៏បានបាំងបាត់ដោយព្រៃគុម្ពោតដែលដុះនៅតាមផ្លូវ។*

*ការសម្តែងរឿងល្ខោន«ចម្ងាយភាពស្ងៀមស្ងាត់»ក៏បានរំឭកខ្ញុំពីការចូលមកដល់នៃរបបខ្មែរក្រហមដែរ។ ថ្ងៃមួយនៅពេលដែលខ្ញុំកំពុងតែដាំបាយនៅក្នុងចង្ក្រាន សូរកាំភ្លើងបានលាន់ឮឡើងយ៉ាងខ្លាំង។ ខ្ញុំនឹងក្រុមគ្រួសារ បានរត់ចូលទៅក្នុងលេណដ្ឋានដែលយើងបានធ្វើបម្រុងទុករួចជាស្រេច ព្រោះយើងដឹងថា ស្ថានការណ៍នៅក្នុងប្រទេសមិនប្រក្រតី។*



*ហ៊ឹម ខេង កំពុងរៀបរាប់ពីរឿងរ៉ាវដែលគាត់បានជួបប្រទះក្នុងរបបខ្មែរក្រហម កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

គ្រួសារនីមួយៗ បានប្រមូលសមាជិកគ្រួសាររបស់ខ្លួនរត់សំដៅចូលទៅក្នុងលេណដ្ឋានរៀងៗខ្លួន ដើម្បីគេចវេះចេញពីស្ថានភាពដ៏គ្រោះថ្នាក់នោះ។ គ្រាប់កាំភ្លើងបានធ្លាក់ចុះមកលើផ្ទៃដីដូចដំណក់ទឹកភ្លៀងដែលកំពុងតែធ្លាក់ចុះ ដើម្បីស្រោចស្រង់ជីវិតឲ្យរស់ឡើងវិញ ប៉ុន្តែផ្ទុយទៅវិញ វាបានបំផ្លាញផ្ទះសម្បែងរបស់ប្រជាជននិងដើមឈើឆេះខ្ទេចខ្ទី។ ស្ថានការណ៍ប្រយុទ្ធគ្នាកាន់តែខ្លាំងទៅៗ ខ្ញុំនិងក្រុមគ្រួសារបានរត់ភៀសខ្លួនទៅភូមិចក ស្ថិតក្នុងខេត្តតាកែវ ដើម្បីគេចចេញពីគ្រាប់ផ្លោងទាំងនោះ។ នៅក្រោមកំដៅព្រះអាទិត្យដ៏សែនក្តៅហែងផ្លូវថ្នល់ហុយទ្រលោម ខ្ញុំប្តីរបស់ខ្ញុំ និងកូនស្រី២នាក់របស់ប្តីខ្ញុំ ជាមួយប្រពន្ធដើមរបស់គាត់បានធ្វើដំណើរទៅកាន់វត្តចម្ប៉ា។ ប្តីរបស់ខ្ញុំបររទេះគោដោយមានផ្ទុកអីវ៉ាន់ដូចជា ភួយ មុង សម្ភារប្រើប្រាស់ ព្រមទាំងស្បៀងអាហារ។ ចំណែកខ្ញុំបានធ្វើដំណើរដោយថ្មើរជើង រែកអីវ៉ាន់ដែលដាក់នៅក្នុងសង្រែកពីខាងលើស្មាទាំងសងខាង ជាមួយកូនដំបូងជាទីស្រឡាញ់របស់ខ្ញុំនៅក្នុងផ្ទៃពោះដែលមានអាយុត្រឹមតែ៤ខែតែប៉ុណ្ណោះ។ នៅតាមផ្លូវ ខ្មែរក្រហមបានឃាត់និងហៅប្តីខ្ញុំទៅសួរព្រោះ គាត់មានសម្បុរសក្បុសនិងមានមុខមាត់ស្រដៀងនឹងជនជាតិចិន។ នៅពេលនោះ ខ្ញុំពិតជាតក់ស្លុតខ្លាំងណាស់ ព្រោះក្នុងចិត្តរបស់ខ្ញុំគិតថា ខ្មែរក្រហមនឹងចាប់យកប្តីខ្ញុំទៅសម្លាប់ ប៉ុន្តែសំណាងល្អ ប្តីខ្ញុំត្រូវបានអនុញ្ញាតឲ្យត្រឡប់មកវិញ។ យើងបានធ្វើដំណើរមកដល់វត្តចម្ប៉ា និងបានស្នាក់នៅខាងជើងវត្តនោះអស់រយៈពេលប្រហែល១០ថ្ងៃ។ នៅពេលខ្វះខាតអាហារសម្រាប់បរិភោគក្នុងគ្រួសារ ខ្ញុំបានយកសម្ភារមានតម្លៃទៅដូរយកគោនិងអង្កររបស់ប្រជាជនមកហូប។ ប្រជាជនជាច្រើនទៀតដែលរស់នៅក្បែរវត្តចម្ប៉ា ក៏ធ្វើដូចគ្រួសារខ្ញុំដែរ។ ក្រោយមក ខ្មែរក្រហម ក៏បានប្រាប់ឲ្យប្រជាជនទាំងអស់ធ្វើដំណើរទៅកាន់ភូមិត្រពាំងអំពិលវិញម្តង។ នៅពេលដែលខ្ញុំនិងក្រុមគ្រួសារទៅដល់ទីនោះដំបូង ខ្មែរក្រហមមិនទាន់រៀបចំឲ្យយើងរស់នៅជាសហករណ៍នោះទេ។ យើងធ្វើការងាររួមដាក់ផលប្រយោជន៍ដែលយើងទទួលបានជារួម ប៉ុន្តែយើងបរិភោគអាហារនៅតាមផ្ទះដោយខ្មែរក្រហមបានចែកអង្ករឲ្យតាមគ្រួសារនីមួយៗ។ ខ្ញុំនិងប្តីតែងតែស្វែងរកម្ហូបអាហារនៅក្បែរផ្ទះ។ ខ្ញុំ និងប្រជាជនដទៃទៀតរស់នៅដោយមិនបានដឹងថាខ្មែរក្រហមមានគោលបំណងធ្វើអ្វីឲ្យពិតប្រាកដនោះទេ។

ក្រោយមក ខ្មែរក្រហមបានឲ្យខ្ញុំនិងក្រុមគ្រួសារផ្លាស់ទៅរស់នៅក្នុងភូមិត្រពាំងគូវិញ។ ជីវិតរស់នៅក្នុងភូមិត្រពាំងគូ គឺជាជីវិតមួយមានអនុស្សាវរីយ៍ដ៏ជូរចត់ជាច្រើនបានកើតឡើងចំពោះក្រុមគ្រួសាររបស់ខ្ញុំ។ មកដល់ភូមិត្រពាំងគូ ខ្មែរក្រហមបានរៀបចំឲ្យប្រជាជនទាំងអស់រស់នៅជាសហករណ៍ គឺធ្វើការងាររួម ហូបរួម និងរក្សាផលប្រយោជន៍រួម។ ខ្ញុំទទួលបានអាហារត្រឹមតែបបរលាយព្រលិត១វែកប៉ុណ្ណោះក្នុងមួយពេល។ នៅពេលនោះ ខ្ញុំឃ្លានខ្លាំងណាស់ ក៏បានលួចគាស់ដំឡូងដែលខ្ញុំដាំជិតផ្ទះយកមកដាក់ស្ងោរនៅក្នុងកំសៀវ



ទិដ្ឋភាពវាលស្រែ ស្ថិតនៅសង្កាត់រការក្នុង ក្រុងដូនកែវ ខេ

ដាំទឹករបស់ខ្ញុំ។ ដោយសារតែភាពស្រេកឃ្លាននិងចង់រក្សាជីវិតកូនក្នុងផ្ទៃពោះ បានធ្វើឲ្យខ្ញុំហ៊ានលួចដោយគ្មានខ្លាចញញើតនឹងសេចក្តីស្លាប់ទេ។ មិនយូរប៉ុន្មាន ខ្ញុំបានបង្កើតកូនស្រីដ៏ស្រស់ស្អាតម្នាក់ ហើយខ្ញុំបានដាក់ឈ្មោះឲ្យថា ស្រីហាច។ មុនពេលសម្រាល ខ្ញុំបានចាប់ផ្តើមឈឺនៅក្នុងផ្ទៃពោះយ៉ាងខ្លាំង ថែមទាំងកូនខ្ញុំបានរើបម្រាស់នៅក្នុងផ្ទៃពោះមិនឈប់សោះ។ ឆ្មបម្នាក់ឈ្មោះ យាយបាន បានជួយសង្គ្រោះជីវិតខ្ញុំនិងកូនស្រីរបស់ខ្ញុំ បានយ៉ាងសុខសប្បាយ។ បន្ទាប់ពីសម្រាលកូនរួច ខ្ញុំបានផ្អើរភ្លើងដោយប្រើតែគាវត្នោត និងគ្មានអាហារហូបគ្រប់គ្រាន់នោះទេ។ ខ្ញុំហូបតែបបរលាយព្រលឹត និងហូបតែបន្លែផ្សេងៗ ដែលអង្គការបានចែកឲ្យ ហើយបន្ទាប់មក ពោះរបស់ខ្ញុំចាប់ផ្តើមហើមធំដូចអ្នកដែលមានជំងឺទាចទឹក។ ខ្លួនប្រាណនិងមុខរបស់ខ្ញុំបានហើមដូចជាមនុស្សធាត់។ បន្ទាប់ពីសម្រាលកូនបានរយៈពេលប្រហែល


...ត្តតាកែវ (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

៣ខែ អង្គការបានឲ្យខ្ញុំទៅបុកអង្ករនិងកិនស្រូវជាមួយនារីដ៏ទៃទៀត ដែលទើបតែសម្រាលកូនចំនួនប្រហែល១០នាក់។ ខ្ញុំខិតខំធ្វើការងារមិនហ៊ានឈប់សម្រាកទេ ទោះបីជាខ្ញុំឈឺដៃជើងនិងឈឺឆ្អឹងឆ្អែងយ៉ាងណាក៏ដោយ។ កូនស្រីច្បងរបស់ប្តីខ្ញុំបានទៅធ្វើការនៅក្នុងកងកុមារ ចំណែកឯកូនស្រីទី២ នៅមើលថែរក្សាកូនរបស់ខ្ញុំនៅផ្ទះ។ រីឯប្តីខ្ញុំវិញ បានទៅធ្វើការនៅក្នុងកងជាមួយអ្នកមូលដ្ឋាន ដូចជាធ្វើស្ពាន ឡើងត្នោតរកត្រី ជាដើម។ គាត់ខិតខំប្រឹងប្រែងយកចិត្តរបស់ក្រុមខ្មែរក្រហមទាំងនោះណាស់ ដោយបានខិតខំធ្វើការងារបន្ថែមទៀតដូចជា ធ្វើដែកកេះ កាត់សក់ឲ្យប្រធានភូមិ គឺដើម្បីតែរក្សាជីវិតរស់។ មិនយូរប៉ុន្មាន កូនស្រីរបស់ខ្ញុំ បានស្លាប់នៅក្នុងមន្ទីរពេទ្យដោយសារកើតជំងឺកញ្ជ្រឹល ហើយក្រោយមកខ្ញុំក៏បានពពោះកូនប្រុសម្នាក់ទៀត។ នៅក្នុងរបបខ្មែរក្រហមសមាជិកក្រុមគ្រួសាររបស់ខ្ញុំ ត្រូវជម្លៀសទៅកាន់ទីកន្លែងផ្សេងៗគ្នាទាំងអស់។ រៀងរាល់យប់ ខ្ញុំបានឮស្នូរជើងរបស់មនុស្សដើរលបថ្មមៗនៅជុំវិញខ្ទមរបស់ខ្ញុំ។ ខ្ញុំនិងប្តី មិនហ៊ាននិយាយគ្នាទេ គឺយើងព្យាយាមបិទភ្នែក និងបន់ស្រន់សុំឲ្យព្រះអាទិត្យរះឡើងឲ្យឆាប់ៗ។ ប្រជាជនរស់នៅក្បែរផ្ទះខ្ញុំ ត្រូវបានខ្មែរក្រហមនាំយកទៅស្ទើរតែរៀងរាល់យប់ និងមិនដែលឃើញវិលត្រឡប់មកវិញនោះទេ។ ការរះឡើងនៃព្រះអាទិត្យគឺជាជីវិតនិងក្តីសង្ឃឹមថ្មីរបស់ក្រុមគ្រួសារខ្ញុំ។ នៅពេលមេឃភ្លឺឡើង ខ្ញុំ និងប្តីក៏បំបែកគ្នាទៅធ្វើការងាររៀងៗខ្លួន។ បន្ទាប់ពីក្រុមនារីបុកអង្ករបានគ្រប់គ្រាន់សម្រាប់តម្រូវការ ខ្មែរក្រហមបានប្រើខ្ញុំឲ្យទៅរែកដីដំបូក។ ពេលនោះហើយ ដែលប្អូនប្រុសជាទីស្រឡាញ់របស់ខ្ញុំត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ដោយសារតែគាត់គឺជាអតីតទាហាន លន់ នល់ ដែលត្រូវបានខ្មែរក្រហមជម្លៀសចេញមកពីទីក្រុងភ្នំពេញ។

នៅចុងឆ្នាំ១៩៧៩ ខ្មែរក្រហមបានបញ្ជូនក្រុមគ្រួសាររបស់ខ្ញុំឲ្យវិលត្រឡប់មករស់នៅភូមិត្រពាំងអំពិលម្តងទៀត។ ប្រជាជនដែលបានវិលត្រឡប់មកភូមិត្រពាំងអំពិល ភាគច្រើន គឺជាការវិលត្រឡប់មករកសេចក្តីស្លាប់។ នៅពេលមក

ដល់ក្នុងភូមិ ខ្មែរក្រហមបានឲ្យគ្រួសារនីមួយៗធ្វើនំបញ្ចុក ហូបឲ្យឆ្អែតនៅតាមគ្រួសាររបស់ខ្លួនៗ ក្រោយមក ខ្ញុំបានឮតៗគ្នាថា ប្រជាជនដែលបានធ្វើនំបញ្ចុកហូបរួច គឺត្រូវខ្មែរក្រហមយកទៅសម្លាប់ៗ គ្រួសារខ្ញុំពិតជាសំណាងល្អខ្លាំងណាស់ ព្រោះនៅថ្ងៃដែលក្រុមគ្រួសាររបស់ខ្ញុំធ្វើនំបញ្ចុក គឺជាថ្ងៃដែលកងទ័ពវៀតណាម បានចូលមកដល់ប្រទេសកម្ពុជាៗ នៅពេលនោះ ខ្មែរក្រហមបានរត់គៀសខ្លួនចេញពីភូមិ ថែមទាំងបានកេណ្ឌប្រជាជនរត់ទៅជាមួយដែរៗ ខ្ញុំ និងក្រុមគ្រួសារបានជួបជាមួយកងទ័ពវៀតណាមចំនួន ២នាក់ ហើយកងទ័ពវៀតណាម បានឲ្យខ្ញុំធ្វើដំណើរមកកាន់ភូមិកំណើតរបស់ខ្ញុំវិញៗ ចុងក្រោយ ក្រុមគ្រួសាររបស់ខ្ញុំបានរួចផុតពីការសម្លាប់របស់ខ្មែរក្រហម ប៉ុន្តែប្អូនប្រុស ឪពុក និងក្មួយរបស់ខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់បាត់ទៅហើយៗ

ខ្ញុំបានវិលត្រឡប់មកភូមិកំណើត និងកសាងក្រុមគ្រួសារខ្ញុំឡើងវិញ ដោយមានតែរទេះគោ១និងកូន៣នាក់ៗ យើងបានសាងសង់ផ្ទះខ្ទមតូចមួយ នៅចំកណ្ដាលភូមិដែលគ្មានមនុស្សរស់នៅទាល់តែសោះៗ ក្រោយមក ខ្ញុំមានកូនចំនួន១០នាក់បន្ថែមទៀត ប៉ុន្តែរហូតដល់បច្ចុប្បន្ននេះ កូនរបស់ខ្ញុំនៅរស់រានមានជីវិតត្រឹមតែ៧នាក់តែប៉ុណ្ណោះ គឺប្រុស ៣នាក់ និងស្រី៤នាក់ៗ

នឹកឃើញដល់របបខ្មែរក្រហម ខ្ញុំ ពិតជានៅតែខឹងនឹងរបបនេះណាស់ ព្រោះរបបខ្មែរក្រហម បានធ្វើឲ្យប្រជាជនខ្មែរទទួលរងទុក្ខវេទនាយ៉ាងខ្លាំងៗ ខ្ញុំនៅតែនឹកឃើញដល់ប្អូនប្រុសដែលគួរឲ្យអាណិតរបស់ខ្ញុំៗ ខ្ញុំនៅតែខឹងនឹងខ្មែរក្រហមដែលបានសម្លាប់សាច់ញាតិរបស់ខ្ញុំៗ ខ្ញុំក៏នៅតែនឹកឃើញ ខឹង និងចងកំហឹងជាប់រហូតដល់សព្វថ្ងៃនេះៗ ម្ដាយចុងរបស់ខ្ញុំបានប្រាប់ខ្ញុំថា ឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមយកទៅវាយសម្លាប់យ៉ាងវេទនាបំផុតៗ

ទោះបីរបបខ្មែរក្រហម បានកន្លងផុតអស់រយៈពេលប្រហែល៤០ឆ្នាំយ៉ាងណាក៏ដោយ ក៏របបនេះនៅតែជាការចងចាំរបស់ប្រជាជនដែលនៅរស់រានមានជីវិតនិងជាមេរៀនមួយដែលក្មេងៗជំនាន់ក្រោយកំពុងតែសិក្សាស្វែងយល់នៅក្នុងសាលា នៅតាមផ្ទះ ក៏ដូចជាតាមរយៈការស្វែងយល់តាមការទស្សនាការសម្ដែងល្ខោន «ទម្លាយភាពស្ងៀមស្ងាត់» នេះដែរៗ

## វត្តមានរបស់ល្ខោន «ទម្លាយភាពស្ងៀមស្ងាត់» ក្នុងខេត្តតាកែវ ភូមិភាគនិរតីនៃប្រទេសកម្ពុជា

បន្ទាប់ពីអវត្តមានរបស់ល្ខោន «ទម្លាយភាពស្ងៀមស្ងាត់» នៅលើទឹកដីនៃខេត្តតាកែវដែលស្ថិតក្នុងភូមិភាគនិរតីនៃប្រទេសកម្ពុជាអស់រយៈពេលប្រហែល ១១ឆ្នាំកន្លងទៅ ល្ខោននេះបានវិលត្រឡប់មកវិញសារជាថ្មីម្ដងទៀតជាមួយនឹងការបន្ថែមឈុតឆាកថ្មីចំនួន១ឈុត ដែលឈុតឆាកនេះបាននាំយកនូវដំណោះស្រាយ ការអប់រំដើម្បីការផ្សះផ្សាសម្រាប់ជនរងគ្រោះ និងជនដៃដល់ ថែមទាំងការផ្ដល់ឲ្យនូវចំណេះដឹងដល់ក្មេងៗជំនាន់ក្រោយៗ

នៅក្នុងបន្ទប់ដ៏ធំមួយនៃសាលាគរុកោសល្យភូមិភាគតាកែវ សិស្ស គរុសិស្ស មន្ត្រីរាជរដ្ឋាភិបាល អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនិងក្មេងៗជំនាន់ក្រោយប្រមាណជាង ៥០០នាក់ បានមកចូលរួមទស្សនាល្ខោននេះៗ ឈុតឆាកនីមួយៗ បានធ្វើឲ្យអ្នកទស្សនាមានទឹកមុខក្រៀមក្រំ ថែមទាំងលាយឡំជាមួយនឹងសំណើចក្អាកក្អាយដែលកើតឡើងដោយភាពក្រមិចក្រមើមតាមរយៈការសម្ដែងរបស់តួអង្គសត្វស្វាៗ ខាងក្រោមនេះគឺជាទស្សនយល់ឃើញរបស់គរុសិស្ស និងអ្នកតួអង្គសម្ដែងផ្ទាល់ចំពោះការសម្ដែងរឿងល្ខោន «ទម្លាយភាពស្ងៀមស្ងាត់» នៅក្នុងខេត្តតាកែវ ៖

១) ឈួន ឆាយ អាយុ២២ ឆ្នាំ គឺជាគរុសិស្សឆ្នាំទី១ ឯកទេសប្រវត្តិវិទ្យានិងភូមិវិទ្យា កំពុងសិក្សានៅសាលាគរុកោសល្យភូមិភាគតាកែវ ដែលមានស្រុកកំណើតនៅក្នុងខេត្តបន្ទាយមានជ័យៗ ឆាយ និយាយថា ៖

ម្ដាយឪពុករបស់ខ្ញុំ ធ្លាប់បាននិយាយរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមជាច្រើនប្រាប់ដល់ខ្ញុំៗ នៅក្នុងរបបខ្មែរក្រហម ម្ដាយឪពុករបស់ខ្ញុំគឺស្ថិតក្នុងវ័យកុមារ

*ភាព និងបានធ្វើការក្នុងកងកុមារ។ រឿងរ៉ាវភាគច្រើនដែលគាត់បាននិយាយប្រាប់ដល់ខ្ញុំគឺការបង្ខិតបង្ខំឲ្យគាត់ធ្វើការងារហួសកម្លាំង និងកង្វះអាហារ។ ជីតារបស់ខ្ញុំក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់ព្រោះគាត់គឺជាអតីតគ្រូបង្រៀននៅក្នុងរបបលន់ នល់។*

*ចំពោះខ្ញុំការសម្តែងល្ខោន «ទម្លាយភាពស្ងៀមស្ងាត់» គឺជាវិធីសាស្ត្រអប់រំអំពីរបបខ្មែរក្រហមដ៏ប្លែកមួយ អាចឲ្យខ្ញុំយល់ដឹងកាន់តែច្បាស់អំពីរឿងរ៉ាវដែលបានកើតឡើង ការស្វែងយល់បន្ថែមពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការគិតរបស់ក្មេងៗជំនាន់ក្រោយចំពោះរបបខ្មែរក្រហម។ ល្ខោននេះ នឹងផ្តល់ឲ្យខ្ញុំនូវវិធីសាស្ត្រនៃការបង្រៀនសិស្ស នាពេលអនាគត ព្រោះការបង្រៀនតម្រូវឲ្យខ្ញុំចាំបាច់ត្រូវតែផ្តោតអារម្មណ៍ដូចជាការទស្សនាល្ខោននេះដែរ។ ខ្ញុំសំណូមពរឲ្យមានការសម្តែងល្ខោន «ទម្លាយភាពស្ងៀមស្ងាត់» នេះ នៅតាមតំបន់ដាច់ស្រយាលបន្ថែមទៀត។*

២) យិន វុត្ថា គឺជាតួអង្គអ្នកច្រៀងនៅក្នុងការសម្តែងល្ខោន «ទម្លាយភាពស្ងៀមស្ងាត់» ចាប់តាំងពីពេលដែលល្ខោននេះសម្តែងដំបូងនៅក្នុងឆ្នាំ២០០៨។ សព្វថ្ងៃ វុត្ថា មានអាយុ៤០ឆ្នាំ និងជាបុគ្គលិកនៅក្នុងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ វុត្ថា បានចែករំលែកបទពិសោធន៍របស់គាត់ថា ៖

*ខ្ញុំចូលចិត្តសម្តែងល្ខោន «ទម្លាយភាពស្ងៀមស្ងាត់» នៅតាមខេត្តព្រោះប្រជាជននៅក្នុងខេត្តតាកែវនេះពិតជារួសរាយរាក់ទាក់ណាស់ ថែមទាំងនៅខេត្តតាកែវនេះ មានទេសភាពនិងបរិយាកាសល្អបរិសុទ្ធ។ ការសម្តែងល្ខោននេះបានជួយឲ្យខ្ញុំយល់កាន់តែច្បាស់ ពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ដែលខ្ញុំមិនធ្លាប់បានឆ្លងកាត់។ ការបញ្ចូលឈុតថ្មីនៃល្ខោននេះ បានចូលរួមចំណែកដល់ការផ្សះផ្សាសម្រាប់ជនរងគ្រោះនិងជនដៃដល់ ថែមទាំងជាមេរៀនមួយដែលបានរំឭកដល់ក្មេងៗជំនាន់ក្រោយឲ្យចងចាំនិងចូលរួមទប់ស្កាត់កុំឲ្យរបបនេះកើតឡើងម្តងទៀត។*

*ចំពោះការសម្តែងរបស់ខ្ញុំលើកទី២នេះ គឺមានការរីកចម្រើនជាងលើកទី១ ព្រោះខ្ញុំ បានរៀនសូត្រពីភាពខ្វះខាតដែលបានកើតឡើងពីមុនមកនិងកែតម្រូវសម្រាប់ការសម្តែងបច្ចុប្បន្ននេះ។ បញ្ហាប្រឈមរបស់ខ្ញុំគឺជាបញ្ហាសុខភាពតែប៉ុណ្ណោះ។ ខ្ញុំសង្ឃឹមថា ការសម្តែងថ្ងៃនេះ អាចឲ្យក្មេងៗជំនាន់ក្រោយទទួលបានចំណេះដឹងបន្ថែមអំពីរបបខ្មែរក្រហម ថែមទាំងចូលរួមក្នុងការផ្សះផ្សារវាងជនរងគ្រោះនិងជនដៃដល់នៅក្នុងតំបន់នេះ។ ខ្ញុំក៏សង្ឃឹមដែរថា ការសម្តែងនេះ នឹងអាចឲ្យគរុសិស្សទាំងអស់ទទួលបានចំណេះដឹង ដើម្បីចែករំលែកដល់សិស្សរបស់ខ្លួននាពេលអនាគត។*

៣) ខៀវ សុវណ្ណារិទ្ធ ភេទប្រុស គឺជាតួអង្គអ្នករាំដែលសម្តែងជាសត្វស្វា។ សព្វថ្ងៃនេះ សុវណ្ណារិទ្ធ មានអាយុ ៣៩ឆ្នាំ និងសព្វថ្ងៃគឺជាបុគ្គលិកបម្រើការងារក្នុងនាយកដ្ឋានទស្សនីយភាពនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានចែករំលែកបទពិសោធន៍របស់គាត់ថា៖

*ការសម្តែងល្ខោន «ទម្លាយភាពស្ងៀមស្ងាត់» បានផ្តល់ចំណេះដឹងដល់ខ្ញុំជាច្រើនអំពីរបបខ្មែរក្រហម និងរឿងរ៉ាវដែលប្រជាជនខ្មែរបានប្រឈមមុខ។ នៅពេលដែលខ្ញុំសម្តែងល្ខោននេះហាក់បីដូចជាបាននាំខ្ញុំ ឲ្យចូលទៅរស់នៅក្នុងសម័យខ្មែរក្រហម ដែលខ្ញុំមិនធ្លាប់បានឆ្លងកាត់ពីមុនមក។ ខ្ញុំក៏បានប្រឈមមុខនឹងបញ្ហាខ្លះៗចំពោះការសម្តែងនេះព្រោះខ្ញុំមានវ័យចំណាស់ជាងមុន ហើយកម្លាំងរបស់ខ្ញុំក៏ចុះខ្សោយដែរ ប៉ុន្តែក្បាច់រាំនិងការសម្តែងរបស់ខ្ញុំ មានភាពរស់រវើកជាងមុន។ ខ្ញុំសង្ឃឹមថា ការសម្តែងល្ខោននេះ នឹងចូលរួមចែករំលែកបទពិសោធន៍ និងជាមេរៀនមួយដល់ក្មេងជំនាន់ក្រោយឲ្យចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត និងថែរក្សាការចងចាំនៃប្រវត្តិសាស្ត្រខ្មែរក្រហម សម្រាប់ក្មេងៗជំនាន់ក្រោយទៀត។ ការសម្តែងល្ខោន «ទម្លាយភាពស្ងៀមស្ងាត់» នៅក្នុងខេត្តតាកែវនេះ គឺមានលក្ខណៈខុសប្លែកពីកន្លែងផ្សេងៗ ព្រោះបរិយាកាសនៅទីនេះគឺមានលក្ខណៈស្ងប់ស្ងាត់ ថែមទាំងមានទេសភាពធម្មជាតិដែលបានជួយឲ្យអារម្មណ៍របស់ខ្ញុំបានធូរស្បើយ។*

***អ៊ុន សុដាវី***

# ការផ្សះផ្សារវាងជនរងគ្រោះ និងជនដៃដល់តាមរយៈសិល្បៈ

សិល្បៈ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សាភ្ជាប់ទៅនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។ សិល្បៈ គឺជាវិធីដែលអាចធ្វើឲ្យមនុស្សមានចិត្តសប្បាយរីករាយ រំសាយនូវទុក្ខកង្វល់ ព្រមទាំងជួយឲ្យមនុស្សបានធូស្បើយពីការហត់នឿយ ដោយសារការងារបិញ្ចឹមជីវិតប្រចាំថ្ងៃទៀតផង។ សិល្បៈ ក៏អាចបណ្តុះនូវមនោសញ្ចេតនាការអាណិតអាសូរ ការយោគយល់ សណ្តោសប្រណី និងស្មារតីស្រឡាញ់សន្តិភាពនៅក្នុងសង្គមជាតិដែរ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំឲ្យមាននូវកម្មវិធីសម្តែងសិល្បៈល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នៅតាមទីតាំងនានានៅក្នុងប្រទេសកម្ពុជា។ គោលបំណងនៃសម្តែងល្ខោននិយាយនេះ គឺដើម្បីជំរុញឲ្យមានការផ្សះផ្សានៅក្នុងសង្គម រវាងជនរងគ្រោះ និងជនដៃដល់នៅសម័យខ្មែរក្រហម ដែលនៅរស់រានមានជីវិតមកដល់សព្វថ្ងៃ។ ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» គឺដើម្បីផ្សព្វផ្សាយ និងចែករំលែកនូវបទពិសោធន៍របស់ប្រជាជន និងសោកនាដកម្មដែលធ្លាប់បានកើតឡើងនៅក្នុងប្រទេសកម្ពុជា ទៅកាន់កូនខ្មែរជំនាន់ក្រោយដើម្បីជាការចងចាំ។

ខាងក្រោមនេះ គឺជាចំណាប់អារម្មណ៍របស់ប្រជាជនបន្ទាប់ពីបានចូលរួមទស្សនា ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» នៅសាលប្រជុំនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ នារសៀលថ្ងៃពុធ ទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ៖

១) នង ប៊ុនធឿន ភេទប្រុស អាយុ៥២ឆ្នាំ គ្រូបង្រៀនឯកទេសសិល្បៈ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ បានមានប្រសាសន៍ថា ខ្ញុំមានភាពសប្បាយរីករាយណាស់ នៅពេលបានទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ដែលបានបង្ហាញអំពីការផ្សះផ្សារវាងជនរងគ្រោះ និងជនដៃដល់នៅក្នុងសម័យខ្មែរក្រហម ឲ្យមានការយោគយល់អធ្យាស្រ័យគ្នាដើម្បីឲ្យមានសុខសន្តិភាពនៅក្នុងសង្គម


ផន ឆាវ៉ាត់ រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា


យឹម ក្រូច រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ជាតិទាំងមូល។ ជាពិសេសតាមរយៈឈុតឆាកនៃការសម្តែង បានជួយឲ្យកូនខ្មែរជំនាន់ក្រោយ បានយល់ដឹងអំពីប្រវត្តិសាស្ត្រ នៃទុក្ខលំបាករបស់ប្រជាជនខ្មែរនៅក្នុងសម័យខ្មែរក្រហម និងចេះរួបរួមសាមគ្គី អត់ឱន ស្រឡាញ់ មានចិត្តមេត្តា ដើម្បីជៀសផុតពីកំហុសប្រវត្តិសាស្ត្រ ដែលបានកើតឡើងកន្លងមក។ តាមរយៈល្ខោននិយាយនេះ បានធ្វើឲ្យខ្ញុំនឹកឃើញដល់ពេលដែលឪពុករបស់ខ្ញុំត្រូវបានយោធាខ្មែរក្រហមយកទៅសម្លាប់ ប៉ុន្តែខ្ញុំយល់ថា មានតែការអត់ធ្មត់ ចេះយោគយល់អធ្យាស្រ័យគ្នាប៉ុណ្ណោះ ទើបអាចធ្វើឲ្យខ្ញុំ គ្រួសាររបស់ខ្ញុំ និងប្រជាជនខ្មែរទូទាំងប្រទេសអាចរួមរស់ជាមួយគ្នាបានដោយភាពសុខសាន្ត។ ខ្ញុំសូមសំណូមពរឲ្យមានការរៀបចំកម្មវិធីសម្តែងល្ខោននិយាយ«ទម្លាយភាពស្ងៀមស្ងាត់» នេះនៅតាមទីតាំងផ្សេងៗទៀតដើម្បីឲ្យអ្នកជំនាន់ក្រោយបានដឹងអំពីទុក្ខសោករបស់ប្រជាជនខ្មែរនៅក្នុងរបបដ៏ខ្មៅងងឹតមួយនេះ។

២) ផន ឆារ៉ាត់ ភេទប្រុស អាយុ២៥ឆ្នាំ គឺជាគរុសិស្សឆ្នាំទី១ ជំនាន់ទី២៩ ឯកទេស ប្រវត្តិភូមិ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ។ ឆារ៉ាត់ បានរៀបរាប់ថា ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយណាស់ នៅពេលទទួលដំណឹងថា មានការសម្តែងសិល្បៈល្ខោននិយាយ«ទម្លាយភាពស្ងៀមស្ងាត់» ដែលឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្រនាសម័យខ្មែរក្រហមនៅក្នុងទីតាំងសាលារបស់ខ្ញុំ។ បន្ទាប់ពីខ្ញុំបានទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» រួចមក ខ្ញុំយល់ថាល្ខោននេះមានតម្លៃអប់រំយ៉ាងប្រសើរថ្លៃថ្លា ក្នុងការជួយឲ្យប្រជាជន ដែលជាជនរងគ្រោះនៅក្នុងសម័យខ្មែរក្រហមបានរំសាយទុក្ខព្រួយ បំបាត់កំហឹង និងការគុំគួនចំពោះអ្នកដែលបានប្រព្រឹត្តកំហុសមកលើខ្លួន។ ជាពិសេសតាមរយៈអត្ថន័យនៃល្ខោននិយាយ បានជួយឲ្យមានការផ្សះផ្សាគ្នា ដើម្បីរួមរស់ជាមួយគ្នាដោយសន្តិភាពរវាង ជនរងគ្រោះនៅសម័យខ្មែរក្រហម និងអតីតកម្មាភិបាលខ្មែរក្រហមដែលនៅរស់រានមានជីវិតមកដល់សព្វថ្ងៃ។ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ក៏បានផ្តល់សារសំខាន់ចំពោះកូនខ្មែរជំនាន់ក្រោយឲ្យទទួលបានការសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រ និងយល់ដឹងអំពីទុក្ខលំបាកប្រជាជនខ្មែរ ដែលរស់នៅក្នុងសម័យខ្មែរក្រហម។ ល្ខោននិយាយនេះបានអប់រំកូនខ្មែរឲ្យស្អប់ខ្ពើមអំពើប្រល័យពូជសាសន៍ ចេះយោគយល់អធ្យាស្រ័យ មានគំនិតរួបរួមសាមគ្គីគ្នា គោរពសិទ្ធិមនុស្ស ដើម្បីធ្វើឲ្យប្រទេសជាតិមានការអភិវឌ្ឍន៍ និងរស់នៅជាមួយគ្នាប្រកបទៅដោយសុខសន្តិភាព។

៣) យឹម គ្រូច ភេទប្រុស អាយុ២៣ឆ្នាំ គឺជាគរុសិស្សឆ្នាំទី១ ជំនាន់ទី២៩ ឯកទេស ប្រវត្តិភូមិ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ បានរៀបរាប់ថា បន្ទាប់ពីបានទស្សនាល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» រួចមក ខ្ញុំយល់ថាល្ខោននេះមានសារសំខាន់ណាស់ក្នុងការផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រខ្មែរក្នុងសម័យកាលដ៏គួរឲ្យរន្ធត់ដល់មនុស្សជំនាន់ក្រោយបានដឹង។ តាមរយៈឈុតឆាកនៃការសម្តែង បើទោះបីជាខ្ញុំមិនបានរស់នៅក្នុងសម័យកាលនោះក៏ដោយ ប៉ុន្តែនៅពេលដែលខ្ញុំបានទស្សនាសាច់រឿងល្ខោននិយាយនេះបានធ្វើឲ្យខ្ញុំគិតស្រមៃទៅដល់ជីវិតប្រជាជនខ្មែររាប់លាននាក់ដែលរស់នៅដោយរងទុក្ខ ការធ្វើបាប និងកាប់សម្លាប់ពីសំណាក់ខ្មែរក្រហម។ លើសពីនេះទៅទៀត ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» បាននាំមកនូវការចងចាំចំពោះជនរងគ្រោះដែលមានជីវិតរស់នៅមកដល់ពេលបច្ចុប្បន្ន។ ដោយល្ខោននេះជាមធ្យោបាយក្នុងការលើកឡើងអំពីកិច្ចពិភាក្សា ដើម្បីចាប់ផ្តើមផ្សះផ្សារវាងជនរងគ្រោះ និងជនដៃដល់ឲ្យមានការអត់ឱនអធ្យាស្រ័យឲ្យគ្នាទៅវិញទៅមកក្នុងគោលបំណងទប់ស្កាត់ការរើសអើង និងអំពើហិង្សានៅក្នុងសង្គម។ មិនត្រឹមតែប៉ុណ្ណោះ ល្ខោននិយាយ«ទម្លាយភាពស្ងៀមស្ងាត់» បានចូលរួមចំណែកក្នុងការអប់រំដល់កូនខ្មែរជំនាន់ក្រោយ បានសិក្សាស្វែងយល់អំពីរបប ប៉ុល ពត និងទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍កើតឡើងវិញម្តងទៀតចំពោះប្រជាជនខ្មែរ និងពិភពលោកទាំងមូល។

***ដាត ចាន់សុនិតា***

# ការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»នៅខេត្តតាកែវ

ល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់ ត្រូវបាននិពន្ធឡើងកាលពី១០ឆ្នាំមុន។ ល្ខោននិយាយមួយនេះ ចង់បង្ហាញអំពីរឿងពិតរបស់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់របបខ្មែរក្រហមដ៏សែនព្រៃផ្សៃ ហើយដែលនៅតែទទួលរងទុក្ខសោកដោយសារតែស្រមោលនៃអតីតកាល ព្រមទាំងដើម្បីលើកទឹកចិត្តឲ្យជនរងគ្រោះ និយាយអំពីបទពិសោធន៍របស់ខ្លួន។ ឈុតឆាកបន្ថែមថ្មីមួយទៀតរបស់ល្ខោននិយាយ ម្ទាយភាពស្ងៀមស្ងាត់ បានបង្ហាញដល់ក្មេងជំនាន់ក្រោយថា ខ្លួនអាចសាកសួរ អាចជឿងឆ្ងល់ និងត្រិះរិះពិចារណាអំពីផលអវិជ្ជមាននៃមហិច្ឆតារបស់ក្រុមមេដឹកនាំខ្មែរក្រហមតែប៉ុន្មាននាក់ដែលបានបំផ្លិចបំផ្លាញប្រទេសកម្ពុជាស្ទើរលាយសូន្យសុង។ ការសម្តែង ក៏បានឆ្លុះបញ្ចាំងចំពោះការអប់រំរបស់ព្រះពុទ្ធសាសនាអំពីកម្មផលនិងចោទសួរទៅលើតួនាទីរបស់សាលាក្តីខ្មែរក្រហមចំពោះប្រព័ន្ធច្បាប់ និងយុត្តិធម៌។ នៅក្នុងឈុតឆាកបន្ថែមថ្មី ក៏បានបង្ហាញអំពីផលវិបាកចំពោះការផ្សះផ្សារវាងជនរងគ្រោះ និងជនដៃដល់ដែលនៅក្នុងឈុតឆាកនោះមានឃ្លាមួយរៀបរាប់ថា «កុំថាឡើយនិយាយ សូម្បីតែមើលក៏មិនបានដែរ» «ឪពុកដូចកូន កូនក៏ដូចឪពុកដែរ ឈាមអាក្រក់គឺនៅតែអាក្រក់អញ្ចឹង អាក្រក់ជារៀងរហូត»។

***អំពីខេត្តតាកែវ***



សាធារណជនរង់ចាំទស្សនាល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់ (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខេត្តតាកែវ គឺជាខេត្តមួយស្ថិតនៅទិសនិរតីនៃប្រទេសកម្ពុជា មានរយៈចម្ងាយប្រហែល៨០គីឡូម៉ែត្រពីទីក្រុងភ្នំពេញ។ ខេត្តតាកែវត្រូវបានគេចាត់ទុកថាជា ដើមកំណើតនៃអរិយធម៌ខ្មែរ ពីព្រោះខេត្តនេះគឺជាទីតាំងប្រវត្តិសាស្ត្រនៃនគរដំបូងបង្អស់របស់ប្រទេសកម្ពុជា គឺនគរគោកធ្លក ថែមទាំងមានប្រាសាទបុរាណជាច្រើនរហូតដល់ទៅ៣៨ប្រាសាទ ដែលបានកសាងឡើងមុនសម័យអង្គរចន្លោះពីសតវត្សរ៍ទី៥ ដល់ទី៨។

នៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៨ ខេត្តតាកែវបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ដែលជាមេដឹកនាំជាន់ខ្ពស់ក្នុងរបបខ្មែរក្រហម។ នៅក្នុងរយៈពេលបីឆ្នាំនៃការគ្រប់គ្រងរបស់ តាម៉ុក ប្រជាជនជាច្រើនត្រូវបានបង្អត់អាហារ កាប់សម្លាប់ និងបង្ខំឲ្យធ្វើពលកម្មហួសកម្លាំង។ លោក ឡាង សុខ សព្វថ្ងៃគឺជាមេភូមិរការក្នុង បានឲ្យដឹងថា «មនុស្សជាច្រើនស្លាប់នៅទីនេះ មិនមែនដោយសារតែភាពអត់ឃ្លាននោះទេ ប៉ុន្តែភាគច្រើនគឺដោយសារតែត្រូវបានគេយកទៅសម្លាប់ចោល»។ គាត់ក៏បានបន្ថែមទៀតថា «ខ្ញុំធ្លាប់បានមើលការសម្តែងសិល្បៈជាច្រើនដងដែរនៅក្នុងរបបខ្មែរក្រហម ប៉ុន្តែការសម្តែងសិល្បៈនាពេលនោះគឺដើម្បីការឃោសនា និងកោតសរសើរអំពីភាពរុងរឿង និងភាពអស្ចារ្យរបស់អង្គការទៅវិញទេ។ ក្នុងរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ ខ្មែរក្រហមបានផ្លាស់ប្តូរសិល្បៈខ្មែរដែលកំពុងតែរីកចម្រើនឲ្យទៅជាឧបករណ៍នយោបាយដើម្បីលើកតម្កើងអំពីបក្សរបស់ខ្លួន។ បច្ចុប្បន្ននេះ សិល្បៈក៏ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដើម្បីបង្ហាញប្រទេសជាតិ និងពិភពលោកទាំងមូលអំពីទង្វើសាហាវព្រៃផ្សៃដែលខ្មែរក្រហមបានប្រព្រឹត្តដែរ។

**ការសម្តែងល្ខោនទម្លាយភាពស្ងៀមស្ងាត់នៅខេត្តតាកែវ**

រយៈពេល ១ថ្ងៃ មុនថ្ងៃទិវានៃសេចក្តីស្រឡាញ់ក្នុងឆ្នាំ២០១៩ និងបន្ទាប់ពីការសម្តែងល្ខោននិយាយ ទម្លាយភាពស្ងៀមស្ងាត់កាលពី១០ឆ្នាំមុនបានកន្លងផុតទៅ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០១៩នេះ ល្ខោននិយាយនេះត្រូវបានរៀបចំធ្វើការសម្តែងជាថ្មីម្តងទៀត ដែលស្ថិតក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ។ ថ្វីត្បិតតែការសម្តែងនេះធ្វើឡើងនៅក្នុងបរិវេណសាលារៀនក៏ពិតមែន ប៉ុន្តែវាមិនមែនសម្រាប់តែសិស្សតែប៉ុណ្ណោះនោះទេ ផ្ទុយទៅវិញគឺសម្រាប់ប្រជាជនកម្ពុជាទាំងអស់ដែលបានរស់នៅក្នុងរបបខ្មែរក្រហម និងក្មេងៗជំនាន់ក្រោយដែរ។

លោក ផេង ពង្សរ៉ាស៊ី គឺជានាយកមជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបាននិយាយថា «យើងរៀបចំការសម្តែងល្ខោននិយាយ ទម្លាយភាពស្ងៀមស្ងាត់នៅក្នុងបរិវេណសាលារៀន ពីព្រោះយើងចង់ឲ្យទស្សនិកជនដឹងថា ការសម្តែងនេះគឺសម្រាប់គោលបំណងនៃការអប់រំ»។ ប្រជាពលរដ្ឋប្រមាណ៥០០ នាក់ជាងដែលមកពីឃុំនិងភូមិផ្សេងៗពីគ្នានៅក្នុងខេត្តតាកែវ បានមកចូលរួមទស្សនាការសម្តែងនេះក្នុងនោះដែរ គឺមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម សិស្សដែលកំពុងសិក្សានៅថ្នាក់វិទ្យាល័យ គរុសិស្សដែលរៀនជំនាញផ្សេងៗពីគ្នា គ្រូបង្រៀន និងអាជ្ញាធរមូលដ្ឋានជាដើម។ មុនពេលនៃការសម្តែងចាប់ផ្តើមប្រហែលជាកន្លះម៉ោង ទស្សនិកជនបានមកអង្គុយពេញសាលសម្តែងរួចបាត់ទៅហើយ។ ខណៈពេលដែលកំពុងរង់ចាំការសម្តែងចាប់ផ្តើម អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយចំនួនដែលបានអង្គុយនៅក្បែរៗគ្នាបានចែករំលែករឿងរ៉ាវរបស់ខ្លួននៅក្នុងរបបខ្មែរក្រហម ដែលភាគច្រើនគាត់និយាយអំពីការងារពលកម្ម នៅក្នុងវាលស្រែ និងអារម្មណ៍រំភើបរីករាយនៅពេលដែលស្វែងរកឃើញអាហារ ដើម្បីបរិភោគ។ ក្នុងអំឡុងពេលនៃការសម្តែង ទស្សនិកជនពិតជាចាប់អារម្មណ៍ទៅលើតួអង្គស្វា និងបទចម្រៀងនីមួយៗនៅក្នុងសាច់រឿង។ អ្នកខ្លះសើច ហើយអ្នកខ្លះទៀតក៏យំទៅតាមឈុតឆាកដែលគាត់ពេញចិត្ត ឬស្រដៀងនឹងរឿងរ៉ាវពិតរបស់ខ្លួន។

ណុប ណារី សព្វថ្ងៃរស់នៅក្នុងភូមិព្រៃព្រាំបាននិយាយថា «ការសម្តែងហាក់បីដូចជាបានឆ្លុះបញ្ចាំងអំពីរឿងរ៉ាវផ្ទាល់

ខ្លួនរបស់ខ្ញុំនៅពេលនោះ ហើយក៏បានធ្វើឲ្យខ្ញុំធូរស្រាលនៅក្នុងចិត្តដែរ។

គរុសិស្សជំនាញខាងប្រវត្តិសាស្ត្រម្នាក់ឈ្មោះ រី សុខកេតា បាននិយាយថា «ការសម្តែង គឺពិតជាទាក់ទាញចិត្តខ្លាំងណាស់។ ខ្ញុំចូលចិត្តតួអង្គសត្វស្វា ចំពោះខ្ញុំតួអង្គមួយនេះគឺហាក់បីដូចជាការតំណាងឲ្យការផ្សះផ្សា»។

## មួយថ្ងៃមុនពេលការសម្តែងចាប់ផ្តើម

នាព្រឹកថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ សិល្បៈករបានចាប់ផ្តើមធ្វើដំណើរទៅកាន់ខេត្តតាកែវដើម្បីត្រៀមខ្លួនសម្រាប់ការសម្តែង។ ក្រុមអ្នកសម្តែងទាំងអស់បានធ្វើដំណើរទៅដល់ខេត្តតាកែវពេលថ្ងៃត្រង់ ហើយក៏បានចាប់ផ្តើមរៀបចំសម្តែងសាកល្បងនៅវេលាម៉ោង៣រសៀល។ អំឡុងពេលនៃការសម្តែងសាកល្បង សិល្បៈករទាំងអស់បានប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីបញ្ចូលមនោសញ្ចេតនាទៅក្នុងការសម្តែងរបស់ខ្លួន។ ថ្វីត្បិតតែមានបញ្ហាប្រឈមខ្លះជាមួយនឹងការភ្លាំងភ្លេចនូវឃ្លាឃ្លោង ដែលត្រូវនិយាយនៅក្នុងឈុតឆាកសម្តែងសាកល្បងរបស់ខ្លួន ក៏សិល្បៈករទាំងនោះនៅតែអាចបន្តការហាត់សម្តែងបានយ៉ាងរលូនដោយសារពួកគាត់បានសហការ និងជួយគ្នាទៅវិញទៅមក។ នៅថ្ងៃនោះដែរ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានឆ្លៀតឱកាសសម្ភាសន៍ប្រជាជននៅតាមភូមិមួយចំនួនអំពីរឿងរ៉ាវនៅក្នុងរបបខ្មែរ-ក្រហម និងចំណាប់អារម្មណ៍របស់ពួកគាត់ចំពោះល្ខោនទម្លាយភាពស្ងៀមស្ងាត់។

លោក ឡាងសុខ បានមានប្រសាសន៍ថា «ខ្ញុំស្នើសុំឲ្យមានការសម្តែងបែបនេះទៀត ព្រោះកូនៗរបស់ខ្ញុំនិងក្មេងជំនាន់ក្រោយជាច្រើន នឹងជឿថារបបខ្មែរក្រហមពិតជាបានកើតឡើងទេ។ ដរាបណាមានឯកសារកត់ត្រាអំពីរបបខ្មែរក្រហម ខ្ញុំមិនភ័យខ្លាចថា ការពិតនៃរឿងរ៉ាវដែលបានកើតឡើងនឹងបាត់បង់ទៅវិញនោះទេ»។ នៅក្នុងអំឡុងពេលសម្ភាសន៍ ក្មេងស្រីតូចម្នាក់បានចូលរួមស្តាប់បទសម្ភាសន៍យ៉ាងយកចិត្តទុកដាក់។

វ៉ន សុនីកា មានអាយុ១២ឆ្នាំ និងសព្វថ្ងៃនេះកំពុងតែសិក្សាថ្នាក់ទី៦បាននិយាយថា ខ្ញុំមិនដែលឮអំពីរបបខ្មែរ-ក្រហមពីមុនមកទេ ហើយគ្រូនៅសាលាក៏មិនបានបង្រៀនអំពីរឿងនេះដែរ។ សុនីកា បានបន្ថែម ថា ខ្ញុំពិតជាចង់ចូលរួមមើលការសម្តែងណាស់ ដើម្បីដឹងឲ្យបានច្បាស់ថាតើរបបខ្មែរក្រហមមានពិតឬយ៉ាងណា។

ជីតារបស់ សុនីកា ដែលបច្ចុប្បន្ននេះមានអាយុ៧៨ឆ្នាំក៏បានបន្ថែមថា ខ្ញុំបានទស្សនាការសម្តែងនេះម្តងដែរកាលពីរយៈពេល១០ឆ្នាំមុន ហើយថែមទាំងទទួលបានសៀវភៅទៀតផង។ ខ្ញុំសប្បាយចិត្តដែលបានចូលរួមទស្សនាការសម្តែងម្តងទៀតនៅទីនេះ។

## សេចក្តីបញ្ចប់

ទោះបីជាមានបញ្ហាកំហុសតិចតួចជាមួយបច្ចេកទេសសំឡេងក៏ដោយ ក៏ការសម្តែងល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់នៅខេត្តតាកែវ បានបញ្ចប់ទៅដោយភាពជោគជ័យ និងមានការចូលរួមនិងគាំទ្រយ៉ាងច្រើនពីសំណាក់ប្រជាជន។ ដោយមានការជួយជ្រោមជ្រែងពីអាជ្ញាធរមូលដ្ឋានគ្រប់កម្រិត ជាពិសេសលោកគ្រូអ្នកគ្រូនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ ប្រជាជនជាង៥០០នាក់បានមកចូលរួមទស្សនាការសម្តែងល្ខោននេះ។ យើងទាំងអស់គ្នាអាចរៀនអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបាន តាមវិធីជាច្រើនបែប។ អ្វីដែលសំខាន់នោះគឺអ្នកដែលរៀនអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម នឹងមិនគ្រាន់តែរៀនសម្រាប់គោលបំណងតែមួយពេលប៉ុណ្ណោះទេ។ របបខ្មែរក្រហមគឺជាប្រវត្តិសាស្ត្រដ៏ខ្មៅងងឹត ប៉ុន្តែវាមិនមានន័យថាយើងគួរតែបំភ្លេចវាចោលដែរ។ ប្រវត្តិសាស្ត្រងងឹតនេះគឺជាឧបករណ៍អប់រំដ៏មានឥទ្ធិពលមួយដែលក្មេងជំនាន់ក្រោយកម្ពុជាអាចយកមករៀនសូត្របាន ហើយកែប្រែ និងតម្រង់ទិសដៅជីវិតឲ្យបានល្អប្រសើរ។

*សូវិចិត្រ មេត្តា*

# ដំណឹងជ្រើសរើសអ្នកស្រាវជ្រាវ

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសអ្នកស្រាវជ្រាវដែលគ្រូបង្រៀន ឬអតីតគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យាចំនួន២០នាក់ ឲ្យចូលរួមក្នុងការសរសេរសំណេរ«ប្រវត្តិសាស្ត្រចេញពីភូមិ» ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងរបបខ្មែរក្រហម ចេញពីភូមិឃុំដែលខ្លួនកំពុង ឬធ្លាប់បំពេញភារកិច្ចជាគ្រូបង្រៀន។ កិច្ចការនេះ ជាកិច្ចការស្ម័គ្រចិត្តនៅក្នុងគម្រោងស្តីអំពី «ប្រវត្តិសាស្ត្រភូមិ» ហើយក៏ជាដំណាក់កាលទី២នៃការអនុវត្តកិច្ចការនេះដែរ។ សំណេររបស់អ្នកស្រាវជ្រាវ នឹងត្រូវបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រួចប្រគល់ជូនវិញដើម្បីប្រើប្រាស់ជាសម្ភារឧបទ្ទេសក្នុងការបង្រៀន ឬប្រើប្រាស់ផ្ទាល់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជា ឧបត្ថម្ភជាថវិកាសម្រាប់ការស្រាវជ្រាវនេះ។






***លក្ខខណ្ឌជ្រើសរើស***

១) អ្នកស្រាវជ្រាវ ត្រូវតែជាអតីត ឬគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យានៅក្នុងខេត្តព្រៃវែង, ស្វាយរៀង, ត្បូងឃ្មុំ, កណ្តាល (ស្រុកមុខកំពូល, ល្វាឯម និងខ្សាច់កណ្តាល) និងក្រចេះ (ស្រុកឆ្លូង) ដែលមិនជាប់តួនាទីជានាយកឬនាយករងនៃវិទ្យាល័យ ឬការងារដ៏ទៃទៀតដែលខ្លួនកំពុងធ្វើការ។

២) មានចំណេះដឹងអំពីវិធីសាស្ត្រក្នុងការធ្វើកិច្ចការស្រាវជ្រាវដូចជា ការធ្វើបទសម្ភាសន៍ទំនាក់ទំនងជាមួយអ្នកដែលត្រូវសម្ភាសន៍ វិភាគលើទិន្នន័យដើម និងសរសេរ។

៣) មានចំណេះដឹងសមរម្យក្នុងការប្រើប្រាស់កុំព្យូទ័រលើកម្មវិធី Microsoft Word & Excel និងមានកុំព្យូទ័រផ្ទាល់ខ្លួនដើម្បីធ្វើកិច្ចការនេះ។

៤) មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចឲ្យបាននូវសំណេរតាមការកំណត់។

៥) មានភាពច្នៃប្រឌិតចំពោះការប្រើប្រាស់ឧបករណ៍ (ថតសំឡេង និងម៉ាស៊ីនថត) សម្រាប់កិច្ចការស្រាវជ្រាវ។

៦) មានសមត្ថភាពទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។

***លក្ខខណ្ឌការងារ***

១) ធ្វើកិច្ចការស្រាវជ្រាវដោយមិនឲ្យប៉ះពាល់ដល់ម៉ោងបង្រៀនសិស្សនៅតាមវិទ្យាល័យដែលខ្លួនកំពុងបង្រៀន។

២) ប្រើប្រាស់ពេលវិស្សមកាល ឬពេលទំនេរពីការបង្រៀន ដើម្បីធ្វើកិច្ចការនេះ។

៣) បែងចែកពេលវេលាច្បាស់លាស់ពីដំណើរការប្រព្រឹត្តទៅនៃកិច្ចការស្រាវជ្រាវ រួចផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីការសហការ។ ឧទាហរណ៍៖ បង្ហាញគម្រោងផែនការជាដំណាក់កាលៗដូចជា៖ ប្រមូលធនធានសម្រាប់ ឯកសារយោង, កំណត់គោលដៅសម្រាប់សម្ភាសន៍, ការសម្ភាសន៍, វិភាគទិន្នន័យសម្ភាសន៍ និងសំណេរ។

៤) សរសេរកិច្ចការស្រាវជ្រាវឲ្យបានយ៉ាងហោចណាស់២០ទំព័រ។

៥) ផ្ញើសំណេរ និងកិច្ចសម្ភាសន៍ជាសំឡេងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរក្សាទុក និងងាយស្រួលក្នុងការពិនិត្យផ្ទៀងផ្ទាត់ និងបោះពុម្ព។

ប្រសិនបើលោកគ្រូអ្នកគ្រូ និងប្រិយមិត្តដ៏ទៃទៀតមានការចាប់អារម្មណ៍លើកិច្ចការនេះ សូមដាក់ពាក្យស្នើសុំមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយភ្ជាប់មកជាមួយនូវ ៖ ១) ពាក្យស្នើសុំធ្វើកិច្ចការស្រាវជ្រាវប្រវត្តិភូមិ។ ២) ប្រវត្តិរូបសង្ខេប១ច្បាប់ និង ៣) សេចក្តីអធិប្បាយត្រួសៗពីប្រធានបទដែលចង់សរសេរ តាមអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬផ្ញើមកកាន់អ៊ីមែល៖ truthrasy.p@dccam.org។ ការទទួលពាក្យផុតកំណត់ត្រឹម ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមទូរសព្ទ៖ ០១២ ៦៩៦៩៦១ ឬអ៊ីមែល៖ truthrasy.p@dccam.org ៕

# ពិធីសម្ពោធផ្ទាំងពាក្យស្លោកស្តីពី «ការទប់ស្កាត់អំពើប្រល័យពូជសាសន៍» និងសួនច្បារនៃការចងចាំ នៅវិទ្យាល័យមេសាង ខេត្តព្រៃវែង ប្រទេសកម្ពុជា

ផ្ទាំងពាក្យស្លោកស្តីអំពីការចងចាំ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា រួមជាមួយនឹងសួនច្បារថ្មី នៅក្នុងវិទ្យាល័យមេសាង ស្ថិតនៅក្នុងភូមិជីផុច ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង ត្រូវបានសម្ពោធកាលពីរសៀលថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រោមអធិបតីភាពលោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា លោក ឈុន សុផល ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង លោក ខឹម សាមៀន អនុប្រធានការិយាល័យអប់រំស្រុកមេសាង លោក ហ៊ិន សុផាត អភិបាលរងស្រុក លោកស្នងការស្រុក មន្ត្រីមន្ទីរសុខាភិបាលស្រុក និងនាយកសាលា ដោយមានការចូលរួមពីលោកគ្រូអ្នកគ្រូ សិស្សានុសិស្ស មន្ត្រីរាជការនិងប្រជាពលរដ្ឋប្រមាណជាង១,០០០នាក់ទៀត។ នៅក្នុងកម្មវិធីសម្ពោធនេះ ក៏មានការចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ អំពើប្រល័យពូជសាសន៍ និងអត្តសញ្ញាណជនជាតិចាមចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុហាំបាលីចំនួន ១.៥០០ក្បាល ដល់សិស្សានុសិស្ស និងអ្នកចូលរួមដែរ។

ពាក្យស្លោកទាំងពីរឃ្លានេះ មានខ្លឹមសារថា «រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍» និង «និយាយពីការរស់នៅក្នុងសម័យខ្មែរ



លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ចូលរួមជាគណអធិបតីក្នុងទិកាសសម្ពោធផ្ទាំងពាក្យស្លោក នៅវិទ្យាល័យមេសាង (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឲ្យអត់ខិន អធ្យាស្រ័យគ្នា» ថែមទាំងមានការដាក់តាំងបង្ហាញផ្ទាំងរូបថតទិន្នន័យនៃការស្រាវជ្រាវ និងប្រវត្តិសង្ខេបនៃមេដឹកនាំកំពូលនៃរបបខ្មែរក្រហមនៅក្នុងសួនច្បារដែលទើបសាងសង់ថ្មីដែរ។

ការសាងសង់សួនច្បារនេះឡើង និងដាក់តាំងបង្ហាញផ្ទាំងរូបថតទាំងនេះបង្ហាញទៅដល់សាធារណជន គឺដើម្បីគោរព រំឭក និងឧទ្ទិសទៅដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលស្លាប់ និងកប់នៅក្នុងបរិវេណវិទ្យាល័យមេសាងផ្ទាល់ ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារបានចុះមកធ្វើការងារស្រាវជ្រាវតាំងពីឆ្នាំ១៩៩៧។ កាលពីឆ្នាំ២០១៨កន្លងទៅ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រុមហ៊ុន ស្ប៉ារ៉ូហក ហ្វាអ៊ីស របស់អាមេរិកបានធ្វើបច្ចុប្បន្នភាពទៅលើទិន្នន័យដែលមានស្រាប់ និងស្រាវជ្រាវជាលក្ខណៈវិទ្យាសាស្ត្រទៅលើរណ្តៅសាកសពនៅក្នុងបរិវេណវិទ្យាល័យមេសាង ដោយប្រើម៉ាស៊ីនទំនើបRD1500ដែលមិនត្រឹមតែអាចវាស់វែងពីជម្រៅកម្ពស់ បណ្តោយ និងទទឹងនៃរណ្តៅនីមួយៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចបង្ហាញពីឆ្អឹងរបស់ជនរងគ្រោះដែលត្រូវបានកប់ក្នុងរណ្តៅកាលពីជំនាន់ខ្មែរក្រហមទៀតផង។ ព័ត៌មានបឋមដែលទទួលបានពីការត្រួតពិនិត្យរបស់ម៉ាស៊ីន RD1500 បានបង្ហាញថា ពិតជាមានឆ្អឹងសាកសពនៅក្នុងរណ្តៅជម្រៅចាប់ពី១ម៉ែត្រកន្លះទៅ៨ម៉ែត្រ។ សួនច្បារថ្មីនេះ ត្រូវបានដាក់ឈ្មោះថា «សួនច្បារអនុស្សាវរីយ៍ឬសួនច្បារនៃការចងចាំ»។

លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា បានឲ្យដឹងថា ការធ្វើសួនច្បារ និងសាងសង់ពាក្យស្លោកលើរណ្តៅសកសពនេះគឺដើម្បីអភិរក្សទីតាំងប្រវត្តិសាស្ត្រ និងដើម្បីបម្រើឲ្យការចងចាំដល់យុវជនជំនាន់ក្រោយ។ ក្រៅពីនេះ លោកជំទាវ ក៏បានកោតសរសើរចំពោះវិទ្យាល័យមេសាង ដែលមានសិស្សគោរពវិន័យបានល្អ និងមានការរាក់ទាក់យ៉ាងកក់ក្តៅបំផុត។ លោកជំទាវមានប្រសាសន៍ថា៖ «យុវជនជំនាន់ក្រោយត្រូវខិតខំរៀនសូត្រនិង



សៀវភៅចំនួន ១,៥០០ក្បាល សម្រាប់ចែកជូនដល់សិស្សានុសិស្ស និងអ្នកចូលរួម (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្វែងយល់អំពីប្រវត្តិសាស្ត្រឲ្យបានច្បាស់លាស់។ និយាយអំពីអំពើប្រល័យពូជសាសន៍គឺដើម្បីការអត់ខឹន ការផ្សះផ្សា និងការអធ្យាស្រ័យ។ យើងត្រូវអភិវឌ្ឍន៍ប្រទេសជាតិយើងឲ្យរីកចម្រើនទៅមុខទាំងអស់គ្នាឲ្យសម្បូរដោយធនធានមនុស្សពូកែ ជាមួយរាជរដ្ឋាភិបាល ព្រោះថ្ងៃក្រោយ ប្អូនៗនឹងក្លាយជាអ្នកដឹកនាំ ធ្វើយ៉ាងណាកុំនាំប្រទេសជាតិទៅរកវិនាសកម្មដូចសម័យខ្មែរក្រហមទៀត»។

ជាមួយគ្នានេះដែរ លោក ឈុន សុផល ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្តព្រៃវែងបានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការទប់ស្កាត់របបកាប់សម្លាប់កុំឲ្យកើតមានឡើងសារជាថ្មី។ លោកក៏បានសរសើរលទ្ធផលសិក្សា និងចំនួនសិស្សពូកែថ្នាក់ជាតិដែលវិទ្យាល័យមេសាង សម្រេចបានកន្លងមក។ លោកបន្តថា ៖ «ពាក្យស្លោក និងលទ្ធផលស្រាវជ្រាវទាំងនេះគឺជាឯកសាររស់មួយបន្ថែមទៀត ជាពិសេសសម្រាប់ក្មួយៗសិស្សានុសិស្សក៏ដូចជាលោកគ្រូអ្នកគ្រូ ដើម្បីរំឭកដល់ការចងចាំអំពីអតីតកាលដើម្បីផលប្រយោជន៍រួមនាពេលអនាគត គឺធ្វើយ៉ាងណា ទប់ស្កាត់កុំឲ្យរបបប្រល័យពូជសាសន៍កើតមកលើប្រទេសកម្ពុជាម្តងទៀត»។

បន្ថែមពីនេះ លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា និងគម្រោងស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជា បង្ហាញថា មានរណ្តៅសាកសពចំនួន៩ស្ថិតនៅក្បែរៗគ្នា និងមានសាកសពស្លាប់ប្រមាណជាង១០០នាក់នៅក្នុងរណ្តៅទាំងនេះ។ ក្នុងនោះរណ្តៅខ្លះមានកប់សាកសពត្រួតលើគ្នារហូតដល់ទៅ២លើក ដែលនេះសរបញ្ជាក់ឲ្យឃើញថា ខ្មែរក្រហមបានសម្លាប់មនុស្សដាក់ចូលទៅក្នុងរណ្តៅចំនួន២លើកផ្សេងគ្នា។ លទ្ធផលទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើជារបាយការណ៍សង្ខេបមួយដាក់នៅលើផ្ទាំងដែក ហើយត្រូវបានយកមកដាក់តាំងបង្ហាញនៅទីនេះ គឺនៅក្នុងបរិវេណនៃទីតាំងសម្លាប់មនុស្សតែម្តង។

រិត សិរីមគ្គ គឺជាសិស្សថ្នាក់ទី១២ បាននិយាយថា៖«ការដាក់ពាក្យស្លោកនៅសាលាដូច្នេះគឺធ្វើឲ្យសិស្សជំនាន់ក្រោយដូចខ្ញុំ បានដឹងពីរឿងរ៉ាវដែលធ្លាប់បានកើតឡើងនៅទីតាំងនេះផ្ទាល់។ ភស្តុតាងនេះនឹងធ្វើឲ្យក្មេងៗជំនាន់ក្រោយដឹងថាកន្លែងនេះគឺជាទីតាំងដែលមានឆ្អឹងនិងសាកសពជាច្រើនថែមទាំងអាចបង្ហាញដល់ខ្ញុំនិងសិស្សដ៏ទៃទៀតឲ្យកាន់តែមានការជឿជាក់ថារឿងរ៉ាវនៃការកាប់សម្លាប់នៅក្នុងរបបខ្មែរក្រហមនាពេលអតីតកាល បានកើតឡើងពិតប្រាកដមែន»។

ហាន សុគន្ធ បានរៀបរាប់ថា៖ «ពាក្យស្លោករួមនឹងទិន្នន័យអំពីសាកសពជនរងគ្រោះនៅក្នុងសម័យខ្មែរក្រហមអាចឲ្យយើងដឹងអំពីភាពព្រៃផ្សៃនៅពេលនោះ ហើយយើងត្រូវរៀនសូត្រពីមូលហេតុផ្សេងនៃការកើតឡើងនៃរបបនេះ ដើម្បីការពារកុំឲ្យមានកើតមកសារជាថ្មីម្តងទៀត។ ដូច្នេះ យើងត្រូវតែរៀនសូត្រឲ្យបានច្បាស់លាស់ និងចងចាំទាំងអស់គ្នា»។

លោក អ៊ុច គី មានអាយុ៧០ឆ្នាំ សព្វថ្ងៃ គឺជាមេភូមិពោធិ៍ព័ទ្ធ ឃុំជីផុច ស្រុកមេសាង ពិតជាសប្បាយរីករាយ



សិស្សទទួលបានសៀវភៅក្នុងឱកាសចូលរួមសម្ភោធផ្ទាំងពាក្យស្លោក នៅវិទ្យាល័យមេសាង
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដែលមានថ្នាក់ដឹកនាំជាន់ខ្ពស់មកចូលរួមនៅក្នុងកម្មវិធីនេះ ដើម្បីបង្ហាញអំពីសារសំខាន់នៃប្រវត្តិសាស្ត្រ។ លោកបាន និយាយថា ៖ «ដើម្បីឲ្យកូនចៅជំនាន់ក្រោយដែលរស់នៅក្នុងតំបន់នេះយល់បន្ថែមពីលើអ្វីដែលខ្ញុំធ្លាប់បាននិយាយកន្លងមក គឺមានតែការចូលរួមពីថ្នាក់ដឹកនាំទេដែលបានផ្តល់សារសំខាន់ខ្លាំង ព្រោះក្មេងៗយកចិត្តទុកដាក់ស្តាប់ថ្នាក់ដឹកនាំជាង បើប្រៀបធៀបពីអ្វីដែលខ្ញុំធ្លាប់បាននិយាយប្រាប់អំពីរបបខ្មែរក្រហមដល់ពួកគេ។ ខ្ញុំចង់ឲ្យមានការផ្សព្វផ្សាយអំពីរបបខ្មែរក្រហមឲ្យបានកាន់តែទូលំទូលាយបន្ថែមទៀតនាពេលអនាគត ជៀសវាងក្មេងជំនាន់ក្រោយបំភ្លេចប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន»។

គួររំឭកដែរថា របបខ្មែរក្រហមដែលមានឈ្មោះជាផ្លូវការថា របបកម្ពុជាប្រជាធិបតេយ្យ ដឹកនាំដោយ ប៉ុល ពត ចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ បានបណ្តាលឲ្យប្រជាជនប្រមាណ ២លាននាក់ស្លាប់បាត់បង់ជីវិតដោយសារការធ្វើការងារហួសកម្លាំង ការសម្លាប់ និងអត់អាហារ។ ខ្មែរក្រហមបានប្រែក្លាយ សាលារៀន និងវត្តអារាមទៅជាមន្ទីរសន្តិសុខ ក្រោលគោក្របី រោងសិប្បកម្ម ជង្រុកស្រូវ និងទីតាំងសម្លាប់និងកប់មនុស្ស។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានរកឃើញមន្ទីរសន្តិសុខឬគុកនៅក្នុងសម័យខ្មែរក្រហមចំនួន ១៩៦កន្លែង ទីតាំងសម្លាប់មនុស្សមាន ៣៨៨កន្លែង ក្នុងនោះរណ្តៅសាកសពមានចំនួនប្រមាណ២ម៉ឺនរណ្តៅ និងស្តូប ឬបូជនីយដ្ឋានចំនួន ៨១ នៅទូទាំងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៩៥។ កន្លងមកថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយក្រុមហ៊ុន ស្ប៉ារ៉ូហក ហ្វារអ៊ីស នៅក្នុងការស្រាវជ្រាវទៅលើរណ្តៅសាកសពជំនាន់ខ្មែរក្រហម តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីទំនើប ក្នុងការពិនិត្យមើលឆ្អឹងសាកសពជនរងគ្រោះដែលកំពុងស្ថិតនៅក្នុងក្រោមដី ក្នុងរណ្តៅដែលបានបន្សល់ទុកតាំងពីក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩។

របកគំហើញថ្មីដែលចេញមកពីកិច្ចការស្រាវជ្រាវនេះនឹងក្លាយជាមេរៀនថ្មីបន្ថែមទៀតបញ្ចូលបន្ថែមលើមេរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលសិស្សានុសិស្សបាន និងកំពុងសិក្សា។ ក្រៅពីនេះឯកសារជាង ១លាន២សែនទំព័រ រួមជាមួយនឹងប្រវត្តិរូបជនរងគ្រោះ និងកម្មាភិបាលប្រមាណ ៣ម៉ឺននាក់ អំពីរបបខ្មែរក្រហមត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

វិទ្យាល័យ មេសាង និងសាលារៀនចំនួន៦ទៀត ក្នុងខេត្តព្រៃវែង ត្រូវខ្មែរក្រហមប្រើប្រាស់ជាកន្លែងសម្លាប់មនុស្សក្នុងរយៈពេលដែលខ្លួនកាន់កាប់អំណាចពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ សម្រាប់ឆ្នាំ២០១៩នេះ សាលារៀនទាំងនោះនឹងក្លាយជាគោលដៅចម្បងសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការចុះផ្សព្វផ្សាយ និងផ្តល់ចំណេះដឹងបន្ថែមពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈកម្មវិធី «វេទិកាថ្នាក់រៀន» សម្រាប់សិស្សថ្នាក់ទី១២ និងការដាក់តាំងពិព័រណ៍រូបភាពមេដឹកនាំខ្មែរក្រហម។

***មីន សាណាស់ និង ផាត សិលា***



សួនច្បារអនុស្សាវរីយ៍ឬសួនច្បារនៃការចងចាំ នៅវិទ្យាល័យ មេសាង (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អង្គជំនុំជម្រះសាលាដំបូង ៖
# សេចក្តីសង្ខេបសាលក្រមសំណុំរឿង០០២/០២
## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

*(តពីលេខមុន)*

*ពាក់ព័ន្ធនឹងការកំណត់លើក្រុមគោលដៅជាក់លាក់ ជនជាប់ចោទត្រូវបានចោទប្រកាន់ពី៖*

*ទីមួយ ពាក់ព័ន្ធនឹងជនជាតិចាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត។*

*ទីពីរ ពាក់ព័ន្ធនឹងជនជាតិវៀតណាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការនិរទេសជនស៊ីវិលដោយខុសច្បាប់ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត។*

*ទីបី ពាក់ព័ន្ធនឹងពុទ្ធសាសនិក ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាតនិង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា។*

*ទីបួន ពាក់ព័ន្ធនឹងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (រួមទាំងអ្នករដ្ឋការស៊ីវិលនិងទាហាន) និងក្រុមគ្រួសាររបស់ពួកគេ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។*

*ពាក់ព័ន្ធនឹងការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍-ពិពាហ៍ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភបំពានផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។*

### *១.៣. សំអាងហេតុសំខាន់ៗរបស់អង្គជំនុំជម្រះសាលាដំបូង*

*៨. អង្គជំនុំជម្រះនឹងលើកឡើងអំពីសំអាងហេតុ និងសំអាងច្បាប់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗ ដោយសារតែវាពាក់ព័ន្ធនឹងគោលនយោបាយដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០២នេះ។ បន្ទាប់មក អង្គជំនុំជម្រះនឹងលើកឡើងអំពីសហឧក្រិដ្ឋកម្មរួម មុនពេលលើកឡើងអំពីសេចក្តីសន្និដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន។*

*៩. មុនពេលលើកឡើងអំពីទីតាំងឧក្រិដ្ឋកម្ម ជាបឋម*

អង្គជំនុំជម្រះ នឹងលើកឡើងអំពីធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។ អង្គជំនុំជម្រះយល់ឃើញថា ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបន្តយ៉ាងហោចណាស់ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ជាពេលវេលាស្ថិតក្រោមយុត្តាធិការនៃសំណុំរឿង០០២/០២ នោះ មានការវាយប្រហារជាទូទៅ និងជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិលនៅកម្ពុជា។ ការវាយប្រហារបានកើតឡើងក្នុងទម្រង់ជាច្រើន ដែលក្នុងនោះមានការជម្លៀសប្រជាជនដោយបង្ខំ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការបាត់ខ្លួនដោយបង្ខំ ការធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ការវាយប្រហារនេះ បានបណ្តាលឲ្យប្រជាជនស៊ីវិល រាប់លាននាក់ក្នុងប្រទេសកម្ពុជារងគ្រោះ ហើយធ្វើឲ្យជនភៀសខ្លួនជាច្រើនរត់គេចទៅប្រទេសជិតខាង។ ការវាយប្រហារនេះ ត្រូវបានធ្វើឡើងដើម្បីជំរុញនិងអនុលោមតាមគោលនយោបាយ និងផែនការរបស់បក្សក្នុងការកសាងសង្គមនិយម និងការការពារប្រទេស។ អង្គជំនុំជម្រះជឿជាក់ថា ការវាយប្រហារនេះ មានទ្រង់ទ្រាយធំទាំងផ្នែកវិសាលភាពភូមិសាស្ត្រ ក៏ដូចជាចំនួនជនរងគ្រោះ។ អង្គជំនុំជម្រះក៏យល់ឃើញផងដែរថាការវាយប្រហារនេះមានលក្ខណៈជាប្រព័ន្ធដោយសារតែឧក្រិដ្ឋកម្មដែលមានវិសាលភាព និងទំហំធំបែបនេះ មិនអាចត្រូវបានធ្វើឡើងដោយគ្មានការគ្រោងទុកឡើយ ហើយត្រូវធ្វើឡើងដើម្បីជំរុញនិងអនុលោមតាមគោលនយោបាយរបស់បក្ស។ អង្គជំនុំជម្រះយល់ឃើញថា ការវាយប្រហារនេះ មានគោលដៅប្រឆាំងនឹងប្រជាជនស៊ីវិលក្នុងប្រទេសកម្ពុជា។ អង្គជំនុំជម្រះយល់ឃើញទៀតថា ការវាយប្រហារត្រូវបានធ្វើឡើងដោយមូលហេតុនយោបាយ ជាតិសាសន៍ ជាតិពន្ធុ ពូជសាសន៍ និងសាសនា ហើយថា មានទំនាក់ទំនងរវាងការវាយប្រហារនេះនិងអំពើដែលបានប្រព្រឹត្ត។ អង្គជំនុំជម្រះក៏យល់ឃើញដែរថា នួន ជា និង ខៀវ សំផន បានដឹងពីការវាយប្រហារនេះ ហើយថា ពួកគាត់ទាំងពីរនាក់បានដឹងថាអំពើរបស់ខ្លួនគឺជាផ្នែកមួយនៃការវាយប្រហារនេះ។

១០. អង្គជំនុំជម្រះយល់ឃើញថា អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ មានចាប់តាំងពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ១៩៤៩ ដែលត្រូវបានចោទប្រកាន់នៅមន្ទីរសន្តិសុខ ស-២១ អង្គជំនុំជម្រះយល់ឃើញថា ជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនេះ គឺជាប្រជាជនស៊ីវិលវៀតណាម ឬឈ្លើយសឹកវៀតណាម ហេតុនេះ ពួកគេគឺជាបុគ្គលដែលត្រូវទទួលបានការការពារពីអនុសញ្ញាទីក្រុងហ្សឺណែវ។ ផ្ទុយទៅវិញ ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅមន្ទីរសន្តិសុខអូរកន្សែង អង្គជំនុំជម្រះមិនអាចជឿជាក់ឲ្យហួសពីវិមតិសង្ស័យបានទេថា ជនជាតិចារ៉ាយជា



រូបខាងឆ្វេង៖ លោក និខូឡាស គំដាន សហព្រះរាជអាជ្ញាអន្តរជាតិ និងលោកស្រី ជា លាង សហព្រះរាជអាជ្ញាជាតិនៃសាលាក្តីខ្មែរក្រហម។ (រូបថត៖ អ.វ.ត.ក)

បុគ្គលដែលទទួលបានការការពារ ទៅតាមអត្ថន័យនៃអនុសញ្ញាទីក្រុងហ្សឺណែវនោះ។ អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តទៅលើបុគ្គលដែលទទួលបានការការពារនៅមន្ទីរសន្តិសុខ ស-២១ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធិទៅនឹងជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម។ អង្គជំនុំជម្រះយល់ឃើញទៀតថា នួន ជា និង ខៀវ សំផន បានដឹងពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាម ហើយថា ពួកគេទាំងពីររូបបានដឹងអំពីឋានៈជាបុគ្គលដែលត្រូវទទួលបានការការពាររបស់ជនរងគ្រោះនៅមន្ទីរសន្តិសុខ ស-២១។

**១.៣.១.បរិបទប្រវត្តិសាស្ត្រ**

១១. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ក្នុងឆ្នាំ១៩៥៩ ទូ សាមុត, ប៉ុល ពត និង នួន ជា បានចាប់ផ្តើមដំណើរការបង្កើតបក្សកុម្មុយនីស្តកម្ពុជាថ្មីមួយ ដើម្បីគេចចេញពីឥទ្ធិពលរបស់វៀតណាម ដែលមានចរិតលក្ខណៈជាបក្សកុម្មុយនីស្តឥណ្ឌូចិន។ គោលការណ៍គ្រឹះរបស់បក្សនេះ គឺប្រជាធិបតេយ្យប្រមូលផ្តុំ និងម៉ាក្សលេនីននិយម។ សន្និបាតបក្សលើកទីមួយត្រូវបានធ្វើឡើង ចាប់ពីថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៦០ ដែលនៅក្នុងពេលនោះមានការអនុម័តលក្ខន្តិកៈបក្ស និងមានការជ្រើសតាំងគណៈកម្មាធិការដឹកនាំ។ ទូ សាមុត ត្រូវបានជ្រើសតាំងជាលេខាបក្ស ចំណែក នួន ជា ត្រូវបានជ្រើសតាំងជាអនុលេខាបក្ស។ បុគ្គលទាំងពីរនាក់នេះ ត្រូវបានជ្រើសតាំងទៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ជាមួយនឹងប៉ុល ពត ក្នុងនាមជាសមាជិកពេញសិទ្ធិ ហើយអៀង សារី ជាសមាជិកត្រៀម។ សុន សេន, សោ ភឹម និង តាម៉ុក ក៏បានចូលរួមក្នុងសន្និបាតនោះដែរ ដោយ សុន សេន និង សោ ភឹម ត្រូវបានជ្រើសតាំងជាសមាជិកត្រៀមនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍។ វន វេត ត្រូវបានជ្រើសតាំង



រូបខាងឆ្វេង៖ ខៀវ សំផន និង នួន ជា នៅបន្ទប់សវនាការនៃសាលាក្តីខ្មែរក្រហម។ រូបថត៖ អ.វ.ត.ក)

ទៅក្នុងគណៈកម្មាធិការមជ្ឈិមបក្សជាមួយនឹង ទូ សាមុត, នួន ជា, ប៉ុល ពត , អៀង សារី និង សុន សេន។ នៅក្នុងសន្និបាត បក្សលើកទីពីរ នៅខែកុម្ភៈ ឆ្នាំ១៩៦៣ ប៉ុល ពត ត្រូវបាន ជ្រើសតាំងជាលេខាបក្ស នៅពេល ទូ សាមុត បានបាត់ខ្លួន ចំណែក នួន ជា នៅតែជាអនុលេខាបក្ស ហើយការប្រើប្រាស់ ហិង្សានយោបាយ និងហិង្សាបដិវត្តន៍ត្រូវបានបញ្ជាក់សាជា ថ្មីទៀត។ អៀង សារី និង សោ ភឹម ត្រូវបានតម្លើងឋានៈជា សមាជិកពេញសិទ្ធិនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ចំណែក វន វ៉េត, រស់ ញឹម, សុន សេន និង តាម៉ុក ត្រូវបានជ្រើសតាំងទៅក្នុងគណៈកម្មាធិការមជ្ឈិម។ នៅក្នុង សន្និបាតបក្សលើកទីបី ដែលត្រូវបានធ្វើឡើងនៅក្នុងខែកញ្ញា ឆ្នាំ១៩៧១ បានបញ្ជាក់សាជាថ្មីអំពីមាគ៌ាយុទ្ធសាស្ត្ររបស់ បក្ស ដែលត្រូវបានអនុម័តនៅក្នុងសន្និបាតបក្សលើកទីមួយ និងលើកទីពីរ។ នេះជាលើកទីមួយដែល ខៀវ សំផន បានចូល រួមនៅក្នុងសន្និបាតបក្ស ហើយគាត់ត្រូវបានជ្រើសតាំងទៅ ក្នុងគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាក្នុងនាមជា សមាជិកបម្រុង រួមជាមួយនឹង ជូ ជេត, កែ ពក និង កុយ ធួន។

១២. រហូតដល់ឆ្នាំ១៩៦៩ សេដ្ឋកិច្ចនៅក្នុងប្រទេស កម្ពុជាបានធ្លាក់ចុះ ហើយមានភាពមិនច្បាស់លាស់អំពី ថា តើកម្ពុជាអាចនឹងធ្លាក់ចូលក្នុងសង្គ្រាមនៅក្នុងប្រទេសវៀត ណាមដែរឬយ៉ាងណា បើទោះបីជា សម្តេច នរោត្តម សីហនុ មានគោលនយោបាយអព្យាក្រឹត្យជាផ្លូវការក៏ដោយ។ ចាប់ ពីឆ្នាំ១៩៦៩ មក ភាពហិនហោច ការទម្លាក់គ្រាប់បែករបស់ សហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជាបានរុញច្រានឲ្យកង ទ័ពវៀតណាមខាងជើងកាន់តែខិតចូលមកក្នុងប្រទេសកម្ពុជា ដែលធ្វើឲ្យវិបត្តិនេះកាន់តែមានភាពតានតឹងថែមទៀត។ នៅ ក្នុងឆ្នាំ១៩៧០ លន់ នល់ ក្រោមការគាំទ្រពីសហរដ្ឋអាមេរិក បានធ្វើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ដែលនៅ ពេលនោះទ្រង់កំពុងស្ថិតនៅក្រៅប្រទេសកម្ពុជា។ សម្តេច នរោត្តម សីហនុ ក្រោយមកបានបង្កើតរណសិរ្សរួបរួមជាតិ កម្ពុជា ដែលជាចលនានយោបាយមួយដើម្បីប្រយុទ្ធប្រឆាំង នឹងអ្នកទម្លាក់ព្រះអង្គ។ នៅក្នុងខែឧសភា ឆ្នាំដដែលនោះ សម្តេចនរោត្តម សីហនុ ដោយមានការគាំទ្រយ៉ាងស្វៀម ស្ងាត់ពីបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតរដ្ឋាភិបាលនិរទេស ថ្មីមួយដែលមានឈ្មោះថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ខៀវ សំផន គឺជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលតាមរយៈតួនាទីនេះ គាត់បានដើរតួធ្វើជាអ្នកសម្របសម្រួលទំនាក់ទំនងរវាងសម្តេច នរោត្តម សីហនុ និង ប៉ុល ពត។ រដ្ឋបាលរបស់រាជរដ្ឋាភិបាល រួបរួមជាតិកម្ពុជាមិនមានអំណាចជាក់ស្តែងនៅក្នុងប្រទេស កម្ពុជាឡើយបើទោះបីជា សម្តេច នរោត្តម សីហនុ នៅបន្ត មានឥទ្ធិពលនៅលើឆាកអន្តរជាតិក៏ដោយ។ តាមពិតទៅបក្ស កុម្មុយនីស្តកម្ពុជាឯណោះទេ ដែលជាអ្នកទទួលខុសត្រូវលើការ តស៊ូប្រដាប់អាវុធ នៅក្នុងប្រទេសកម្ពុជានោះ។ ថ្នាក់ដឹកនាំ បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយតឹងរ៉ឹងក្នុងការ រក្សាការសម្ងាត់ ហើយមិនបង្ហាញអត្តសញ្ញាណរបស់ពួកគេ ជាសាធារណៈឡើយ។ ពួកគេនិយមប្រើប្រាស់ពាក្យ«អង្គការ» ដែលជាពាក្យមិនច្បាស់លាស់ និងជាពាក្យបិទបាំង សំដៅជា ស្ថាប័នដែលបានដឹកនាំប្រទេស ហើយដែលប្រជាជនធម្មតា យល់ថាមានអំណាចគ្រប់គ្រងលើប្រទេសទាំងមូល។ ពួកគេ ថែមទាំងបានប្រើប្រាស់បុគ្គលសាធារណៈដែលទទួលបានការ គោរព ដូចជា ខៀវ សំផន និង សម្តេចនរោត្តម សីហនុ ទាំងក្នុងប្រទេស និងលើឆាកអន្តរជាតិដើម្បីជាការបិទបាំង ចំពោះសកម្មភាព និងគោលនយោបាយរបស់ពួកគេ។

១៣. នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កង កម្លាំងបក្សកុម្មុយនីស្តកម្ពុជាបានចូលក្នុងទីក្រុងភ្នំពេញ ក្នុង នាមជាកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ហើយបានចាប់ផ្តើមបណ្តេញប្រជាជនឲ្យចាកចេញពីទីក្រុង ភ្នាម ដែលជាការចាប់ផ្តើមនៃរបបកម្ពុជាប្រជាធិបតេយ្យ។

**(នៅមានត)**

***អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា***

# កាលវិភាគបញ្ចាំងខ្សែភាពយន្តឯកសារ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា



បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅវិចិត្រសាលសិល្បៈ
សហសម័យវិទ្យាស្ថានស្លឹករឹត
អគារ H នៃវិទ្យាស្ថានជាតិអប់រំ
(មហាវិថីព្រះសីហនុ
រាជធានីភ្នំពេញ)










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាព-យន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរជ្ជកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ស៊ាង ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល truthchenda.s@dccam.org

# តើសិល្បៈបានចូលរួមចំណែកក្នុងការអប់រំ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍ឬយ៉ាងណា?

សិល្បៈគឺជាការផាវជំនាញ ឬស្នាដៃដែលធ្វើឲ្យមនុស្សចាប់ចិត្ត ចាប់អារម្មណ៍ ចង់មើល ចង់ឃើញ និងចង់ស្តាប់ៗ នៅពេលខ្លះ សិល្បៈក៏បានទាក់ទាញចំណាប់អារម្មណ៍របស់មនុស្សឲ្យក្រៀមក្រំ ភ័យរន្ធត់ និងរំភើបរីករាយដែរៗ សិល្បៈបានផ្សាភ្ជាប់ចំណាប់អារម្មណ៍របស់អ្នកទស្សនាឲ្យកាន់តែខិតចូលជិតខ្លួន និងចង់ស្វែងយល់ពីខ្លួនបានយ៉ាងងាយស្រួលៗ ដូច្នេះហើយ ទើបមានមនុស្សមួយចំនួនបានយកសិល្បៈមកពន្យល់ន័យប្រធានបទផ្សេងៗ ទាក់ទងអំពើប្រល័យពូជ-សាសន៍ ព្រោះសិល្បៈបានផ្តល់នូវចំណុចចាប់ផ្តើមមួយដែលជំរុញឲ្យអ្នកទស្សនាបញ្ចេញយោបល់និងបង្កើនការពិភាក្សាគ្នាៗ សិល្បៈបានផ្តល់ឲ្យនូវភាពងាយស្រួលក្នុងការសិក្សាស្វែងយល់ និងទទួលបានចំណេះដឹងអំពីបទពិសោធន៍នៃអំពើប្រល័យពូជសាសន៍ ខណៈពេលដែលមនុស្សជាច្រើនពិបាកនឹងឲ្យនិយមន័យ និងស្វែងយល់ដោយផ្ទាល់លើប្រធានបទនៃអំពើប្រល័យពូជសាសន៍ៗ បន្ថែមលើការស្វែងរកយុត្តិ-ធម៌ ការផ្សះផ្សា និងការរក្សាសន្តិភាពតាមរយៈនីតិវិធីរបស់តុលាការ សិល្បៈអាចចូលរួមដោះស្រាយ និងបំពេញបន្ថែមទៅលើចំណុចខ្វះខាត និងការសម្រេចបាននូវអ្វីដែលជាការខ្វះចន្លោះរបស់តុលាការៗ ម្យ៉ាងទៀត សិល្បៈក៏ជានិមិត្តរូបមួយ ចំពោះអ្នកដែលបានបាត់បង់ជីវិតដោយសារតែអំពើ



ក្រុមសិល្បៈករមកពីប្រទេសភូមាទស្សនាពិព័រណ៍ទីក្រុងភ្នំពេញនៅសាលសិល្បៈសហសម័យវិទ្យាស្ថានស៊ីករីត
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រល័យពូជសាសន៍ ហើយក៏ជាការរំឭកដល់មនុស្សជាតិឲ្យចងចាំពីព្រឹត្តិការណ៍ដែលបានកើតឡើងដែរ។

កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨នេះ សិល្បៈករជនជាតិភូមាចំនួន ១៨នាក់ បានមកទស្សនកិច្ចសាលសិល្បៈសហសម័យវិទ្យាស្ថានស្ទឹករីត និងទស្សនាការតាំងពិព័រណ៍រូបគំនូរចំនួន១៥ផ្ទាំង ដែលជាស្នាដៃរបស់វិចិត្រករវ័យក្មេងមកពីសាលាហ្វាពន្លឺសិល្បៈ រួមទាំងរូបគំនូរផ្សេងៗ និងបានជួបពិភាក្សាជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីស្វែងយល់បន្ថែមអំពីការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្តោតទៅលើអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។

គោលបំណងនៃដំណើរទស្សនកិច្ចរបស់សិល្បៈករភូមា គឺចង់សិក្សាអំពីរឿងរ៉ាវរបស់សង្គមខាងក្រៅ ដែលធ្លាប់បានជួបប្រទះនឹងសង្គ្រាម ការកាប់សម្លាប់ និងទទួលរងផលប៉ះពាល់ពីអំពើប្រល័យពូជសាសន៍។ ប្រទេសកម្ពុជា គឺជាប្រទេសមួយ ដែលបានឆ្លងកាត់អំពើប្រល័យពូជសាសន៍យ៉ាងឃោរឃៅនៅក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ខ្មែរក្រហម និងកំពុងតែខិតខំដោះស្រាយវិបត្តិអតីតកាលរបស់ខ្លួនដែលបានបន្សល់ទុកពីសង្គ្រាម។ សិល្បៈករទាំងអស់សង្ឃឹមថា ខ្លួននឹងអាចស្វែងយល់អំពី វិធីសាស្ត្រនៃការដោះស្រាយវិបត្តិអតីតកាលរបស់ប្រទេសកម្ពុជាចំពោះអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងដើម្បីឆ្លុះបញ្ចាំងទៅ



ក្រុមសិល្បៈករមកពីប្រទេសភូមាទស្សនាពិព័រណ៍ទីក្រុងភ្នំពេញនៅសាលសិល្បៈសហសម័យវិទ្យាស្ថានស្ទឹករីត
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នឹងប្រវត្តិសាស្ត្ររបស់ប្រទេសភូមាផ្ទាល់ និងបញ្ហាដែលប្រទេសភូមាកំពុងតែជួបប្រទះសព្វថ្ងៃនេះ។

លោកឈិតមុន្នីអ្នកសម្របសម្រួលក្រុមបាននិយាយថា សិល្បៈករដែលមកធ្វើទស្សនកិច្ចនៅថ្ងៃនេះ មានចំនួនសរុប ១៨នាក់ (ស្រី៩នាក់ និងប្រុស៩នាក់) ដែលសិល្បៈករទាំងអស់នេះ គឺជាវិចិត្រករ ផលិតករ អ្នកធ្វើការងារសង្គម អ្នកសម្តែង និងជាងគំនូរ។ សិល្បៈករភូមាទាំង១៨នាក់ មានបំណងចង់ប្រើប្រាស់ស្នាដៃសិល្បៈរបស់ខ្លួនសម្រាប់ការអប់រំ និងពន្យល់អំពីអំពើប្រល័យពូជសាសន៍ និងគាំទ្រដល់កិច្ចការសង្គមនៅក្នុងប្រទេសភូមា។ សិល្បៈករទាំងនេះ បានទៅទស្សនាសារមន្ទីរទួលស្លែង វាលពិឃាតជើងឯក សារមន្ទីរជាតិ និងមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីស្វែងយល់អំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។

នៅក្នុងជំនួបជាមួយសិល្បៈករជនជាតិភូមាទាំង ១៨ នាក់ លោក ឆាំង យុ បានបង្ហាញរូបគំនូរជាច្រើនផ្ទាំងនៅក្នុងបន្ទប់ប្រជុំរបស់ខ្លួន ដែលរូបគំនូរទាំងអស់នោះបានរៀបរាប់អំពី វប្បធម៌ សិល្បៈ សាសនា និងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា។ លោក ឆាំង យុ បាននិយាយថា យើងប្រើប្រាស់ភាពស្រស់ស្អាត ដើម្បីស្វែងយល់ពីភាពឃោរឃៅ។ លោកក៏បានបន្ថែមថា សិល្បៈ គឺជាផ្នែកមួយបានជួយដល់ការសិក្សាស្រាវជ្រាវរបស់លោក និងការយល់ដឹងអំពីឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានប្រព្រឹត្តដែរ។ **អ៊ុន សុដាវី**



ក្រុមសិល្បៈករមកពីប្រទេសភូមាជួបជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា
(រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ផ្ទាំងរូបថតរបស់ តាម៉ុក ត្រូវបានដាក់បង្ហាញលើកដំបូង នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

អ៊ុង ជឿន ឬ ឈិន ជឿន ហៅតាម៉ុក និង មានឈ្មោះបដិវត្តន៍ ផ្លូន កង កើតនៅឆ្នាំ ១៩២៦ ក្នុងភូមិប្រគាប ឃុំត្រពាំងធំ (ត្បូង) ស្រុកត្រាំកក់ ខេត្តតាកែវ។ នៅឆ្នាំ ១៩៦៨-១៩៦៩ តាម៉ុក ត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាត់តាំងឲ្យធ្វើជាលេខាភូមិភាគនិរតី។ តាម៉ុក ត្រូវបានកត់ត្រាក្នុងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យថា គឺជាមេដឹកនាំដែលសាហាវឃោរឃៅ។ នៅក្នុងអតីតមន្ទីរសន្តិសុខដែលគ្រប់គ្រងដោយ តាម៉ុក ស្ថិតនៅក្នុងឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ មានឃុំឃាំងអ្នកទោសចំនួនប្រមាណជា១ម៉ឺន៥ពាន់នាក់។ អ្នកទោសទាំងនោះត្រូវបានបង្ខំឲ្យធ្វើការងារហួសកម្លាំង និងគ្មានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ និងសម្លាប់ចោល។ នៅក្នុងឆ្នាំ ១៩៧៣ តាម៉ុក ត្រូវបានចាត់តាំងឲ្យទទួលបន្ទុកផ្នែកកងទ័ពនៅក្នុងភូមិភាគនិរតី។ នៅឆ្នាំ១៩៧៤ តាម៉ុក បានសហការជាមួយ កែពក អតីតលេខាភូមិភាគកណ្តាលដណ្តើមកានកាប់បានឧដុង្គ ខេត្តកំពង់ស្ពឺ ព្រមទាំងបានធ្វើការជម្លៀសប្រជាជនចេញដោយបង្ខំមានចំនួនប្រមាណជា២ម៉ឺននាក់។ ប្រជាជនទាំងអស់នោះត្រូវបានសម្លាប់ និងបង្អត់អាហារ។ ដោយឡែកទីតាំងមន្ទីរឃុំឃាំងមួយទៀត ដែលប្រជាជនដឹងថាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ដែរ គឺគុកសង់។ នៅក្នុងឆ្នាំ ១៩៧៧ អ្នកទោសភាគច្រើនដែលជាប់ឃុំក្នុងគុកសង់ គឺជាប្រជាជនថ្មី ហើយអ្នកទោសចំនួនប្រមាណជា ៥០០នាក់ត្រូវបានសម្លាប់នៅក្នុងគុកនេះ។ នៅពេលនោះ តាម៉ុក មានតួនាទីជាអគ្គមេបញ្ជាការកងទ័ព ហើយនៅឆ្នាំ១៩៧៨ តាម៉ុក ជាអគ្គលេខាបក្សកុម្មុយនីស្តកម្ពុជាប្រចាំភូមិភាគនិរតី។ ក្រោយរបបខ្មែរក្រហមដួលរលំ តាម៉ុក បានទៅបង្កើតកងកម្លាំងយោធានៅស្រុកអន្លង់វែង និងធ្វើការតស៊ូប្រឆាំងជាមួយរដ្ឋាភិបាលនៅភ្នំពេញ រហូតដល់សមាហរណកម្មនៅឆ្នាំ១៩៩៨។ តាម៉ុក គឺជាបុគ្គលដែលមានឈ្មោះល្បីល្បាញនៅស្រុកអន្លង់វែង ថែមទាំងទទួលបានការគោរពស្រឡាញ់ពីប្រជាជនរស់នៅស្រុកអន្លង់វែង ដោយសារតែប្រជាជនដែលរស់នៅទីនោះយល់ឃើញថា តាម៉ុក គឺជាមេទ័ពដ៏ខ្លាំងពូកែ និងជាអ្នកថែរក្សាការពារប្រជាជននៅអន្លង់វែង។ រឿងរ៉ាវនេះ បានធ្វើឲ្យមានការយល់ឃើញផ្ទុយពីប្រជាជនដែលរស់នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ក្នុងភូមិភាគនិរតី និងតំបន់ផ្សេងៗទៀត។ យុវជនជំនាន់ក្រោយ នៅស្រុកអន្លង់វែងមិនដែលបានឃើញ និងស្គាល់ តាម៉ុក នោះទេ។ តាម៉ុក ក៏បានស្លាប់មុនការកាត់ទោសរបស់តុលាការខ្មែរក្រហមដែរ។

កាលពីពេលថ្មីៗនេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានដាក់តាំងពិព័រណ៍រូបថតរបស់ តាម៉ុក ជាច្រើនផ្ទាំងនៅក្នុងបរិវេណសារមន្ទីរអតីតផ្ទះ តាម៉ុក និងទីតាំងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងស្ថិតនៅលើភ្នំដងរែកបង្ហាញទៅដល់សាធារណជន។ ផ្ទាំងរូបថតនីមួយៗមានការសរសេររៀបរាប់ខ្លីៗអំពីសកម្មភាពរបស់ តាម៉ុក ដែលបានប្រព្រឹត្ត មុននិងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ រូបថត តាម៉ុក ដែលដាក់បង្ហាញនៅបរិវេណសារមន្ទីរ ហាក់ដូចជាពុំសូវទទួលបាននូវការចាប់អារម្មណ៍ពីយុវជននោះឡើយ ពីព្រោះយុវជនមិនបានដឹងថា ផ្ទាំងរូបថតដែលបានដាក់តាំងពិព័រណ៍គឺជា តាម៉ុក ដែលពួកគេតែងតែឮឈ្មោះ។ នៅពេលដែលសិស្សានុសិស្សបានដឹងផ្ទាំងរូបថតនោះ គឺជារូបរបស់ តាម៉ុក ដែលពួកគេធ្លាប់តែឮពីឪពុកម្តាយ ពីគ្រូសារ ពីអ្នក

ជិតខាងនិងតាមរយៈសៀវភៅរបស់ក្រសួងអប់រំ ក្រុមសិស្សានុសិស្សបានបង្ហាញទឹកមុខភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ក្រុមយុវជន និងសិស្សានុសិស្សចាប់ផ្តើមរៀបរាប់អំពីស្នាដៃរបស់ តាម៉ុក នៅក្នុងស្រុកអន្លង់វែងដូចជា៖ ស្ពានសាលារៀនមន្ទីរពេទ្យនិងការរៀបចំបង្កើតបានជាភូមិ និងមានមនុស្សចូលមករស់នៅប្រមូលផ្តុំគ្នារហូតបច្ចុប្បន្ន។ មិនខុសអ្វីពីយុវជនផ្សេងទៀតទេ ឈ្មោះ ម៉ក់ សីហា គឺជាសិស្សវិទ្យាល័យអន្លង់វែង ដែលរស់នៅភូមិអូរគគីរកណ្តាល ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ យល់ឃើញថា តាម៉ុក គឺជាមនុស្សម្នាក់ដែលមានចិត្តស្នេហាជាតិប្រឆាំងជាមួយបរទេស ដូចជា បារាំង ជប៉ុន ដែលបានដាក់អាណានិគមមកលើប្រទេសកម្ពុជា ទោះគាត់មិនបានដឹងរឿងរ៉ាវរបស់ តាម៉ុក ពីមុនមកក៏ដោយ។ គ្រួសាររបស់ សីហា ជាអ្នកចំណូលថ្មីមកពីខេត្តកំពង់ចាម ហើយក៏មិនដែលបានជួប តាម៉ុក ដោយផ្ទាល់ដែរ។ សីហា បានដឹងរឿងរ៉ាវរបស់ តាម៉ុក តាមរយៈអ្នកជិតខាង និងឪពុកម្តាយនិយាយប្រាប់តែប៉ុណ្ណោះ។ ទោះបីយ៉ាងណា សីហា បានដឹងរឿងតិចតួចពីការប្រព្រឹត្តជាអំពើឃោរឃៅ អមនុស្សធម៌ សាហាវយង់ឃ្នងរបស់ តាម៉ុក ដូចដែលមានសរសេរនៅក្នុងអត្ថបទ និងការដាក់តាំងបង្ហាញនៅក្នុងផ្ទាំងរូបថត។ សីហា បានបន្តថា គាត់យល់ដូច្នេះដោយផ្អែកតែទៅការរៀបរាប់ពីគ្រួសារ អ្នកជិតខាង និងទៅលើសមិទ្ធផលរបស់ តាម៉ុក ដែលបានបន្សល់រហូតមកដល់ពេលបច្ចុប្បន្ននេះ។ ទោះជាយ៉ាងនេះក្តី សីហា ក៏មានចិត្តសោកសង្រេង នៅពេលដឹងពីការប្រព្រឹត្តរបស់ តាម៉ុក។ សីហា ក៏ចង់ឲ្យ តាម៉ុក ទទួលខុសត្រូវរាល់កំហុសដែលគាត់បានប្រព្រឹត្ត។ សីហា បានបង្ហាញអំពីការសោកស្តាយដែល តាម៉ុក បាត់បង់អាយុជីវិតមុនសាលាក្តីខ្មែរក្រហមបង្កើតឡើង និងមិនបានឡើងនិយាយពីកំហុសរបស់គាត់នៅចំពោះមុខតុលាការ។ ចំណែកការដាក់បង្ហាញរូបថតរបស់ តាម៉ុក នៅបរិវេណសារមន្ទីរផ្ទះតាម៉ុក និងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៅលើភ្នំដងរែក សីហា យល់ឃើញថា ពិតជាសារប្រយោជន៍ណាស់ព្រោះបានឲ្យគាត់ ក៏ដូចជា យុវជន និងអ្នកភូមិ ដែលធ្លាប់តែឮឈ្មោះ តាម៉ុក មិនដែលបានឃើញមុខពីមុន បានស្គាល់មុខរបស់ តាម៉ុក។

យុន ថង មានអាយុ៣៩ឆ្នាំ មានស្រុកកំណើតនៅខេត្តតាកែវ ហើយបច្ចុប្បន្នមានគ្រួសារបានមករស់នៅស្រុកអន្លង់វែងបានបង្ហាញពីការចាប់អារម្មណ៍ទៅលើរូបថតរបស់តាម៉ុក ដែលបានដាក់បង្ហាញ នៅមុខផ្លូវចូលមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាស្ថិតនៅលើភ្នំដងរែក នៅក្នុងឱកាសចូលរួមកម្មវិធីធ្វើដំណើរសិក្សាប្រវត្តិសាស្ត្រ កាលពីដើមខែមករា ឆ្នាំ២០១៩ នេះ។ ថង ធ្លាប់បានឮឈ្មោះរបស់ តាម៉ុក ពីអ្នកជិតខាង។ ថង គិតថា តាម៉ុក ជាមនុស្សល្អព្រោះគាត់បានបន្សល់ស្នាដៃជាច្រើនសម្រាប់ប្រជាជនរស់នៅក្នុងសហគមន៍អន្លង់វែងនេះ។ ថង មានភាពស្ទាក់ស្ទើរចំពោះការបញ្ចេញនូវការយល់ឃើញចំពោះ តាម៉ុក ត្រូវបានស្លាប់មុនការកាត់ទោសរបស់សាលាក្តីខ្មែរក្រហម។ ការដាក់តាំងបង្ហាញរូបថតរបស់ តាម៉ុក បានធ្វើឲ្យគាត់ចាប់អារម្មណ៍ ព្រោះមិនដែលបានឃើញរូបថតរបស់តាម៉ុកពីមុនមក។

អ៊ុង ជឿន ហៅ តាម៉ុក ត្រូវបានចាប់ខ្លួននៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមមាត្រា២ ក្រឹត្យច្បាប់លេខ០១ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៩។ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ តាម៉ុក បានស្លាប់ដោយសារតែជំងឺសម្ពាធឈាមឡើងខ្ពស់នៅក្នុងមន្ទីរពេទ្យយោធា ក្នុងទីក្រុងភ្នំពេញ។ តាម៉ុក គឺជាមេដឹកនាំខ្មែរក្រហម ដែលធ្វើឲ្យប្រជាជនមានការយល់ឃើញថា ជាមនុស្សសាហាវឃោរឃៅ។ ទោះបីជា តាម៉ុក បានបន្សល់ស្នាដៃជាច្រើនសម្រាប់ប្រជាជនដែលរស់នៅស្រុកអន្លង់វែងក្តី ប៉ុន្តែរឿងរ៉ាវអតីតកាលដែលកើតឡើងក្រោមការដឹកនាំរបស់ តាម៉ុក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) មិនអាចឲ្យប្រជាជនបំភ្លេចបានឡើយ។

**ដារ៉ារដ្ឋ មេត្តា**

# សូមចែករំលែករឿងរ៉ាវជីវិត
# ពីសម័យខ្មែរក្រហមដល់យុវជនជំនាន់ក្រោយ

ទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្តើមបោះពុម្ពផ្សាយដំបូងបង្អស់នៅខែមករា ឆ្នាំ២០០០។ ទស្សនាវដ្តីស្វែងរកការពិត បាននិងកំពុងសរសេរ ព្រមទាំងបោះពុម្ពផ្សាយពីរឿងរ៉ាវផ្សេងៗដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ដែលបណ្តាលឲ្យប្រជាជនកម្ពុជាស្លូតត្រង់ប្រមាណជិតពីរលាននាក់បាត់បង់ជីវិត បែកបាក់គ្រួសារ និងរងការឈឺចាប់រហូតមមកដល់សព្វថ្ងៃ។ អត្ថបទទាំងនេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឲ្យធូរស្បើយផ្លូវចិត្តសម្រាប់អ្នកដែលនៅរស់រានមានជីវិត ការជំរុញឲ្យមានយុត្តិធម៌ និងការផ្សះផ្សានៅក្នុងសង្គមកម្ពុជាទាំងមូល។ ការសរសេរសាច់រឿងពិតចេញពីបទពិសោធន៍របស់ប្រជាជនកម្ពុជា គឺជាការចូលរួមចំណែកដ៏ធំធេងក្នុងការថែរក្សាការចងចាំ និងជាសារមួយដ៏សំខាន់សម្រាប់អប់រំក្មេងៗជំនាន់ក្រោយឲ្យបានដឹងពីរឿងរ៉ាវរបស់មនុស្សដែលកំពុងរស់នៅជុំវិញខ្លួន ជាពិសេសសាច់ញាតិរបស់ខ្លួន និងប្រវត្តិសាស្រ្តដែលបានកើតឡើងនៅប្រទេសកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ បន្ថែមលើរឿងរ៉ាវប្រវត្តិសាស្រ្ត ទស្សនាដ្តីស្វែងរកការពិតក៏បានសរសេរ និងចែករំលែកនូវព័ត៌មានពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សាលាក្តីខ្មែរក្រហម) ដែរ។

បច្ចុប្បន្ន មានប្រជាជនកម្ពុជា និងជនបរទេសបានអាន និងគាំទ្រដល់ការងាររបស់ទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ អ្នកទាំងនេះបានសរសេរ និងបានផ្ញើរឿងរ៉ាវជីវិតផ្ទាល់ខ្លួន រួមទាំងសាច់ញាតិរបស់ខ្លួនមកចុះផ្សាយនៅលើទស្សនាវដ្តីស្វែងរកការពិតទៀតផង។

ដូច្នេះ ប្រសិនបើ អ៊ំ ពូ មីង បងប្អូន មានបំណងចង់បន្តចូលរួមសរសេរ និងមានអត្ថបទ ទាក់ទងនឹងរឿងរ៉ាវពីរបបខ្មែរក្រហម ហើយចង់ចុះផ្សាយនៅលើទស្សនាវដ្តីស្វែងរកការពិត សូមផ្ញើអត្ថបទទាំងនេះមកកាន់ខ្ញុំបាទ សោម ប៊ុនថន លេខទូរសព្ទ ៖ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១៨ ០០៩ អ៊ីម៉ែល ៖ truthbunthorn.s@dccam.org ឬតាមរយៈអាសយដ្ឋាន ៖ ផ្ទះលេខ ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ។ សូមអរគុណ!







# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

(តពីលេខមុន)

យុន គួយ មានអាយុ៣៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក១៨ តំបន់២៥ (ស្រុកកោះធំ ខេត្តកណ្ដាល) ជាកូនរបស់អ៊ំ ហឹង យុន និងអ៊ំស្រី ម៉ៅ អេង យុទ្ធជនកង២១ កងពល៧០៣ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅស-២១ យ។ ខ្មែរក្រហមសម្លាប់ យុន គួយ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។

យូ ឆាំងលាត មានអាយុ២៦ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតភ្នាក់ងារអគ្គការយ៉ៃ មានស្រុកកំណើតនៅកោះធំ ខេត្តកណ្ដាល ជាកូនរបស់ពូ យូ គីមប៉ាន និងមីង នាង ឡោយី មានប្រពន្ធឈ្មោះ ងី សេងឡាំ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៦ នៅមន្ទីរអប់រំស្រុក ១៨ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៥ បន្ទប់លេខ ៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

យូ ឆាំងសែ ហៅ អយ មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៧ អតីតសាស្ត្រាចារ្យ មានស្រុកកំណើតនៅកោះធំខេត្តកណ្ដាល ជាកូនរបស់អ៊ំ យូ កែវ ហាវ និងអ៊ំស្រី ស៊ាង ស៊ីម មានប្រពន្ធឈ្មោះ ហូ គីបថ មានកូនស្រី១នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៧ នៅភូមិព្រែកតាដួង ខេត្តកណ្ដាល ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០២ បន្ទប់ធំ ៤។ ខ្មែរក្រហមបញ្ជូល យូ ឆាំងសែ មកដល់គុកទួលស្លែង នៅថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៦១ថ្ងៃ។

យូ ទាប ជាប្រជាជនថ្មី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅឧស្សាហកម្ម ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះលេខ ០៤។ ខ្មែរក្រហមបញ្ជូល យូ ទាប មកដល់គុកទួលស្លែងនៅឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦។ ខ្មែរក្រហមក៏បានចាប់បងស្រីបង្កើតឈ្មោះ ឃី សេង បញ្ជូលមកដល់គុកទួលស្លែងនៅថ្ងៃទី២ ឬ៣ ខែមេសា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦។

ឃួន ដារិដ មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសង្កែ ខេត្តបាត់ដំបង ជាកូនរបស់ពូ ឃួន ឆុំ និងមីង ឡោ យក់អ៊ីវ អតីតបុគ្គលិកបេសកម្មរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅប៉ារីស ប្រទេសបារាំង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ មន្ទីរ ក-១៦ បឹងត្របែក ខាងត្បូង ភ្នំពេញ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៤ បន្ទប់តូច ៤ នៅថ្ងៃដដែល និងសម្លាប់ចោលនៅថ្ងៃនោះតែម្ដង។

ឃួន ណា ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៦ នៅរទេះភ្លើង។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឃួន នី ហៅ ណាង មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅចំការលើ ខេត្តកំពង់ចាម ជាកុនរបស់ពូ ឃួន យុត និងមីង វង យ៉ង់ យុទ្ធនារីកងពល៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ ០២ បន្ទប់តូច ១៥។ ខ្មែរក្រហមសម្លាប់ ឃួន នី នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧។

ឃួន សាន ហៅ វឿន មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៧

មានស្រុកកំណើតនៅស្ទោង ខេត្តកំពង់ធំ ជាកូនរបស់ពូ ឃិន ជិត និងមីង ញឹម សួង ប្រធានកងធំ ពាណិជ្ជកម្ម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅពាណិជ្ជកម្មរដ្ឋ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ០២ បន្ទប់តូច ៨។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

យួន សារុំ ហៅ ម៉េន មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទោង ខេត្តកំពង់ធំ ជាកូនរបស់ពូ ហង់ ឈឹម និងមីង ហួន យឹម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅដែកំពង់សោម។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

យួន សំបាន់ ហៅ រីន មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅចំការលើ ខេត្តកំពង់ចាម ជាកូនរបស់ពូ យួន យុត និងមីង វ៉ វ៉ាង យុទ្ធនារីពេទ្យ៣១ កងពល៣១០ មានប្តីឈ្មោះ ឆេវ ឆុន ហៅ ម៉ុន មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ នៅកងពល៣១០។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

យឿង បួយស៊ ហៅ បួយ មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧ ស្រុកកំណើតនៅស្រុក២០ (ស្រុកស្អាង) ខេត្តកណ្តាល ជាកូនរបស់ពូ យឿង ទ្រី និងមីង ស៊្រុន បាក់លី អនុលេខាធនុសេនាធំ កងពល៥០២ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកងពល៥០២។ ខ្មែរក្រហមសម្លាប់ យឿង បួយស៊ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៧ បន្ទាប់ជាប់ឃុំឃាំងអស់រយៈ ១៤៦ ថ្ងៃ។

យៀម សុកជា ជាវិស្វករ មកពីរុស្ស៊ី ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ចូល យៀម សុកជា ចូលគុកទួលស្លែងនៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញ ដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា កាលបរិច្ឆេទនៃការសម្លាប់ គឺខុសគ្នា ឯកសារមួយសរសេរថា ថ្ងៃទី១ ខែធ្នូ និងមួយទៀតថា ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ ដូចគ្នា។

យ៉ោក ដារាភក្ត្រ័ ហៅ ភក្ត្រ័ មានអាយុ ៣៩ឆ្នាំក្នុងឆ្នាំ១៩៧៥ អតីត «អ្នកបច្ចេកទេសខាងគីមីនៅមន្ទីពិសោធន៍ក្រសួងឧស្សាហកម្ម វិភាគគ្រឿងបរិភោគ និងគីមី ដើម្បីមើលគុណភាព និងធ្វើទឹកដបផ្លែឈើដាក់ដបដាក់កំប៉ុង» មានស្រុកកំណើតនៅបន្ទាយមាស ខេត្តកំពត ជាកូនរបស់អ៊ំ អ៊ូ យ៉ោក និងអ៊ំស្រី ម៉ែន ខាន់ មានប្រពន្ធឈ្មោះ ចាន់ វិជ្ជ វតី ហៅ មាន មានកូនប្រុស១នាក់និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៥ នៅភូមិព្រែកជ្រៃ សង្កាត់ (ឃុំ) ព្រែកឫស្សី ស្រុកល្វាឯម តំបន់២២ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០៥ បន្ទប់ធំ ៣។ ខ្មែរក្រហមបញ្ជូន យ៉ោក ដារាភក្ត្រ័ ដល់គុកទួលស្លែងនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា កាលបរិច្ឆេទនៃការសម្លាប់ គឺខុសគ្នា ឯកសារមួយសរសេរថា ថ្ងៃទី១៣ ខែឧសភា និងមួយទៀតថា ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ ដូចគ្នា។

យ៉ោក ព្រិល យុទ្ធជនកងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅកងពល១៧០។ ខ្មែរក្រហមបញ្ជូន យ៉ោក ព្រិល មកដល់គុកទួលស្លែងនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៥១ ថ្ងៃ។

យ៉ោក លីង៉ាន់ ហៅ ង៉ាន់ អាយុ៤១ឆ្នាំក្នុងឆ្នាំ១៩៧៦ និស្សិតកម្មសិក្សាការី មានស្រុកកំណើតនៅត្រាំកក់ ខេត្តតាកែវ ជាកូនរបស់អ៊ំ យ៉ោក ង៉ែត និងអ៊ំស្រី វើក ញ៉ មានប្រពន្ធឈ្មោះ មាស មូលី មានកូនប្រុស១នាក់និងស្រី៤នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៧៦

ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ១ បន្ទប់តូច ១៥។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ផន ទូច កត់ អនុវរៈសេនាតូចកងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅកងពល១៧០។ ខ្មែរក្រហមបញ្ជូន ផន ទូចកត់ ទៅដល់គុកទួលស្លែងនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៦ ថ្ងៃ។

ផន ស៊ាង ហ ប៉េង ស៊ាង យុទ្ធជនកងពល៥០២ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ នៅកងពល៥០២។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថា កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមានភាពខុសគ្នាដល់ទៅ ៣ គឺថ្ងៃទី១១, ទី១៩ និងទី២៩ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ផន ស៊ាង នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦។

ផ៊ាន ផុន ហៅ រឹម ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅឃ្លាំងរដ្ឋ។ ខ្មែរក្រហមចាប់បញ្ជូន ផ៊ាន ផុន មកដល់គុកទួលស្លែងនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៩២ ថ្ងៃ។

ផិន វឿន ជាប្រពន្ធរបស់ ញ៉ែម នេន ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦ នៅរទេះភ្លើង ហើយបញ្ចូលគុកទួលស្លែងនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ផិន វឿន នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ ក្រោយជាប់គុកបាន៣ថ្ងៃ។ រីឯប្តីឈ្មោះ ញ៉ែម នេន វិញត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៦ មុនប្រពន្ធមួយថ្ងៃ ហើយសម្លាប់ចោលក្រោយប្រពន្ធ គឺនៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១០៣ ថ្ងៃ។

ផី ហ៊ាង មានអាយុ៣៧ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ ជាអតីតវិស្វករផលិតថ្នាំពេទ្យ មានស្រុកកំណើតនៅស្រុក៥៥ ខេត្តកំពង់ស្ពឺ (ស្រុកព្រៃកប្បាស ខេត្តតាកែវ) ជាកូនរបស់ពូ ផី ស្រ៊ុន និងមីង អ៊ុក យី មានប្រពន្ធឈ្មោះ ម៉ី ប៊ុត សៃដា ហៅ សៃដា មានកូនប្រុស២នាក់និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក៩ បន្ទប់ធំ ២ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ផី ហ៊ាង នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំដដែល បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១០០ ថ្ងៃ។

ផ៊ុយ ប៉ោសេង មានអាយុ២៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ជាកូនរបស់ពូ ផ៊ុយ ហួត និងមីង ដាក ដូ កម្មករផ្លូវដែក មានប្រពន្ធឈ្មោះ អេង សុកឆេង មានកូនប្រុស១នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៦ នៅកំពង់ត្រឡាច ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឆ បន្ទប់ធំ ៥ បន្ទប់តូច ៦។ ខ្មែរក្រហមសម្លាប់ ផ៊ុយ សេងប៉ោ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៤០ ថ្ងៃ។

ផ្ញ៊ូ ចឺនឡុង មានអាយុ៣៦ឆ្នាំក្នុងឆ្នាំ១៩៧៦ ជនជាតិវៀតណាម ឪពុកម្តាយ ផ្ញ៊ូ វ៉ាន់ទី និង យ៉ាក ពូលីឌីប៊ីន មានប្រពន្ធឈ្មោះ លី ឆឹធូវិន មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ នៅកោះរ៉ៃ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ១ បន្ទប់តូច ២។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ផ្ញ៊ួយ៉ាង ឈុន មានអាយុ៣៩ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មាន

ស្រុកកំណើតនៅផ្លូវ ខេត្តតឹងសុងផ្លូវទាំង ឪពុកម្តាយ ង៉ូ យ៉ាងយុន និង លេធី តួង មានប្រពន្ធឈ្មោះ ចូវ ធីហ្វួយ មានកូនប្រុស៣នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៦ បន្ទប់តូច ១៦។ ខ្មែរក្រហមបញ្ជូន ង៉ូ យ៉ាងឈុន មកដល់គុកទួលស្លែងនៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ង៉ូវ ឆេង មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៧ ជនជាតិចិន មានស្រុកកំណើតនៅភ្នំពេញ ឪពុកម្តាយ ង៉ូវ សេង កង និង លាង ហ្វង មានប្រពន្ធឈ្មោះ វ៉ុង យាកមិញ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅរោងចក្រ ដ-៧ និងសម្លាប់ចោលនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៨៥ ថ្ងៃ។

ង៉ូវ ណៃអៀង ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅកន្លែងរទេះភ្លើង ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ង៉ូវ ទ្រី មានអាយុ៥០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅក្រូចឆ្មារ ខេត្តកំពង់ចាម ជាកូនរបស់លោកតា ង៉ូវ ឡោ និងលោកយាយ គឹម ហៀន មានប្រពន្ធឈ្មោះ ឆាយ សេងលី មានកូនប្រុស៣នាក់ និងស្រី៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃនៅទី៣១ ខែមករា ឆ្នាំ១៩៧៧ នៅមន្ទីរ ស-៨ឡានទឹក។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ង៉ូវ លាញ ហៅ ធន់ មានអាយុ៣៥ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតសាស្ត្រាចារ្យបច្ចេកទេសថ្នាក់លេខ២ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ង៉ូវ ស្រ៊ុន និងអ៊ំស្រី នាង លី ជា ម៉េង ហុងមានប្រពន្ធឈ្មោះ វ៉ា សូដាចន្ទ័ ហៅ បុង មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៦ នៅឃុំព្រៃឈរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៥ បន្ទប់លេខ១០។ ខ្មែរក្រហមបញ្ជូន ង៉ូវ លាញ មកដល់គុកទួលស្លែងនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ សម្លាប់ចោលនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៥៧ ថ្ងៃ។

ង៉ូវ ស៊ីជួរ ជាប្រពន្ធរបស់ អ៊ូ សារុន ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ នៅអគ្គីសនីទី២ និងសម្លាប់ចោលនៅថ្ងៃបន្ទាប់គឺថ្ងៃទី៣១។ រីឯប្តីឈ្មោះ អ៊ូ សារុន ត្រូវបានខ្មែរក្រហមឃាត់ខ្លួន២ថ្ងៃមុនប្រពន្ធគឺនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៣ ថ្ងៃ។

**(នៅមានត)**

**វ៉ាន់ថាន់ ពៅដារ៉ា និង ឡុង ដានី**

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

## ការចុះផ្សាយពីរឿងរ៉ាវប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូប ដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួននឹងផ្ញើមក មជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទលេខ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសព្ទលេខ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthbunthorn.s@dccam.org

Home Page: www.d.dccam.org

# សេក មឿន ៖ ពលទាហាន

ប្រពន្ធរបស់គាត់ឈ្មោះ ទៀងឃួន បាននិយាយរៀបរាប់ប្រាប់ថា ៖

ប្តីរបស់ខ្ញុំបានធ្វើការនៅរដ្ឋបាលអាកាសចរណ៍ស៊ីវិល នៅព្រលានយន្តហោះពោធិចិនតុង នៅពេលដែលយើងបានជួបគ្នា។ គាត់ជាអ្នកទទួលខុសត្រូវលើផ្នែកសន្តិសុខនៅព្រលានយន្តហោះ នាពេលនោះគឺជាពេលដែលប្រជាជនបានព្យាយាមដុតកម្ទេចព្រលានយន្តហោះនោះ។

មឿន បានរៀនសូត្រច្រើនជាងខ្ញុំ។ គាត់អាចនិយាយភាសាអង់គ្លេស បារាំង និងភាសាចិនបានយ៉ាងស្ទាត់ ព្រោះគាត់ជាកូនកាត់ចិននិងវៀតណាម។ បន្ទាប់ពីយើងរៀបការរួច យើងបានសង់ផ្ទះមួយនៅជិតការិយាល័យរបស់ មឿន។

មឿន មានប្រាក់ចំណូលតែ៤០០រៀលគត់ក្នុងមួយខែពីការងាររបស់គាត់នៅព្រលានយន្តហោះ ដូច្នេះគាត់បានបង្ខំចិត្តលួចប្រេងឥន្ធនៈយកទៅលក់ ដើម្បីធ្វើឲ្យយើងមានប្រាក់គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ថ្ងៃមួយនៅក្នុងឆ្នាំ១៩៧០ គាត់បានសម្រេចចិត្តមិនចង់ធ្វើការងារនៅខាងអាកាសចរណ៍ស៊ីវិលតទៅទៀតទេ គឺគាត់បានស្ម័គ្រចិត្តចូលធ្វើជាទាហានទៅច្បាំងនឹងខ្មែរក្រហម។ រាល់លើកគាត់ចេញទៅសមរភូមិ គាត់បានយកកូនៗរបស់ខ្ញុំ និងខ្ញុំទៅជាមួយគាត់។ កូនប្រុសច្បងរបស់ខ្ញុំមិនអាចអានឬសរសេរដល់សព្វថ្ងៃ ព្រោះវាតែងតែទៅជាមួយឪពុករបស់វា និងមិនបានចូលសាលារៀនទេ។ នៅពេលខ្លះខ្ញុំធ្វើជាអ្នកយាមជំនួសប្តីរបស់ខ្ញុំ ដូច្នេះគាត់មានពេលសម្រាកខ្លះ។

នៅឆ្នាំ១៩៧៣ គាត់បានលាលែងពីទាហានហើយទៅធ្វើការជាអ្នកបើកបរជំនួសវិញ។ គាត់ក៏ចេះជួសជុលរថយន្តដែរ។ ប៉ុន្តែមួយរយៈពេលខ្លីក្រោយមក គាត់បានត្រឡប់ទៅធ្វើជាទាហានម្តងទៀត។ នៅពេលដែលគាត់បានផ្ទេរទៅការិយាល័យយោធា២៤ ខ្ញុំបានទៅជាមួយគាត់ទោះបីជាខ្ញុំរៀបតែនឹងសម្រាលកូនទីបួនរបស់ខ្ញុំក៏ដោយ។ នៅថ្ងៃដែលគាត់នឹងត្រូវបញ្ជូនទៅរៀនក្បួនយុទ្ធសាស្ត្រយោធានៅប្រទេសវៀតណាម ខ្ញុំបានរលូតកូន ដូច្នេះគាត់បានយកខ្ញុំទៅមន្ទីរពេទ្យ និងនៅជាមួយខ្ញុំទាល់តែខ្ញុំបានជាសះស្បើយ។

នៅឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំទាំងអស់ចេញពីបន្ទាយទាហាននៅភ្នំពេញ។ ខ្ញុំបានវេចខ្ចប់ឯកសណ្ឋានទាហានរបស់ប្តីខ្ញុំ ប៉ុន្តែបន្ទាប់មកបានគ្រវាត់វាចោលនៅតាមផ្លូវ ព្រោះអីខ្ញុំខ្លាចខ្មែរក្រហមរកឃើញឯកសណ្ឋាននោះ។ យើងបានធ្វើដំណើរឆ្ពោះទៅខេត្តតាកែវ ជាទីកន្លែងដែលម្តាយរបស់ខ្ញុំ និងសាច់ញាតិជាច្រើននាក់របស់ខ្ញុំធ្វើជាប្រជាជនមូលដ្ឋាន។

យ៉ាងណាក៏ដោយ នៅពេលដែលយើងទៅដល់ អង្គការមិនបានអនុញ្ញាតឲ្យយើងនិយាយជាមួយអ្នករាល់គ្នាទេ ព្រោះយើងជាប្រជាជនថ្មី ហើយអ្នកភូមិក៏មិនបានស្វាគមន៍យើងដែរ។ បន្ទាប់មក យើងត្រូវបានបញ្ជូនទៅកាន់ភូមិមួយទៀតដែលនៅឆ្ងាយពីស្រុកកំណើតរបស់ខ្ញុំ ជាទីកន្លែងដែលអង្គការឲ្យយើងបំផ្លាញសាលារៀន និងវត្តជាច្រើន ហើយជីករណ្តៅសម្រាប់ដាក់សាកសពជនជាតិចិន និងបំផ្លាញម៉ុងរបស់ជនជាតិចិនដែរ។ ប្តីរបស់ខ្ញុំត្រូវបានបញ្ជាឲ្យឡើងដើមត្នោតច្រើនដើម ដើម្បីយកទឹកត្នោត និងវេញខ្សែព្រួរ។ ទោះបីការងារទាំងនេះថ្មីសម្រាប់គាត់ ក៏គាត់បានខិតខំប្រឹងធ្វើការយ៉ាងខ្លាំងដើម្បីជៀសវាងការចោទប្រកាន់ថាគាត់ជាអ្នកមូលធន។

រាល់យប់មានរទេះគោប្រហែល១៥គ្រឿង បានចូលមកក្នុងភូមិ និងបានដឹកប្រជាជនចេញទៅ។ អង្គការបាននិយាយថា អ្នកទាំងនោះត្រូវបានបញ្ជូនទៅរៀនសូត្រសាឡើងវិញ ប៉ុន្តែអ្នកទាំងនោះត្រូវបានសម្លាប់។ ខ្ញុំដឹងអំពីរឿងនេះ ព្រោះរបស់ប្រើប្រាស់ និងខោអាវរបស់អ្នកទាំងនោះបានយកមកភូមិវិញ។ ភាគច្រើននៃប្រជាជនដែលដឹកចេញទៅ គឺជាពល

បាលទោ ឬនាយទាហានជាន់ខ្ពស់ៗ ខ្ញុំបានសួរថា ហេតុអ្វីបានជាមិនយកខ្ញុំទៅ អង្គការបាននិយាយថា អង្គការទុកខ្ញុំមួយរយៈសិន និងបន្ទាប់មកទៀត ខ្ញុំនឹងត្រូវរៀនសូត្រសាឡើងវិញ។

នៅចុងឆ្នាំ១៩៧៥ យើងត្រូវបានបញ្ជូនទៅខេត្តបាត់ដំបង ជាទីកន្លែងដែលយើងបានរស់នៅជាមួយប្រជាជន១៧មេសាដូចគ្នា។ យើងបានសង់ជម្រកមួយធ្វើពីឫស្សី ហើយជីវិតរបស់យើងក៏មិនលំបាកដូចមុនដែរ។ យើងមានពេលវេលាសម្រាកខ្លះ និងអាចស្តាប់ចម្រៀងប្រពៃណី នៅអំឡុងពេលចូលឆ្នាំខ្មែរ។ ប្តីរបស់ខ្ញុំបានបន្តធ្វើការជាអ្នកឡើងត្នោត ហើយខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅក្នុងរោងកិនស្រូវ។

ថ្ងៃមួយនោះ អង្គការបានឆែកឃើញអង្ករមួយក្តាប់ដៃ ដែលលាក់ទុកនៅក្នុងហោប៉ៅអាវរបស់ខ្ញុំ។ ខ្ញុំមិនបានដឹងសោះថា មានអង្ករនៅក្នុងហោប៉ៅរបស់ខ្ញុំ។ កូនស្រីរបស់ខ្ញុំបានដាក់អង្ករនោះនៅក្នុងហោប៉ៅរបស់ខ្ញុំនៅពេលនាងកំពុងលេង។ អង្គការបានយកខ្ញុំទៅឃុំនៅក្នុងរោងកិនស្រូវចាស់មួយ ពេញមួយថ្ងៃ ប៉ុន្តែពិតជាសំណាងល្អ អង្គការបានដោះលែងខ្ញុំវិញ។

កងទ័ពវៀតណាមបានចូលមកប្រទេសកម្ពុជា នៅឆ្នាំ១៩៧៩ ហើយគ្រួសាររបស់ខ្ញុំ បានរត់ចេញពីសហករណ៍។ យើងបានផ្លាស់ទីលំនៅទៅខេត្តសៀមរាបមួយរយៈពេលខ្លី។ ខ្ញុំបានពរពោះកូនទីប្រាំរបស់ខ្ញុំ ហើយប្តីរបស់ខ្ញុំបានសម្រេចចិត្តហែលឆ្លងបឹង ដូច្នេះគាត់អាចទៅដោះដូរស្បៀងបាន ប៉ុន្តែវាគ្រោះថ្នាក់ខ្លាំងណាស់ចំពោះគាត់។ គាត់បានប្រើកំណាត់ឈើដើម្បីរែកស្បៀងនោះ។ គាត់តែងតែធ្វើបែបនេះសម្រាប់គ្រួសារ។ បន្ទាប់មកយើងបានត្រឡប់ទៅស្រុកកំណើតរបស់ មឿន វិញ។ យើងមិនមានអង្ករច្រើនសម្រាប់ដាំបាយហូបទេ ដូច្នេះ យើងបានយកមាសរបស់យើងដូរយកក្រម៉ាបានជាច្រើន។ បន្ទាប់មកយើងបានយកក្រម៉ាទៅដូរយកស្បៀង។ **ប៉ាង ពីរ័ន្ត និង វេនី ខកហ្មៀល**



សេក មឿន នៅខាងស្តាំ ជាមួយមិត្តភក្តិ
នៅព្រលានយន្តហោះពោធិចិនតុង ក្នុងឆ្នាំ១៩៦៦

# អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ

## បញ្ជីអដ្ឋិធាតុដែលរកឃើញនៅក្រោមបល្ល័ង្កព្រះពុទ្ធរូបក្នុងវត្តលង្កា, ទីក្រុងភ្នំពេញ

*រៀបរៀងដោយ៖ ចាន ប្រាថ្នា, សា ហ្វាទីលី, សុភ័ក្ត្រ ភាណា និង អ៊ុន សុដាវី*

*វិទ្យាស្ថានស្ទីករីត, ខែកុម្ភៈ ឆ្នាំ២០១៥*

(តពីលេខមុន)

| ល.រ | លេខកូដ | ឈ្មោះ ជាភាសាអង់គ្លេស | ឈ្មោះ | ភេទ | អាយុ | ថ្ងៃមរណភាព | ទំព័រក្នុងសៀវភៅ |
|---|---|---|---|---|---|---|---|
| ៣១០ | ៨៥៦០ | Nhanh Sarik | ញ៉ាញ សារីក | ? | ៤២ឆ្នាំ | ? | ១៧៥ |
| ៣១១ | ៨៥៧៣ | Kim Chhaya | គីម ឆាយា | ប្រុស | ? | ០៤/១២/១៩៨៩ | ១០៥ |
| ៣១២ | ៨៥៧៥ | Khiev Mit | ខៀវ មិត | ? | ៤៥ឆ្នាំ | ០២/០៦/១៩៩២ | ១០៥ |
| ៣១៣ | ៨៥៧៦ | Sok Chhann | សុខ ឆាន់ | ? | ៥១ឆ្នាំ | ១៦/០៧/១៩៨៨ | ១០៥ |
| ៣១៤ | ៨៥៧៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១០៥ |
| ៣១៥ | ៨៥៨២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១០៥ |
| ៣១៦ | ៨៦១៧ | Ta Kao | តា កៅ | ប្រុស | ? | ២៣/០១/១៩៩០ | ១៨២ |
| ៣១៧ | ៨៥៨៥ | Unknown | មិនដឹងឈ្មោះ | ? | ៤៣ឆ្នាំ | ២៩/១១/១៩៩០ | ១០៦ |
| ៣១៨ | ៨៥៨៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១០៦ |
| ៣១៩ | ៨៥៩១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១០៦ |
| ៣២០ | ៨៥៩០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១០៦ |
| ៣២១ | ៨៥៩៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១១១ |
| ៣២២ | ៨៥៩៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១១១ |
| ៣២៣ | ៨៦០០ | Saot Sinat | សោត ស៊ីណាត | ? | ? | ? | ១១១ |
| ៣២៤ | ៨៦០២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១១១ |
| ៣២៥ | ៨៦០៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១១១ |
| ៣២៦ | ៨៦០៦ | Mao Un | ម៉ៅ អ៊ុន | ? | ? | ១៩៧៤ | ១១២ |
| ៣២៧ | ៨៦០៨ | Uong Ponlork | អ៊ួង ពន្លក | ? | ? | ១៩៩៣ | ១១២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣២៨ | ៨៦០៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១១២ |
| ៣២៩ | ៨៦១២ | Lim Puch | លឹម ពុជ | ស្រី | ? | ? | ១១២ |
| ៣៣០ | ៨៦១៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១១២ |
| ៣៣១ | ៨៦១៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៨២ |
| ៣៣២ | ៨៦២០ | Chea Savorn | ជា សាវ៉ន | ? | ៤៤ឆ្នាំ | ១៦/០២/១៩៨៨ | 18១៨២ |
| ៣៣៣ | ៨៦២៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៨២ |
| ៣៣៤ | ៨៦២៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៨២ |
| ៣៣៥ | ៨៦៣០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៨៥ |
| ៣៣៦ | ៨៦៣៣ | Phok Kim | ផុក គិម | ? | ? | ? | ១៨៥ |
| ៣៣៧ | ៨៦៣៥ | Photo | មានរូបថត | ស្រី | ? | ? | ១៨៥ |
| ៣៣៨ | ៨៦៣៨ | Pech | ពេជន៍ | ? | ? | ? | ១៨៥ |
| ៣៣៩ | ៨៦៣៩ | Hao Seat | ហោ ស៊ាត | ? | ? | ១៩៨៧ | ១៨៥ |
| ៣៤០ | ៨៦៤២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៨៦ |
| ៣៤១ | ៨៦៤៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៨៦ |
| ៣៤២ | ៨៦៤៧ | Thaong Kimpros | ថោង គីមប្រុស | ? | ? | ១៩៩៣ | ១៨៦ |
| ៣៤៣ | ៨៦៤៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៨៦ |
| ៣៤៤ | ៨៦៥៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៨៩ |
| ៣៤៥ | ៨៦៥៤ | San Yan | សាន យ៉ន | ? | ? | ១៩៨៨ | ១៨៦ |
| ៣៤៦ | ៨៦៥៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៩១ |
| ៣៤៧ | ៨៦៥៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៩២ |
| ៣៤៨ | ៨៦៦១ | Moeun Samon | មឿន សាម៉ុន | ? | ? | ០៦/១១/១៩៧២ | ១៩១ |
| ៣៤៩ | ៨៦៦២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៩១ |
| ៣៥០ | ៨៦៦៣ | Hang Soul | ហង្ស ស៊ូល | ? | ? | ៣១/១០/១៩៨៨ | ១៩១ |
| ៣៥១ | ៨៦៦៥ | Keo It | កែវ អ៊ិត | ? | ? | ១៩៨៣ | ១៩១ |
| ៣៥២ | ៨៦៧៦ | Se Leang | សែ លាង | ស្រី | ? | ០២/០៩/១៩៩៣ | ១៩២ |

(នៅមានត)

# ដំណឹងស្វែងរកឪពុក

នាងខ្ញុំឈ្មោះ ស៊ូ បូរ៉ាមី ភេទស្រី អាយុ៥១ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិ៥ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។ នាងខ្ញុំជាកូនច្បងនៅក្នុងគ្រួសារ ដែលមានបងប្អូនបង្កើតចំនួន៣នាក់៖ ទី១) នាងខ្ញុំ,ទី២) ស៊ូ ពេជ្រ (ភេទប្រុស),ទី៣) ស៊ូ សុធារី (ភេទស្រី) និង ទី៤) ស៊ូ ស្រីល័ក្ខ (ភេទស្រី)។ នាងខ្ញុំមានម្ដាយឈ្មោះ អោម ណារី និងឪពុកឈ្មោះ ស៊ូ ណែម។

នាងខ្ញុំសូមប្រកាសរកឪពុកឈ្មោះ ស៊ូ ណែម។ នៅពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តកំពង់ស្ពឺ។ នៅទីនោះមិនបានប៉ុន្មានខែផង ខ្មែរក្រហមក៏បានជម្លៀសគ្រួសារនាងខ្ញុំ ទៅរស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ នៅឆ្នាំ១៩៧៦ ឪពុករបស់នាងខ្ញុំត្រូវបានខ្មែរ-ក្រហម ហៅទៅរៀនសូត្រនៅផ្សារមួយក្នុងឃុំព្រះនេត្រព្រះ បន្ទាប់មកខ្មែរក្រហមបានយកគាត់ដាក់នៅវត្តព្រះនេត្រព្រះ ជាមួយឈ្មោះ ម៉ែន ហឿន ដែលជាមិត្តភក្តិជិតស្និទ្ធរបស់គាត់ និងអ្នកដែលមានចំណេះដឹងប្រមាណ ៥០នាក់ទៀត។

ក្រោយរបបខ្មែរក្រហមបានដួលរលំ ម្ដាយនាងខ្ញុំបានជួបជាមួយអ្នកធ្លាប់ធ្វើម្ហូប និងដាំបាយនៅគុកទួលស្លែង ដែលផ្ទះរបស់គាត់នៅជាប់ជាមួយផ្ទះរបស់ខ្ញុំកាលពីសង្គមចាស់។ គាត់បានប្រាប់ម្ដាយខ្ញុំថា គាត់បានឃើញខ្មែរក្រហមដឹកឪពុករបស់ខ្ញុំ ចូលទៅគុកទទួលស្លែងយ៉ាងច្បាស់ផ្ទាល់ភ្នែក។ ទោះបីជាយ៉ាងនេះក្តី នាងខ្ញុំបានខិតខំស្វែងរករូបថត និងចម្លើយសារភាពរបស់ឪពុកខ្ញុំ តែរកមិនឃើញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ប្រសិនបើបងប្អូនណាបានស្គាល់ ឬធ្លាប់ឮឈ្មោះ ឪពុកនាងខ្ញុំឈ្មោះ ស៊ូ ណែម សូមមេត្តាទំនាក់ទំនងតាមរយៈអាសយដ្ឋាន៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬតាមរយៈទូរសព្ទលេខ៖ ០២៣ ២១៨ ០ ០៩ ឬ ០១២ ៩៩៦ ៧៥០ និងសារអេឡិចត្រូនិច៖ truthbunthorn.s@dccam.org។

**សូមអរគុណ!**



ស៊ូ បូរ៉ាមី បច្ចុប្បន្នជាគ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ



ឪពុកម្ដាយ និងប្អូនប្រុសរបស់ បូរ៉ាមី




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org



A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 231, March 2019 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M BRK, 30 Ocotber 2018.